

# ការបាត់បង់បឹងទំពុន

## ការវាយតម្លៃហេតុប៉ះពាល់សង្គម និងសិទ្ធិមនុស្ស
## អំពីការបំផ្លាញតំបន់បឹងទំពុន ឬជើងឯក

របាយការណ៍ចេញផ្សាយខែ កក្កដា ឆ្នាំ២០២០

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា

របាយការណ៍នេះត្រូវបានរៀបរៀងបោះពុម្ពផ្សព្វផ្សាយដោយមានការឧបត្ថម្ភពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស។ ទស្សនៈ និងបទបង្ហាញនានាក្នុងអត្ថបទនេះ គឺជាការទទួលខុសត្រូវទាំងស្រុងរបស់អង្គការសម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ បណ្តាញយុវជនកម្ពុជា អង្គការសមធម៌កម្ពុជា និងអង្គការសមាគមធាងត្នោត វាមិនមែនជាការឆ្លុះបញ្ចាំងពី ទស្សនៈរបស់អង្គការសហប្រជាជាតិឡើយ។

របាយការណ៍នេះត្រូវបានរៀបរៀងបោះពុម្ពផ្សព្វផ្សាយដោយមានការឧបត្ថម្ភគាំទ្រផ្នែកហិរញ្ញវត្ថុពីសហភាពអឺរ៉ុប។ ទស្សនៈ និងបទបង្ហាញនានាក្នុងអត្ថបទនេះ គឺជាការទទួលខុសត្រូវទាំងស្រុងរបស់ អង្គការសម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ បណ្តាញយុវជនកម្ពុជា អង្គការសមធម៌កម្ពុជា និងអង្គការសមាគមធាងត្នោត វាមិនមែនជាការឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបឡើយ ។

*ប្រទេសកម្ពុជាគឺជាប្រទេសមួយដែលមានពាក់កណ្ដាលជាផ្ទៃដី ពាក់កណ្ដាលជាផ្ទៃទឹក។ ទីក្រុងមិនគួរត្រូវបានសាងសង់ដោយការចាក់បំពេញដីឡើយប៉ុន្តែគួរតែមានការបញ្ចូលផ្ទៃទឹកទៅក្នុងផែនការសាងសង់។*

– លោក វណ្ណ មូលីវណ្ណ[១]

[១] សម្រង់សំដីនៅក្នុងសន្និសីទមជ្ឈមណ្ឌលវប្បធម៌បារាំង ថ្ងៃទី ២១ ខែឧសភា ឆ្នាំ១៩៩៩ សរសេរដោយ ហ្វាស័រ អឹម(Falser M) ក្នុងបេសកម្មកេត្តិ៍តំណែលវប្បធម៌។ បោះពុម្ពដោយស្ព្រីនធ័រអន្តរជាតិ(Sprinter International) ក្នុងឆ្នាំ២០១៥

# មាតិកា


បញ្ជីពាក្យកាត់......iv

១. ខ្លឹមសារសង្ខេប......១

២. វិធីសាស្ត្រស្រាវជ្រាវ......៤

៣. តំបន់ដីសើម......៧

៤. ការសាងសងគម្រោងឋានសួគ៌៖ គម្រោងអភិវឌ្ឍន៍ដែលបំផ្លាញតំបន់បឹងទំពុន ឬជើងឯក......១០

៥. ការរកឃើញសំខាន់ៗ...... ២២

អ្នកចូលរួមការស្ទង់មតិ......២៣

បំណុល......២៤

ការវិភាគលើបញ្ហាយេនឌ័រ......២៥

សិទ្ធិក្នុងការទទួលបានលំនៅឋានសមរម្យ......២៥

សិទ្ធិទទួលបានសន្តិសុខសង្គម......២៨

សិទ្ធិក្នុងការទទួលបានការងារធ្វើ...... ២៩

សិទ្ធិទទួលបានម្ហូបអាហារ...... ៣០

សិទ្ធិក្នុងការចូលរួមក្នុងកិច្ចការសាធារណៈ......៣២

សិទ្ធិក្នុងការទទួលបានទឹកស្អាត អនាម័យ និងសិទ្ធិទទួលបានសុខភាពល្អ...... ៣៤

ការបូមខ្សាច់......៣៩

ការបាត់បង់ជីវចម្រុះដោយសារការបំផ្លាញតំបន់ដីសើម......៤១

ប្រព្រឹត្តកម្មទឹកកខ្វក់...... ៤២

៦. សេចក្តីសន្និដ្ឋាន......៤៣

៧. អនុសាសន៍ និងជម្រើសផ្សេងៗ......៤៣

៨. ឧបសម្ព័ន្ធ...... ៤៦

# បញ្ជីពាក្យកាត់

| | |
|---|---|
| CYN | បណ្ដាញយុវជនកម្ពុជា |
| EC | អង្គការសមធម៌កម្ពុជា |
| EIA | ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន |
| FPIC | ការយល់ព្រមជាមុន ដោយសេរី និងដោយទទួលបានព័ត៌មានគ្រប់គ្រាន់ |
| ICCPR | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| ICERD | អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ |
| ICESR | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ |
| IUCN | សហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ |
| JICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ-ជប៉ុន (ចៃកា) |
| LICADHO | សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្សលីកាដូ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MPP | សាលារាជធានីភ្នំពេញ |
| MOWRAM | ក្រសួងធនធានទឹក និងឧតុនិយម |
| NHS | គោលនយោបាយជាតិស្តីពីលំនៅឋាន |
| OHCHR | ការិយាល័យឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស នៃអង្គការសហប្រជាជាតិ |
| RGC | រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា |
| SHRIA | ការវាយតម្លៃហេតុប៉ះពាល់សង្គម និងសិទ្ធិមនុស្ស |
| SIA | ការវាយតម្លៃហេតុប៉ះពាល់សង្គម |
| STT | អង្គការសមាគមធាងត្នោត |
| UDHR | សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស |
| UN | អង្គការសហប្រជាជាតិ |

# ខ្លឹមសារសង្ខេប

## ការអភិវឌ្ឍគឺជាទឹកភ្នែករបស់ប្រជាជនក្រីក្រ

### កសិករពីបឹងទំពុន

នៅឆ្នាំ២០០៤ គម្រោង អាយ អិន ជី ស៊ីធី (ING City) បាន និង កំពុងបំផ្លាញបឹងទំពុន ឬជើងឯកក្នុងរាជធានីភ្នំពេញ ហើយបន្តគំរាមកំហែងដល់ជីវភាពរស់នៅ និងលំនៅឋានរបស់ប្រជាពលរដ្ឋជាងមួយពាន់ គ្រួសារ ប្រព័ន្ធអេកូឡូស៊ីក្នុងបឹង និងជីវចម្រុះកំពុងបន្តបាត់បង់។ ប្រជាពលរដ្ឋជាងមួយលាននាក់កំពុងប្រឈមនឹងគ្រោះទឹកជំនន់ធ្ងន់ធ្ងរ អសន្តិសុខស្បៀងការបំពុលទឹកក្នុងទន្លេមេគង្គ ទន្លេបាសាក់ដោយទឹកស្អុយ ដែលមិនបានចម្រោះត្រឹមត្រូវ និងជាការបំពុល ដែលអាចបង្កគ្រោះថ្នាក់ ដល់ប្រជាពលរដ្ឋ។តំបន់បឹងទំពុន ឬជើងឯក គឺជាតំបន់ការពារទឹកជំនន់ដ៏សំខាន់សម្រាប់រាជធានីភ្នំពេញ ក៏ដូចជាប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អាតតែមួយគត់របស់ទីក្រុង។ បច្ចុប្បន្នគម្រោង អាយ អិន ជី ស៊ីធី និងក្រុមដទៃទៀត កំពុងតែចាក់ដី និងខ្សាច់បំពេញបឹង និងបង្កើតជាតំបន់អចលនទ្រព្យ។

តំបន់បឹងទំពុន ឬជើងឯកនេះ មានទំហំយ៉ាងហោចណាស់ ១.៥០០ហិកតានៅភាគខាងត្បូងនៃរាជធានីភ្នំពេញក្នុងខណ្ឌមានជ័យ និងជាប់ក្រុងតាខ្មៅ។ បឹងនេះជាផ្នែកមួយដ៏សំខាន់ក្នុងការកាត់បន្ថយទឹកជំនន់ ក្នុងរាជធានីភ្នំពេញដោយទឹកភ្លៀង និងទឹកស្អុយប្រមាណ ៧០% បានហូរចូលទៅក្នុងបឹងនេះ[២]។ ការដាំដំណាំនៅលើទឹកគឺជួយចម្រោះសំណល់ក្នុងទឹកកខ្វក់បានពាក់កណ្តាលមុនពេលចូលទៅក្នុងទន្លេបាសាក់[៣]។ រាជធានីភ្នំពេញមិនទាន់មានរោងចក្រប្រព្រឹត្តកម្មទឹកស្អុយនៅឡើយទេ ហើយការបាត់បង់បឹងទំពុនជាផលលំបាកដល់ជម្រកត្រីក្នុងទន្លេមេគង្គ និងទន្លេបាសាក់។ បរិមាណទឹកស្អុយជាច្រើននឹងមិនត្រូវបានសម្អាត ហើយទឹកកាន់តែកខ្វក់។

ផ្ទៃបឹងជាង ៩០% នឹងត្រូវបំផ្លាញដោយការកាត់ដីថ្មីៗ ដែលត្រូវបានគ្រប់គ្រងដោយអនុក្រឹត្យ[៤]។ លទ្ធផលបង្ហាញថាហេតុអ្វីតំបន់ជីវៈចម្រុះដ៏សម្បូណ៌បែបមួយដែលមានទំហំជាង ១៥០០ ហិកតា ត្រូវកាត់ទៅជាប្រឡាយតូចមួយ ដែលមានទំហំតិចជាង ១០៧ ហិកតា។ បច្ចុប្បន្នតាមរយៈរូបភាពផ្កាយរណបបានបង្ហាញថាប្រហែលមួយភាគបីនៃបឹងទំពុនត្រូវបានចាក់ខ្សាច់បំពេញ និងនៅសល់តែប្រហែល ១.០០០ ហិកតាប៉ុណ្ណោះ[៥]។



[២] សាលាក្រុងប៉ារីស និងសាលារាជធានីភ្នំពេញ (ឆ្នាំ២០១៨)៖ សៀវភៅស្តីអំពី ការពង្រីក និងការផ្លាស់ប្តូរនៃរាជធានីភ្នំពេញ ទំព័រទី ៣៨

[៣] ការស្រាវជ្រាវរបស់អង្គការចៃកា (JICA) បានបង្ហាញថាតំបន់ដីសើមអាចជួយចម្រោះទឹកសម្អុយដោយមានប្រសិទ្ធភាពបានពាក់កណ្តាលក្នុងរាជធានីភ្នំពេញ។ អង្គការចៃកា (JICA)" របាយការណ៍ស្ទង់មតិលើគម្រោងអភិវឌ្ឍន៍រោងចក្រប្រព្រឹត្តកម្មទឹកសម្អុយក្នុងរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា" ឆ្នាំ ២០១៩ ។

[៤] អនុក្រឹត្យលេខ ២៦ អនក្រ.បក (ឆ្នាំ២០១២) ស្តីពីការកែសម្រួលអនុក្រឹត្យ ១២៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ ២០០៨ របស់រាជរដ្ឋាភិបាល ស្តីពីការកំណត់ផ្ទៃបឹងជើងឯក និងប្រឡាយ ស្ថិតក្នុងខណ្ឌមានជ័យ និងខណ្ឌដង្កោ រាជធានីភ្នំពេញ និងស្រុកតាខ្មៅ ខេត្តកណ្តាល ជាសម្បត្តិសាធារណៈរបស់រដ្ឋ អនុក្រឹត្យលេខ ៧០ អនក្រ.បក ឆ្នាំ២០១៧ និងអនុក្រឹត្យលេខ ០៥ លេខ១២ លេខ ១៤៨ និងលេខ ១៦៨ (ឆ្នាំ២០១៨) ស្តីពីការកែសម្រួលផ្ទៃបឹងជើងឯក ស្ថិតក្នុងខណ្ឌមានជ័យ និងខណ្ឌដង្កោ រាជធានីភ្នំពេញ និងក្រុងតាខ្មៅ ខេត្តកណ្តាល

[៥] សូមមើលផែនទីនៅទំព័រ ទី១២

## ច្បាប់ស្តីពីសិទ្ធិមនុស្ស និងនីតិរដ្ឋ

បឹងទំពុន គឺជាផ្ទះរបស់ប្រជាពលរដ្ឋជាងមួយពាន់គ្រួសារ ដែលកំពុងរស់នៅនិងប្រើប្រាស់តំបន់នេះ សម្រាប់ធ្វើកសិកម្ម និងនេសាទ[៦]។ប្រទេសកម្ពុជាត្រូវបានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិ[៧] មួយចំនួនដើម្បីការពារ និងអនុវត្តសិទ្ធិមនុស្សតាមរយៈច្បាប់អន្តរជាតិ ប៉ុន្តែមានការព្រួយបារម្ភថានឹងមានការរំលោភសិទ្ធិមនុស្សកើតឡើងដោយគ្មានការការពារល្អប្រសើរ។ សិទ្ធិដែលអាចប៉ះពាល់ ឬកំពុងរងផលប៉ះពាល់រួចហើយដោយគម្រោងអភិវឌ្ឍន៍រួមមាន សិទ្ធិមានលំនៅឋាន សិទ្ធិទទួលបានសន្តិសុខសង្គម សិទ្ធិធ្វើការងារ សិទ្ធិទទួលបានចំណីអាហារ សិទ្ធិចូលរួមក្នុងកិច្ចការសង្គម សិទ្ធិទទួលបានទឹកស្អាតនិងអនាម័យ សិទ្ធិទទួលបានការអប់រំ និងសិទ្ធិទទួលបានសុខភាព។

ការបណ្តេញចេញដោយបង្ខំ គឺប្រាកដជាអាចកើតឡើង សម្រាប់ប្រជាពលរដ្ឋរាប់រយគ្រួសារ ដែលរស់នៅតំបន់បឹងទំពុន។ នៅក្នុងរបាយការណ៍មួយឆ្នាំ២០១៨ ដែលចុះហត្ថលេខាដោយអភិបាលរាជធានីភ្នំពេញបានកត់សម្គាល់លើការផ្លាស់ទីលំនៅជាច្រើន ទំនងជាកើតមាននៅទីតាំងតាមបណ្តោយប្រឡាយ ដែលត្រូវពង្រីកដើម្បីឱ្យទឹកហូរចេញពីបឹងទៅទន្លេបាសាក់[៨]។ ការស្រាវជ្រាវនេះ បង្ហាញថាគ្រួសារភាគច្រើន ដែលរស់នៅលើ ឬជុំវិញបឹងមិនមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ (ប្លង់រឹង) ឡើយ ហើយសហគមន៍មួយចំនួនចាប់ផ្តើមទទួលការគំរាមកំហែង នៃការបណ្តេញចេញដោយមិនមានការពិគ្រោះយោបល់។

ការបាត់បង់មុខរបរចិញ្ចឹមជីវិត ត្រូវបានក្លាយជាបទពិសោធន៍សម្រាប់គ្រួសារជាច្រើនដែលបានបាត់បង់កន្លែងដាំដំណាំនៅបឹងទំពុន។ ទីនោះជាទីកន្លែង ដែលពួកគេពឹងផ្អែកក្នុងការចិញ្ចឹមជីវិតរាប់ឆ្នាំមកហើយ។ការធ្វើកសិកម្មលើទឹកផ្តល់គុណតម្លៃជាច្រើន ព្រោះថាដំណាំលើទឹកអាចបន្សុទ្ធទឹកស្អុយបានពាក់កណ្តាលប្រកបដោយប្រសិទ្ធភាព ហើយគ្រួសារក្រីក្រអាចប្រមូលផលបន្លែទៅលក់នៅផ្សារ សម្រាប់ប្រភពចំណូល។ ផលប៉ះពាល់អវិជ្ជមាននឹងកើតមានកាន់តែធ្ងន់ធ្ងរមកលើគ្រួសារទាំងនេះ ដោយពួកគេមានបំណុលជាច្រើន ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងអ្នកផ្តល់កម្ចីឯកជន ដែលអាចបង្ខំឱ្យជីវភាពរបស់ពួកគេស្ថិតក្នុងស្ថានភាពកាន់តែអាក្រក់។

សហគមន៍ជាច្រើនមិនបានដឹងពីផែនការរបស់គម្រោងអាយ អិន ជី នោះទេ និងមិនទទួលបានការពិគ្រោះយោបល់ ឬការជូនដំណឹងជាមុនពីក្រុមហ៊ុន អាយ អិន ជី ហូលឌីង ឬរាជរដ្ឋាភិបាលឡើយ។ សហគមន៍អាចដាក់ឈ្មោះក្រុមហ៊ុនធំៗ ដែលទទួលខុសត្រូវចំពោះការបំផ្លាញបឹង មានដូចជា ផ្សារទំនើបអ៊ីអន ឬក្រុមហ៊ុនជីបម៉ុងគ្រុប និងមានតែសហគមន៍មួយប៉ុណ្ណោះ ដែលបានជួបជាមួយក្រុមហ៊ុនផ្ទាល់។

ទឹកស្អុយជាច្រើនប្រមាណជា ៣៧០.០០០ ម៉ែត្រគូបក្នុងមួយថ្ងៃ ត្រូវបានហូរមកពីរាជធានីភ្នំពេញចូលទៅក្នុងបឹងទំពុន។ ជិតពាក់កណ្តាលនៃរាជធានីភ្នំពេញ មានប្រជាពលរដ្ឋប្រហែល ១.២លាននាក់នឹងប្រឈមការជន់លិចដោយទឹកជំនន់ដែលជាទឹកកខ្វក់ ប្រសិនបើបឹងទំពុននៅតែបន្តលុប។ បឹងទំពុនមានសារៈសំខាន់ណាស់ក្នុងការស្តុកទឹកជំនន់ដែលការពាររាជធានីភ្នំពេញ និងទីក្រុងតាខ្មៅពីការជន់លិចទឹកកខ្វក់ នៅរដូវកាលទឹកទន្លេបាសាក់ឡើងហើយហូរចូលក្នុងបឹងទំពុន។

រាជរដ្ឋាភិបាលកម្ពុជាហាក់ដូចជា ជួលដីសាធារណៈរបស់រដ្ឋដល់ក្រុមហ៊ុនឯកជន ដោយមិនបានពិគ្រោះយោបល់ជាសាធារណៈតាមមធ្យោបាយល្អៗ ផ្សេងៗណាមួយឡើយ។ គ្រួសារជាច្រើននៅតំបន់បឹងទំពុនបានត្អូញត្អែរច្បាប់មិនអនុវត្តឱ្យពួកគេកាន់កាប់ដីតំបន់បឹងទំពុនបានទេ ប៉ុន្តែសម្រាប់ក្រុមហ៊ុន និងបុគ្គលឯកជន ដែលកំពុងសាងសង់គម្រោងនៅតំបន់នោះទទួលបានសិទ្ធិកាន់កាប់ទៅវិញ។ តំបន់បឹងទំពុនជាដីសាធារណៈរបស់រដ្ឋ បើទោះបីជាដីនោះមិនមានការបញ្ជាក់ក៏ដោយ។ ដីសាធារណៈរបស់រដ្ឋ មិនអាចធ្វើចំណាត់ថ្នាក់ឡើងវិញសម្រាប់ការអភិវឌ្ឍបានទេ ដរាបណាដីនោះបាត់បង់ផលប្រយោជន៍ជាសាធារណៈ។ បឹងទំពុនផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ការប្រើប្រាស់ជាសាធារណៈ ដូចជាការការពារទឹកជំនន់ ការសម្អាតទឹកស្អុយ ផ្តល់ជាផ្ទះ និងជីវភាពដល់ប្រជាពលរដ្ឋជាងមួយពាន់គ្រួសារ។

---

[៦] ការស្ទង់មតិ និងការស្រាវជ្រាវរបស់អង្គការសមាគមធាងត្នោត ឆ្នាំ២០១៩។

[៧] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌(១៩៦៦) អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (១៩៦៩) អនុសញ្ញាទាក់ទងនឹងឋានៈជនភៀសខ្លួន (១៩៥១) អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (១៩៧៩) អនុសញ្ញាស្តីពីសិទ្ធិកុមារ (១៩៨៩) អនុសញ្ញាស្តីពីសិទ្ធិរបស់ជនពិការ (២០០៨) ។

[៨] សាលាក្រុងប៉ារីស និងសាលារាជធានីភ្នំពេញ ឆ្នាំ២០១៨ ទីក្រុងភ្នំពេញ៖ ការពង្រីក និងការផ្លាស់ប្តូរ ទំព័រទី៤៣។

## ការបាត់បង់បរិស្ថាន

លទ្ធផលនៃការបំផ្លាញ ឬការថយចុះបរិមាណ និងសមត្ថភាពរបស់បឹងទំពុន ធ្វើឱ្យដំណើរការប្រព្រឹត្តកម្មទឹកសំណល់ធម្មជាតិ ត្រូវបានចាត់ទុកជាមោឃៈ ឬថយចុះគួរឱ្យកត់សម្គាល់ហើយទឹកទន្លេមេគង្គ និងទន្លេបាសាក់នឹងត្រូវបានបំពុល។ បច្ចុប្បន្នការដាំដំណាំលើផ្ទៃបឹង ជួយសម្អាតឬចម្រោះទឹកកខ្វក់មុនពេលហូរចូលទៅទន្លេបាសាក់[៩]។ ដំណាំទាំងនេះ គឺជាដំណាំដែលស្ថិតនៅចន្លោះទឹកកខ្វក់ពីរាជធានីភ្នំពេញ និងត្រីរស់នៅតាមដងទន្លេតូចមួយនៅជុំវិញតាខ្មៅ ទន្លេមេគង្គ និងទន្លេបាសាក់។ ប្រសិនបើបឹងទំពុនត្រូវបានបាត់បង់ទឹកស្អុយនឹងត្រូវប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ការរស់នៅរបស់ត្រី និងសហគមន៍ដែលពឹងផ្អែកលើទន្លេទាំងនេះ ជាទឹកបរិភោគ និងចំណីអាហារ។

មានការរំពឹងទុកថា ការបាត់បង់ជីវចម្រុះ គឺជាប្រភេទត្រីកម្រដែលជិតផុតពូជ។ បឹងទំពុនគឺជាជម្រកសត្វ[១០] ជាច្រើនប្រភេទក្នុងនោះមានត្រីពីរប្រភេទ និងបក្សីមួយប្រភេទកំពុងរងការគំរាមកំហែង[១១]។ ត្រីខ្លះត្រូវបានចុះបញ្ជីជិតផុតពូជដោយបទប្បញ្ញត្តិ[១២] របស់កម្ពុជាហើយជាប្រភេទសត្វជិតផុតពូជនៅក្រោមបញ្ជីក្រហមរបស់ អាយ យូ ស៊ី អិន។[១៣ ១៤]

ជាចុងក្រោយបរិមាណខ្សាច់ដ៏ច្រើនសន្ធឹកសន្ធាប់ ដែលត្រូវបានចាក់លុបបឹងទំពុនអាចបង្កឱ្យខូចខាតយ៉ាងខ្លាំងដល់ទន្លេមេគង្គ និងទន្លេបាសាក់។ ការស្រាវជ្រាវថ្មីៗនេះ រកឃើញថា ការបូមខ្សាច់ហួសកម្រិត នៅក្នុងប្រទេសកម្ពុជាផ្តល់ផលប៉ះពាល់គួរឱ្យកត់សម្គាល់ លើស្ថេរភាពច្រាំងទន្លេ[១៥]។ បរិមាណខ្សាច់ ដែលត្រូវការដើម្បីចាក់លុបបឹងត្រូវបានគេប៉ាន់ប្រមាណថាមានចំនួន៧៧.000.000 ម៉ែត្រគូប[១៦] ។ ការចាក់បំពេញបឹងទំពុនត្រូវបានគេប៉ាន់ស្មានថា នឹងត្រូវការខ្សាច់ច្រើនជាងគម្រោងដទៃទៀតនៅក្នុងប្រវត្តិសាស្ត្រ របស់ប្រទេសកម្ពុជា។

---

[៩] ការស្រាវជ្រាវរបស់អង្គការចៃកា (JICA) បានបង្ហាញថាតំបន់ដីសើមអាចជួយចម្រោះទឹកសម្អុយដោយមានប្រសិទ្ធភាពបានពាក់កណ្តាលក្នុងរាជធានីភ្នំពេញ។ អង្គការចៃកា (JICA)" របាយការណ៍ស្ទង់មតិលើគម្រោងអភិវឌ្ឍន៍រោងចក្រប្រព្រឹត្តកម្មទឹកសម្អុយក្នុងរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា" ឆ្នាំ ២០១៩ ។

[១០] ដូចខាងលើ

[១១] ដូចខាងលើ

[១២] អនុក្រឹត្យលេខ ១២៣ អនក្រ.បក ស្តីពីការកំណត់ប្រភេទផល ផលិតផលជលផលដែលកំពុងគ្រោះថ្នាក់ ឆ្នាំ២00៩។

[១៣] Hogan, Z. ឆ្នាំ២០១១ Catlocarpio siamensis។ បញ្ជីប្រភេទសត្វដែលត្រូវបានគំរាមកំហែងរបស់ IUCN Red ឆ្នាំ២០១១៖ e.T180662A7649359. https://dx.doi.org/10.2305/IUCN.UK.2011-1.RLTS.T180662A7649359.en. ទាញយកកាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០។

[១៤] Ahmad, A.B. ឆ្នាំ២០១៩ Probarbus jullieni ។ បញ្ជីប្រភេទសត្វដែលត្រូវបានគំរាមកំហែងរបស់ IUCN Red ឆ្នាំ២០១៩ e.T18182A1728224. https://dx.doi.org/10.2305/IUCN.UK.2019-2.RLTS.T18182A1728224.en. អាចទាញយកបានក្នុងថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០។

[១៥] ហេគនី(Hackney), C R., et al,ឆ្នាំ ២០២០៖ អស្ថិរភាពនៅច្រាំងទន្លេពីការបូមខ្សាច់គ្មាននិរន្តរភាពនៅទន្លេមេគង្គក្រោម។ សូមមើលគេហទំព័រ៖ www. nature.com/natsustain.

[១៦] ការគណនាផ្អែកលើជម្រៅខុសគ្នានៃបឹង ហើយយើងបានបន្ថែមកម្ពស់១ម៉ែត្រទៀតដើម្បីឱ្យលើកម្រិតទឹកជំនន់។ ការគណនាទំនងជាអាចខុសគ្នា ហើយយើងមិនអាចគណនាបានត្រឹមត្រូវដូចការសិក្សាបែបវាស់វែងលម្អិតរបស់គម្រោង អាយ អិន ជី និងគម្រោងពាក់ព័ន្ធឡើយ។ ដីខ្សាច់សរុបដែលត្រូវចាក់បំពេញប្រហែលជាអាចមានតិច ឬច្រើនជាងនេះទៅតាមទំហំនៃការចាក់បំពេញជាក់ស្តែង ក៏ប៉ុន្តែចំនួនបន្ថែម១ម៉ែត្រនេះ គឺជាកម្ពស់ទាបបំផុតចំពោះបទពិសោធន៍ដែលយើងបានដឹងនៃការចាក់បំពេញកន្លងមកក្នុងតំបន់នេះ។

# ២. វិធីសាស្ត្រស្រាវជ្រាវ

របាយការណ៍នេះ ប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវចម្រុះផ្អែកលើ ទ្រឹស្តីការវាយតម្លៃហេតុប៉ះពាល់ ជាពិសេសទ្រឹស្តីការវាយតម្លៃ ហេតុប៉ះពាល់សង្គមវិធីសាស្ត្រស្រាវជ្រាវផ្អែកលើសិទ្ធិមនុស្ស ការគូសផែនទីភូមិសាស្ត្រសហគមន៍ ការស្រាវជ្រាវនៅទីតាំងផ្ទាល់ របាយការណ៍ពិនិត្យតាមដានការសិក្សាទៅលើឯកសារពាក់ព័ន្ធ ការវិភាគផ្នែកច្បាប់ បទសម្ភាសជាមួយភាគីពាក់ព័ន្ធសំខាន់ៗ និងការស្ទង់មតិតាមគ្រួសារ។

**គោលបំណង៖** របាយការណ៍នេះ មានគោលបំណងវាយតម្លៃហេតុប៉ះពាល់សង្គម និងសិទ្ធិមនុស្ស ដែលនឹងអាចកើតមាន កំពុងកើតមានឬបានកើតមានចំពោះប្រជាសហគមន៍ងាយរងគ្រោះ ដោយសារតែគម្រោងទីក្រុងរណប អាយ អិន ជី ស៊ីធី ឬគម្រោងអភិវឌ្ឍន៍ដទៃទៀតនៅក្នុងតំបន់បឹងទំពុន ឬជើងឯក។ របាយការណ៍នេះក៏មានគោលបំណងចូលរួមផ្សព្វផ្សាយព័ត៌មានពីគម្រោងអភិវឌ្ឍន៍នេះដល់ប្រជាសហគមន៍ស្របតាមគោលការណ៍នៃការយល់ព្រមជាមុន ដោយសេរី និងដោយទទួលបានព័ត៌មានគ្រប់គ្រាន់(FPIC) និងផ្តល់ឱកាសឱ្យសមាជិកសហគមន៍សម្តែងនូវមតិយោបល់ចំពោះគម្រោងដែលបានស្នើឡើង និងផលដែលអាចកើតឡើងពីគម្រោងនេះ ក៏ដូចជាការរំលឹកដល់សាធារណជន និងរាជរដ្ឋាភិបាលផងដែរ អំពីសក្តានុពលនៃហេតុប៉ះពាល់ដែលអាចកើតមានដោយសារការបំផ្លិចបំផ្លាញតំបន់បឹងទំពុន ឬជើងឯកទាំងនេះ ។

**ការសិក្សាលើឯកសារពាក់ព័ន្ធ ការវិភាគផ្នែកច្បាប់ បទសម្ភាសជាមួយភាគីពាក់ព័ន្ធ៖** ឯកសារស្រាវជ្រាវ ពីសហគមន៍នាពេលកន្លងមកនិងរបាយការណ៍ពិនិត្យតាមដាន ពាក់ព័ន្ធនឹងក្រុមងាយរងគ្រោះ នៅក្នុងទីតាំងគម្រោងត្រូវបានសិក្សានិងត្រូវបានយកប្រើប្រាស់ជាមូលដ្ឋានដើម្បីរៀបចំសេចក្តីព្រៀងការស្ទង់មតិសម្រាប់ការវាយតម្លៃហេតុប៉ះពាល់សង្គម និងសិទ្ធិមនុស្ស(SHRIA)[១៧]។ លើសពីនេះទៀត ក្រុមអ្នកស្រាវជ្រាវក៏បានសិក្សាទៅលើគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនានា។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ដែលធ្វើការក្នុងវិស័យនេះត្រូវបានជ្រើសរើសដើម្បីចូលរួមក្នុងបទសម្ភាសជាភាគីពាក់ព័ន្ធសំខាន់ៗ ក៏ប៉ុន្តែក្រុមការងារមិនបាន ធ្វើការសម្ភាសជាមួយក្រុមហ៊ុន និងរាជរដ្ឋាភិបាលឡើយ។ ក្រុមហ៊ុនធំៗ ដែលមានចំណែកនៅក្នុងគម្រោងទីក្រុងរណប អាយ អិន ជី ស៊ីធី ក៏ដូចជាស្ថាប័នរដ្ឋដែលពាក់ព័ន្ធ និងក្រុមហ៊ុនអភិវឌ្ឍន៍ផ្សេងទៀតនៅក្នុងសហគមន៍បឹងទំពុន ឬជើងឯក នេះមិនត្រូវបានសម្ភាសឡើយដោយសារតែពេលវេលាមានកំណត់ និងការព្រួយបារម្ភពីសុវត្ថិភាព[១៨]។ ជាចុងក្រោយការសិក្សាលើឯកសារសំខាន់ៗ និងការស្រាវជ្រាវពីហេតុប៉ះពាល់បរិស្ថានដែលអាចកើតឡើងដោយសារការបំផ្លិចបំផ្លាញតំបន់បឹងនេះ បានផ្តល់ជាលទ្ធផលសំខាន់សម្រាប់ការរកឃើញអំពីផលប៉ះពាល់ទៅលើបរិស្ថាននៅក្នុងការសិក្សាស្រាវជ្រាវនេះ។ ទោះបីជាច្បាប់តម្រូវឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាមុនក៏ដោយ ក៏អ្នកស្រាវជ្រាវ មិនបានទទួលឯកសារវាយតម្លៃនោះទេ ដែលការនេះគឺជាឧបសគ្គរារាំង ដល់ការទទួលបានទស្សនៈទូលំទូលាយ ដើម្បីសិក្សាលើផលប៉ះពាល់ដល់បរិស្ថាន។

ការវាយតម្លៃហេតុប៉ះពាល់សង្គម និងសិទ្ធិមនុស្ស (SHRIA)៖ កម្រងសំណួរត្រូវបានចងក្រងឡើងដោយផ្តោតសំខាន់លើស្ថានភាពសង្គមសេដ្ឋកិច្ចរបស់អ្នកចូលរួម ការទទួលបានការគោរពសិទ្ធិមនុស្ស ការទទួលបានព័ត៌មានពីគម្រោងនៅក្នុងតំបន់បឹងទំពុន ឬជើងឯក និងសន្តិសុខផ្នែកសិទ្ធិកាន់កាប់ដីធ្លី។ បទសម្ភាស និងការប្រមូលទិន្នន័យត្រូវបានធ្វើឡើងនៅអំឡុងខែឧសភា ឆ្នាំ២០២០។

**ការបញ្ជាក់ទៅលើ ការរកឃើញនៃការស្ទង់មតិការវាយតម្លៃ ហេតុប៉ះពាល់សង្គម និងសិទ្ធិមនុស្ស៖** កិច្ចពិភាក្សាក្រុមដែលមានតំណាងមកពី ៨ សហគមន៍ត្រូវបានធ្វើឡើងនៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០។ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជម្ងឺ កូវីដ១៩ តាមរយៈការចាត់វិធានការរក្សាគំលាតសង្គម មានតែតំណាងសហគមន៍មកពី ៨ សហគមន៍ប៉ុណ្ណោះត្រូវបានអញ្ជើញចូលរួមក្នុងកិច្ចពិភាក្សានេះ។ តំណាងសហគមន៍ទាំងនេះត្រូវបានស្នើឱ្យផ្តល់ការបញ្ជាក់ ឬការជំទាស់ចំពោះការរកឃើញចម្បងៗ ជាច្រើននិងពិភាក្សាទូទៅអំពីផលប៉ះពាល់ ដែលសហគមន៍អាចនឹងជួបប្រទះនាពេលអនាគត។ ការស្រាវជ្រាវនេះ ក៏បានធ្វើការឆ្លុះបញ្ចាំងអំពីចំណុចដែលតំណាងសហគមន៍ មិនយល់ស្របឬមានទស្សនៈផ្សេងពីការរកឃើញផងដែរ។

**ក្រុមអ្នកផ្តល់បទសម្ភាសសំខាន់៖** ក្រុមអ្នកផ្តល់បទសម្ភាសគោលដៅចម្បងនៅក្នុងការស្ទង់មតិការវាយតម្លៃហេតុប៉ះពាល់សង្គម និងសិទ្ធិមនុស្សនេះគឺជាក្រុមងាយរងគ្រោះ និងក្រុមដែលធ្លាប់បាន ឬកំពុងប្រើប្រាស់តំបន់បឹងទំពុន ឬជើងឯក និងតំបន់ជាប់មាត់ប្រឡាយនៃបឹងពុន។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[១៩] បានឱ្យនិយមន័យក្រុមងាយរងគ្រោះថា

---

[១៧] សូមមើលឧបសម្ព័ន្ធទី៥

[១៨] របាយការណ៍ប្រចាំឆ្នាំចុងក្រោយរបស់ការិយាល័យឧត្តមស្នងការនៃអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធមនុស្ស និងរបាយការណ៍របស់ការិយាល័យឧត្តមស្នងការ និងអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ (២០១៩) បានផ្តល់ជាអនុសាសន៍ (ង) ដល់រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាឱ្យ "អនុញ្ញាតអង្គការសង្គមស៊ីវិលអនុវត្តន៍ការងារនៅថ្នាក់ក្រោមជាតិដោយមិនមានការឃាយឺង និងការឃ្លាំមើល ឬការដាក់កំហិតមិនសមហេតុផល"។

[១៩] យោងតាមនីតិវិធីប្រតិបត្តិស្តង់ដារនៃការតាំទីលំនៅដោយមិនស្ម័គ្រចិត្ត និងការទទួលយកដីសម្រាប់គម្រោងដែលទទួលមូលនីធិពីបរទេសនៅក្នុងប្រទេសកម្ពុជានៅឆ្នាំ២០១៨ ដែលបានប្រកាសឱ្យអនុវត្តជាផ្លូវការណ៍តាមរយៈមាត្រា១ នៃអនុក្រិតលេខ ២២ ស្តីពីការប្រកាសឱ្យអនុវត្តជាផ្លូវការនៃនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់គម្រោងដែលទទួលមូលនីធិពីបរទេសនៅក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៨។

ជាគ្រួសារក្រីក្រ គ្រួសារដែលមានស្ត្រីជាមេគ្រួសារ និងមានកូនក្នុងបន្ទុក គ្រួសារដែលមានមេគ្រួសារជាមនុស្សចាស់ជរាគ្មានមុខរបរច្បាស់លាស់ គ្រួសារដែលមានជនពិការជាមេគ្រួសារ អ្នកប្រើប្រាស់ដីតាមប្រពៃណី និងជនជាតិភាគតិចដែលគ្មានប័ណ្ណកម្មសិទ្ធិដីធ្លីស្របច្បាប់[២០] ។

**ទំហំសំណាកៈ** សមាជិកគ្រួសារសរុបចំនួន ៤៦៩នាក់ បានចូលរួមក្នុងការស្ទង់មតិ វាយតម្លៃហេតុប៉ះពាល់សង្គម និងសិទ្ធិមនុស្ស ដែលក្នុងនោះមាន ៣៥៩ នាក់ (៧៧%) គឺជាស្ត្រី ។ ចំនួនសរុបនៃក្រុមជនងាយរងគ្រោះខ្លាំង ដែលកំពុងប្រើប្រាស់តំបន់បឹងទំពុន និងប្រឡាយនានានៃបឹងទំពុនមានចំនួនចន្លោះពី ៩០០ ទៅ ១. ២០០[២១] នាក់ ដែលធ្វើឱ្យទំហំសំណាកនេះស្មើនឹងប្រមាណ ៣៩% ទៅ ៥២% នៃក្រុមគោលដៅ ។

**វិសាលភាពនៃការស្រាវជ្រាវៈ** ទំហំនៃការសិក្សានេះត្រូវបានកំណត់នៅត្រឹមការវាយតម្លៃថាក្រុមណាខ្លះដែលទំនងនឹងរងផលប៉ះពាល់ដោយសារតែគម្រោងនេះ ដោយរួមបញ្ចូលទាំងក្រុមប្រជាពលរដ្ឋ ដែលរស់នៅក្នុង និងក្រៅដែននៃគម្រោងផងដែរ។ ការស្ទង់មតិ វាយតម្លៃហេតុប៉ះពាល់សង្គម និងសិទ្ធិមនុស្ស បានធ្វើឡើងនៅទីតាំងចំនួន ១៥ កន្លែង នៅក្នុងតំបន់បឹងទំពុន ឬជើងឯក (សូមមើលឧបសម្ព័ន្ធទី៥)។ ប្រជាពលរដ្ឋជាច្រើនអាចនឹងរងការប៉ះពាល់ដោយសារតែគម្រោងអភិវឌ្ឍន៍នៅក្នុងតំបន់បឹងទំពុន ឬជើងឯក ដោយសារតែការជីកយកខ្សាច់ដើម្បីយកមកចាក់បំពេញដីនៅក្នុងតំបន់បឹងនេះ។ ប៉ុន្តែដោយសារតែកត្តាហិរញ្ញវត្ថុ និងពេលវេលាមិនគ្រប់គ្រាន់ ការស្ទង់មតិនេះមិនបានរួមបញ្ចូលក្រុមប្រជាពលរដ្ឋទាំងអស់ទេ។ ក្រុមប្រជាពលរដ្ឋមួយចំនួនដែលទំនងនឹងរងការប៉ះពាល់ឬកំពុងទទួលរងការប៉ះពាល់ ដោយសារការបំផ្លិចបំផ្លាញតំបន់បឹងមានដូចជាក្រុមដែលរងផលប៉ះពាល់ដោយសារ ការបូមខ្សាច់ដើម្បីចាក់បំពេញតំបន់បឹង ក្រុមដែលរងផលប៉ះពាល់ដោយសារការបាត់បង់បរិមាណត្រី និងប៉ះពាល់ដល់សាធារណជន ដែលរស់នៅក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ។

**ដែនកំណត់នៃការសិក្សាៈ** ការរកឃើញនៅក្នុងរបាយការណ៍នេះ ភាគច្រើនគឺជាការប៉ាន់ប្រមាណអំពី ផលប៉ះពាល់ នៃគម្រោងអភិវឌ្ឍន៍បឹងនេះ និងការបំផ្លិចបំផ្លាញតំបន់ដីសើម ដែលត្រូវបានចងក្រងឡើង ដើម្បីឱ្យរាជរដ្ឋាភិបាលបានដឹងអំពីហានិភ័យ ដែលគម្រោងនេះអាចនឹងបង្កឡើង។

របាយការណ៍នេះ មិនធ្វើការអះអាងថា អាចវាយតម្លៃបានជាក់លាក់អំពីផលប៉ះពាល់នៃគម្រោងនេះឡើយ ប៉ុន្តែអាចផ្តល់ការវាយតម្លៃអំពីគ្រោះអន្តរាយ និងហានិភ័យដែលអាចនឹងកើតឡើង និងគួរស្វែងយល់ឱ្យច្បាស់ដើម្បីបញ្ចៀសគ្រោះអន្តរាយបន្ថែមផ្សេងទៀត។ លើសពីនេះការសិក្សាវាយតម្លៃហេតុប៉ះពាល់ គឺជាទំនួលខុសត្រូវរបស់ម្ចាស់គម្រោង[២២]។ រាល់ការវាយតម្លៃការខូចខាតដល់បរិស្ថាន ដែលអាចនឹងកើតឡើង គឺជាការប៉ាន់ស្មានប៉ុណ្ណោះ ។ ដោយសារមិនមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានគ្រប់ជ្រុងជ្រោយ ផលប៉ះពាល់ទៅលើបរិស្ថាន ដែលនឹងអាចកើតមាននឹងមិនអាចធ្វើការវាយតម្លៃបានច្បាស់លាស់នោះឡើយ ហើយជាលទ្ធផល ផែនការកាត់បន្ថយហានិភ័យនានា ដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះនឹងត្រូវការការសិក្សាស្រាវជ្រាវបន្ថែមទៀត។

ជាចុងក្រោយ បើទោះជាទំហំសំណាកសម្រាប់ការស្ទង់មតិ វាយតម្លៃហេតុប៉ះពាល់សង្គម និងសិទ្ធិមនុស្សនេះ មានប្រមាណជា ៣៩% ទៅ៥២% នៃក្រុមគោលដៅ ដែលអាចតំណាងឱ្យចំនួនក្រុមទាំងអស់ក៏ដោយ ក៏គ្រួសារមួយចំនួនអាចនឹងមិនយល់ស្របទៅនឹងការរកឃើញនៃការសិក្សានេះដែរ ។

---

[២០] ឯកសារដូចខាងលើ ផ្នែកទី៦ ការវាយតម្លៃហេតុប៉ះពាល់សង្គម (ឃ) ទំព័រទី ២៨-២៩

[២១] ការស្ទង់មតិសហគមន៍ និងទិន្នន័យនៃការគូសផែនទីរបស់អង្គការសមាគមធាងត្នោត

[២២] អនុក្រឹត្យលេខ ៧២ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ១៩៩៩ មាត្រា៦

ផែនទីទី ១៖ តំបន់ដែលបានចាក់បំពេញរួចរាល់ដោយខ្សាច់ក្នុងតំបន់បឹងទំពុន ឬជើងឯក




*ខ្សាច់នៃតំបន់បឹងទំពុនដែលបានចាក់លុប (ពណ៌ក្រហម) និងតំបន់ដែលមានទឹកជាប្រចាំ(ពណ៌ខៀវ) ។*

# ៣. តំបន់ដីសើម

*វាគឺជាប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ធម្មជាតិ ជាអ្នកការពារទឹកជំនន់ ជាកន្លែងសម្រាប់រស់នៅរបស់កសិករជាច្រើនគ្រួសារ និងជាតំបន់ជីវចម្រុះសម្រាប់សត្វជាច្រើនប្រភេទ។*

បឹងទំពុន ឬជើងឯកជាតំបន់ដីសើម ជាតំបន់ដែលបណ្តុំទៅដោយបឹងបួ វាលភក់ ទន្លេ ព្រែក និងតំបន់លិចទឹកជាច្រើន ដែលសរុបមានផ្ទៃដីជាង១.៥០០ហិកតា។ ទោះបីជាតំបន់នេះមានសារៈសំខាន់ផ្នែកបរិស្ថានយ៉ាងណាក្តី ក៏តំបន់នេះមិនដែលត្រូវបានការពារដោយច្បាប់នោះទេរហូតទាល់តែផ្នែកមួយនៅទិសខាងជើង ដែលហៅថាបឹងជើងឯក ជាបឹងតែមួយគត់ត្រូវបានអាជ្ញាធរវាស់វែង និងចុះបញ្ជីនៅក្នុងឆ្នាំ ២០០៨[២៣]។ ទឹកភ្លៀង និងទឹកសម្អុយ ក្នុងរាជធានីភ្នំពេញ ប្រមាណ ៧០% ហូរចូលទៅក្នុងតំបន់ដីសើមនេះ តាមរយៈប្រឡាយសំខាន់ៗចំនួនបីៈ ប្រឡាយបឹងត្របែក ប្រឡាយស្ទឹងមានជ័យ និងប្រឡាយលូប្រាំ (សូមមើលផែនទីលេខ ២)។ ដោយសារមានទំនប់ និងផ្លូវក្រវាត់ក្រុងជាច្រើនជុំវិញរាជធានី ហើយតំបន់ដីសើមជាច្រើន មានកម្ពស់ខ្ពស់ជាងតំបន់មួយចំនួនក្នុងរាជធានីភ្នំពេញ។ ប្រឡាយចំនួនពីរខ្សែត្រូវការស្ថានីយបូមទឹកដើម្បីរំដោះទឹកភ្លៀង និងទឹកសម្អុយចេញពីប្រឡាយក្នុងរាជធានីភ្នំពេញ ចូលទៅក្នុងតំបន់ដីសើមទាំងនោះ។ ស្ថានីយបូមទឹក សម្រាប់ប្រឡាយបឹងត្របែក និងស្ទឹងមានជ័យ បានបង្ហាញថាចំនួនទឹកភ្លៀង និងទឹកសម្អុយ ដែលត្រូវបានបូមចេញពីរាជធានីភ្នំពេញ ចូលទៅក្នុងតំបន់ដីសើម មានប្រមាណពី៣៧០.០០០ ទៅ ៣៨០.០០០ ម៉ែត្រគូប ក្នុងមួយថ្ងៃ (សូមមើលឧបម្ព័ន្ធទី ៣) ។



ទឹកកខ្វក់ហូរចេញពីប្រឡាយបឹងត្របែកក្នុងរាជធានីភ្នំពេញ ចាក់ចូលតំបន់ដីសើមបឹងទំពុន ឬជើងឯក ឆ្នាំ២០២០។

[២៣] អនុក្រឹត្យលេខ ១២៤អនក្រ.បក ស្តីពីការកំណត់ផ្ទៃបឹងជើងឯក និងប្រឡាយស្ថិតនៅក្នុងខណ្ឌមានជ័យ និងខណ្ឌដង្កោ រាជធានីភ្នំពេញ និង ស្រុកតាខ្មៅ ខេត្តកណ្តាល ជាសម្បត្តិសាធារណៈរបស់រដ្ឋ ឆ្នាំ២០០៨

## ផែនទីទី ២៖ រំហូរនៃទឹកស្អុយក្នុងរាជធានីភ្នំពេញចូលទៅក្នុងបឹងទំពុន




ទឹកសម្អុយចេញពីរាជធានីភ្នំពេញ ចូលទៅក្នុងតំបន់ដីសើម ហើយចាក់ចូលទៅក្នុងទន្លេបាសាក់ បន្ទាប់ពីឆ្លងកាត់ការធ្វើប្រព្រឹត្តកម្មទឹកពីរុក្ខជាតិជាច្រើននៅក្នុងបឹង។ ត្រកួន ភ្លៅកង្កែប កញ្ឆែត កំប្លោក និងស្មៅដុះក្នុងទឹក ជួយកាត់បន្ថយល្បឿនទឹកហូរ និងបន្សុទ្ធទឹកកខ្វក់តាមធម្មជាតិ ដោយសម្លាប់នូវសារធាតុពុលជាច្រើន[២៤]។ សត្វស្លាប ថនិកសត្វ និងសត្វល្មិតជាច្រើន ក៏ត្រូវបានរកឃើញនៅក្នុងតំបន់ដីសើមនេះផងដែរ ក្រៅពីប្រភេទត្រី សត្វល្អូន និងថលជលិកសត្វជាច្រើនប្រភេទដែលនៅទីនោះ។

---

[២៤] អង្គការចៃកា ៉របាយការណ៍ស្ដីពីការត្រៀមស្ទង់មតិអំពីគម្រោងអភិវឌ្ឍន៍ប្រព័ន្ធទឹកកខ្វក់នៅក្នុងរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩

នៅក្នុងរដូវប្រាំង ទឹកហូរចេញពីតំបន់ដីសើមបឹងទំពុនឬជើងឯក ឬ ចូលទៅក្នុងទន្លេបាសាក់ ប៉ុន្តែអំឡុងពេលរដូវវស្សា ចាប់ពីខែមិថុនា ដល់ខែវិច្ឆិកា រំហូរទឹកផ្លាស់ប្តូរទិសដៅ ដោយទឹកជំនន់ពីទន្លេបាសាក់ ហូរចូលតំបន់ដីសើមបឹងទំពុន ឬជើងឯក ឬតាមរយៈស្ទឹងជ្រៅ និងស្ទឹងព្រែកត្នោត (សូមមើលផែនទីលេខ១២)។ រាជធានីភ្នំពេញ និងទីក្រុងតាខ្មៅ ត្រូវបានការពារពីការជន់លិចដោយទឹកជំនន់ ដោយសារមានតំបន់ដីសើម ដែលដើរតួនាទីជាអាងស្តុកទឹកដែលហូរពីទន្លេបាសាក់។


ដំណាំត្រកួន និងកញ្ឆែត នៅលើផ្ទៃទឹកក្នុងតំបន់ដីសើមបឹងទំពុន ឬជើងឯក ឆ្នាំ២០២០។

សហគមន៍មួយចំនួននៅក្នុងតំបន់នេះ បានលើកឡើងថា ប្រជាសហគមន៍ បានមករស់នៅក្នុងតំបន់នេះតាំងពីឆ្នាំ១៩៧០។ ប្រជាពលរដ្ឋមួយចំនួនក្នុងសហគមន៍ទាំងនោះ ប្រកបរបរដាំដំណាំលើផ្ទៃទឹករីឯប្រជាពលរដ្ឋមួយចំនួនទៀតប្រើប្រាស់ជាកន្លែងឃ្វាលសត្វ នេសាទ ចិញ្ចឹមទា ឬដាំដំណាំផ្សេងៗ នៅពេលទឹកស្រក។ សហគមន៍ជាច្រើនរស់នៅលើតំបន់ជាយមាត់បឹង រីឯសហគមន៍មួយចំនួនទៀតរស់នៅតំបន់មាត់ប្រឡាយនៃបឹង ឬនៅក្នុងតំបន់ដីសើម ដោយសាងសង់ផ្ទះមានសរសរខ្ពស់ៗ។ ប្រជាពលរដ្ឋក្រីក្រដែលងាយរងគ្រោះប្រមាណជាង ១.០០០ គ្រួសារ រស់នៅក្នុងនិងជុំវិញតំបន់នេះ ហើយពឹងផ្អែកលើតំបន់ដីសើមនេះ ដើម្បីរស់នៅ និងចិញ្ចឹមជីវិត។


បក្សីដែលចាប់ត្រីជាអាហារ កំពុងរកត្រីនៅក្នុងតំបន់ដីសើមបឹងទំពុន ឬជើងឯក ឆ្នាំ២០២០។

## ច្បាប់ និងបទបញ្ញត្តិ

### ច្បាប់អន្តរជាតិស្តីពីការគ្រប់គ្រងតំបន់ដីសើម និងទន្លេ

ប្រទេសកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិស្តីពីតំបន់ដីសើមដែលមានសារៈសំខាន់ជាអន្តរជាតិ ជាពិសេសជាជម្រកសត្វស្លាប ឬហៅថាអនុសញ្ញារ៉ាមសារ នៅខែមិថុនា ឆ្នាំ១៩៩៩។ ប្រទេសកម្ពុជាបានកំណត់នូវតំបន់ចំនួនបួនកន្លែង សម្រាប់ការពារជាតំបន់ដីសើមដែលមានសារៈសំខាន់សម្រាប់ពិភពលោក។ បើទោះបីជាប្រទេសកម្ពុជាមិនបានដាក់តំបន់ដីសើមបឹងទំពុន ឬជើងឯកជាតំបន់ការពារក៏ដោយ តំបន់នេះមានលក្ខខណ្ឌគ្រប់គ្រាន់ដែលគួរតែជាតំបន់ការពារ ជាពិសេសដោយសារអនុសញ្ញា បានអំពាវនាវដល់ភាគីទាំងអស់ សូមឱ្យទទួលស្គាល់ការអាស្រ័យគ្នាទៅវិញទៅមករវាងមនុស្ស និងតំបន់ដីសើម និងសារៈសំខាន់នៃតំបន់ដីសើមសម្រាប់វដ្តនៃការផ្តល់សារធាតុចិញ្ចឹម និងការគ្រប់គ្រងទឹកជំនន់ ។[២៥]

ប្រទេសកម្ពុជាគឺជាភាគីនៃកិច្ចព្រមព្រៀងស្តីពីសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍដោយចីរភាពនៃអាងទន្លេមេគង្គ (១៩៩៥)។ ប្រទេសកម្ពុជា រួមជាមួយប្រទេសឡាវ ថៃនិងវៀតណាម ទទួលស្គាល់ថាធនធាននៃអាងទន្លេមេគង្គមានតម្លៃធំធេងសម្រាប់ប្រទេសទាំងអស់ដែលទន្លេនេះហូរកាត់ និងប្រជាពលរដ្ឋនៃប្រទេសទាំងនោះ។[២៦] ភាគីនៃកិច្ចព្រមព្រៀងត្រូវតែការពារបរិស្ថាន និង"តុល្យភាពអេកូឡូស៊ីនៃអាងទន្លេមេគង្គ ពីការបំពុល ឬផលប៉ះពាល់អវិជ្ជមានដទៃទៀត"។[២៧] មាត្រា ៧ តម្រូវឱ្យរដ្ឋជាភាគីព្យាយាមគ្រប់យ៉ាង ដើម្បីជៀសវាងពីការធ្វើឱ្យខូចគុណភាពទឹក និងប្រព័ន្ធអេកូឡូស៊ីនៃអាងទន្លេមេគង្គ តាមរយៈការបង្ហូរកាកសំណល់ចូលក្នុងទន្លេ។[២៨] មាត្រា ៨ បានលើកឡើងពីការទទួលខុសត្រូវរបស់រដ្ឋជាភាគី ក្នុងករណីដែលមានការខូចខាត កើតចេញពីការល្មើសនឹងមាត្រា ៧ ក៏ដូចជានីតិវិធីដែលត្រូវអនុវត្តសម្រាប់ការដោះស្រាយបញ្ហានានា។[២៩] ទន្លេមេគង្គ កំពុងត្រូវបានគេធ្វើអាជីវកម្មបូមខ្សាច់ ដើម្បីយកខ្សាច់ចាក់បំពេញតំបន់ដីសើមបឹងទំពុន ឬជើងឯក។ លើសពីនេះ សារធាតុពុលជាច្រើននឹងចូលទៅក្នុងទឹកទន្លេ ប្រសិនបើផែនការកាត់បន្ថយហានិភ័យមិនត្រូវបានបង្កើតឡើងដើម្បីការពារពីគ្រោះថ្នាក់នេះ។

---

[២៥] អនុសញ្ញាស្តីពីតំបន់ដីសើមដែលមានសារៈសំខាន់ជាអន្តរជាតិ ជាពិសេសជាជំរកសត្វស្លាបព្រៃ (១៩៧១)

[២៦] កិច្ចព្រមព្រៀងស្តីពីសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍដោយចីរភាពនៃអាងទន្លេមេគង្គ (១៩៩៥) ជំពូកទី១ បុព្វកថា

[២៧] មាត្រា ៣ នៃកិច្ចព្រមព្រៀងខាងលើ

[២៨] មាត្រា ៧ នៃកិច្ចព្រមព្រៀងខាងលើ

[២៩] មាត្រា ៨ នៃកិច្ចព្រមព្រៀងខាងលើ

## ៤. ការសាងសង់គម្រោងឋានសួគ៌៖ គម្រោងអភិវឌ្ឍន៍ដែលបំផ្លាញតំបន់បឹងទំពុន ឬជើងឯក

ក្រុមហ៊ុន អាយ អិន ជី ហូលឌីង (ING Holdings) បានអភិវឌ្ឍគម្រោងទីក្រុងរណប ដែលគ្របដណ្តប់លើផ្ទៃដី ២.៥៧២ ហិកតា នៅក្នុងតំបន់បឹងទំពុន ឬជើងឯក តាំងពីឆ្នាំ ២០០៤។[៣០] កិច្ចសន្យាជួល មិនត្រូវបានបង្ហាញជាសាធារណៈឡើយ ទោះបីជាតំបន់ដីសើមបឹងទំពុន ឬជើងឯកត្រូវបានសាធារណជនប្រើប្រាស់ និងបានផ្តល់ជាប្រយោជន៍ជាសាធារណៈតាមរយៈការការពារទឹកជំនន់ និងការប្រព្រឹត្តកម្មទឹកកខ្វក់តាមធម្មជាតិ។ក្រុមហ៊ុន អាយ អិន ជី ហូលឌីងត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៥ និងចាប់ដៃគូជាមួយក្រុមហ៊ុនដូនពេញគ្រុប ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា និងក្រុមហ៊ុនខូកថែល (Cogetel) (Online)។[៣១] ទីក្រុងរណបអាយអិន ជី ស៊ីធីគឺជាគម្រោងអភិវឌ្ឍន៍ធំបំផុតនៅក្នុងប្រទេសកម្ពុជា[៣២]។ក្រោយការបូមខ្សាច់ចាក់បំពេញតំបន់ដីសើម គម្រោងអភិវឌ្ឍបង្កើតឱ្យមាននូវអចលនទ្រព្យ ដើម្បីជួលបន្តឱ្យក្រុមហ៊ុនដទៃទៀត ដោយមានការគាំទ្រទាំងស្រុងពីរាជរដ្ឋាភិបាលកម្ពុជា និងស្របតាមប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ២០៣៥។[៣៣]

គម្រោង អាយ អិន ជី ស៊ីធីតំណាក់កាលទី១ រួមមានបណ្តុំតំបន់ពាណិជ្ជកម្មជាច្រើន ដូចជាសាលារៀន អគាររដ្ឋាភិបាល ហាងសម្ភារៈសំណង់គ្រឿងបរិក្ខារ រថយន្ត សំលៀកបំពាក់ មន្ទីរពេទ្យសម្រាប់ជនជាតិជប៉ុនមណ្ឌលថែរក្សាជនចាស់ជរាជប៉ុន លំនៅឋានសម្រាប់និវត្តន៍ជនជាតិចិនសួនកំសាន្ត លំនៅឋាន និងហាងលក់ទំនិញ។[៣៤]

នៅក្នុងផែនការដែលបង្ហាញជាសាធារណៈ គម្រោងអភិវឌ្ឍន៍មិនបានរួមបញ្ចូលគម្រោងលំនៅឋានសម្រាប់ជនក្រីក្រ ឬអ្នកមានចំណូលទាបនោះទេ ប៉ុន្តែបែជាផ្តោតទៅលើទីផ្សារជនបរទេស ដែលជាអតិថិជនគោលដៅចម្បង ដូចជាជនជាតិជប៉ុន និងចិន។[៣៥] អតិថិជនលំដាប់ទីពីរ គឺជាអ្នកដែលមានចំណូលពីមធ្យមទៅខ្ពស់។ លំនៅឋានប្រមាណ ៣០០.០០០ ខ្នង នឹងត្រូវបានសាងសង់តាមរយៈគម្រោងអភិវឌ្ឍ។[៣៦]

បឹងជើងឯក ដែលត្រូវបានវាស់វែងព្រំប្រទល់តាមច្បាប់នៅក្នុងតំបន់ដីសើមត្រូវបានការពារដោយច្បាប់ ក្រោយពីបានជួលតំបន់ដីសើមនេះឱ្យទៅក្រុមហ៊ុន អាយ អិន ជី ស៊ីធី[៣៧] ។ ផ្ទុយនឹងទំហំដីអប្បបរមាដែលនៅសល់ចំនួន១.៥០០ ហិកតា បឹងទំពុន ឬជើងឯក ត្រូវបានវាស់វែងថាជាដីសាធារណៈរបស់រដ្ឋ។

ការវាស់វែងព្រំប្រទល់បឹង ចោទជាសំណួរអំពីភាពស្របច្បាប់នៃកិច្ចសន្យាជួលដីដំបូងរបស់ក្រុមហ៊ុន អាយ អិន ជី ស៊ីធី ទៅលើតំបន់ដីសើមជាសំណួរសួរថាហេតុអ្វីដីមានតែចំនួន ៥២០ហិកតា ត្រូវបានវាស់វែងជាដីសាធារណៈរបស់រដ្ឋដែលមានផ្ទៃដីសរុបចំនួន១.៥០០ហិកតា ជាតំបន់ទឹកអចិន្ត្រៃយ៍។ រហូតមកដល់ឆ្នាំ២០១៧ បឹងជើងឯកត្រូវបានរក្សាទុក និងអាចជួយការពារពីទឹកជំនន់ ក៏ដូចជាជួយប្រព្រឹត្តកម្មទឹកកខ្វក់ពីរាជធានីភ្នំពេញ ដោយសារទំហំមួយសមល្មម នៃដីក្នុងតំបន់ដីសើមមិនត្រូវបានអភិវឌ្ឍក្នុងគម្រោងក្រុមហ៊ុន អាយ អិន ជី ស៊ីធី[៣៨]។ យ៉ាងតិចផ្ទៃបឹងទំពុន ឬជើងឯកចំនួន ៤៨០ហិកតា គួរតែត្រូវបានអភិរក្ស ដើម្បីការពារពីទឹកជំនន់និងបញ្ហាទឹកកខ្វក់ ដោយយោងតាមការសិក្សាមួយដែលមានឈ្មោះថា ការពង្រីក និងការផ្លាស់ប្តូរនៃរាជធានីភ្នំពេញ(Livre Phnom Penh extensions et mutations) ដែលជាការសិក្សាមួយធ្វើឡើងដោយមានកិច្ចសហប្រតិបត្តិការជាមួយសាលារាជធានីភ្នំពេញ[៣៩]។ ប៉ុន្តែនៅក្នុងអំឡុង ២ឆ្នាំចុងក្រោយនេះ ជាង ៧០% នៃបឹងជើងឯកត្រូវបានជួលទៅឱ្យក្រុមហ៊ុនឯកជន ឬបុគ្គលឯកជន រួមមានក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន អ័រគីដេវីឡា និងក្រុមហ៊ុនជីបម៉ុង។ តំបន់ដីសើមបឹងទំពុន ឬជើងឯកអាចនឹងត្រូវបានបំផ្លាញទាំងស្រុង ដោយជាង ៩០% នៃដីទំហំ ១.៥០០ ហិកតាត្រូវបានជួលឱ្យអ្នកអភិវឌ្ឍអចលនវត្ថុ។

---

[៣០] គេហទំព័រក្រុមហ៊ុនអាយ អិន ជី៖ http://www.ing-holdings.com/overview; http://www.ing-holdings.com/projectpdfEng.

[៣១] គេហទំព័រក្រុមហ៊ុនអាយ អិន ជី៖ http://www.ing-holdings.com/profile#

[៣២] គេហទំព័រក្រុមហ៊ុនអាយ អិន ជី៖ http://www.ing-holdings.com/overproject

[៣៣] ដូចខាងលើ

[៣៤] ដូចខាងលើ

[៣៥] ដូចខាងលើ

[៣៦] ចៃកា (២០១៦) ការសិក្សាអំពីការធ្វើឱ្យប្រសើរឡើងនូវគម្រោងបង្ហូរទឹក និងទឹកកខ្វក់នៅក្នុងតំបន់ទីប្រជុំជនក្នុងរាជធានីភ្នំពេញ របាយការណ៍ចុងក្រោយ (ភាគពីរ)

[៣៧] អនុក្រឹត្យលេខ ១២៤អនក្រ.បក ស្តីពីការកំណត់ផ្ទៃបឹងជើងឯក និងប្រឡាយស្ថិតនៅក្នុងខណ្ឌមានជ័យ និងខណ្ឌដង្កោ រាជធានីភ្នំពេញ និង ស្រុកតាខ្មៅ ខេត្តកណ្តាល ជាសម្បត្តិសាធារណៈរបស់រដ្ឋ ឆ្នាំ២០០៨

[៣៨] សាលាក្រុងប៉ារីស និងសាលារាជធានីភ្នំពេញ៖ ការពង្រីក និងការផ្លាស់ប្តូរនៃរាជធានីភ្នំពេញ (ឆ្នាំ២០១៨) ទំព័រទី ៤០

[៣៩] ដូចខាងលើ

## ច្បាប់ និងបទបញ្ញត្តិ

### ពីប្រយោជន៍សាធារណៈ ទៅកាន់គណនីធនាគាររបស់បុគ្គលឯកជន

យោងតាមច្បាប់ភូមិបាលឆ្នាំ២០០១ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនអាចជាកម្មវត្ថុទិញលក់នោះទេ ប៉ុន្តែអាចត្រូវបានគេធ្វើអនុបយោគឱ្យទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នៅពេលដែលវាបាត់បង់ ប្រយោជន៍សាធារណៈ[៤០] ។ ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋអាចជាកម្មវត្ថុនៃការទិញលក់ ជួល និងអំណោយដោយអនុក្រឹត្យ។[៤១]

ព្រះរាជក្រឹត្យលេខ៣៣៩ បានកំណត់នូវបទបញ្ញត្តិ និងនីតិវិធីស្តីពីការធ្វើអនុប្រយោគទ្រព្យសម្បត្តិ សាធារណៈរបស់រដ្ឋ។ ដើម្បីធ្វើចំណាត់ថ្នាក់ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

១. ទ្រព្យសម្បត្តិនោះមិនមានផលប្រយោជន៍ដល់សាធារណៈ

២. ទ្រព្យសម្បត្តិនោះបានបាត់បង់មុខងារផលប្រយោជន៍សាធារណៈ

៣. ទ្រព្យសម្បត្តិនោះមិនអាចប្រើប្រាស់បានជាសាធារណៈ។[៤២]

យោងតាមអនុក្រឹត្យលេខ ១២៩ ដែលបានកំណត់គោលការណ៍ យុទ្ធសាស្ត្រ និងនីតិវិធីសម្រាប់ការរៀបចំ និងចាត់ចែងទ្រព្យសម្បត្តិរបស់រដ្ឋអាជ្ញាធរដែលមានតួនាទីតាមដាន និងធ្វើរបាយការណ៍ស្តីពីស្ថានភាពនៃការប្រើប្រាស់ជាសាធារណៈនៃទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ គឺជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ[៤៣] ។

ដោយផ្អែកលើលក្ខខណ្ឌជាច្រើន ដែលត្រូវតែបំពេញ ដើម្បីចាត់ថ្នាក់ឡើងវិញនូវទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋឱ្យទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ការបាត់បង់នូវ "ការប្រើប្រាស់ជាសាធារណៈ" នៅក្នុងតំបន់ដីសើមគឺពិបាកនឹងកំណត់។ តំបន់ដីសើមជាច្រើន នៅតែបន្តផ្តល់ប្រយោជន៍ដល់សាធារណជន តាមរយៈការការពារទឹកជំនន់និងការប្រព្រឹត្តកម្មទឹកកខ្វក់តាមបែបធម្មជាតិ។

ភាពច្បាស់លាស់ទៅនឹងការចាត់ថ្នាក់លើដីធ្លីដោយរាជរដ្ឋាភិបាល អាចកម្រិតលើការរំលោភបំពានសិទ្ធិជាច្រើន ដោយផ្តល់នូវតម្លាភាព សន្តិសុខ និងភាពដែលអាចដឹងទុកមុនបានសម្រាប់ពលរដ្ឋ និងអ្នកប្រើប្រាស់ដី។ ដោយសុវត្ថិភាពលើភាពជាម្ចាស់កម្មសិទ្ធិគឺជាចំនុចចម្បងនៃសិទ្ធិទទួលបានលំនៅឋានសមរម្យ[៤៤] ការផ្តល់នូវភាពច្បាស់លាស់នៃស្ថានភាពច្បាប់ទៅលើដីធ្លីនឹងធ្វើឱ្យកម្ពុជាបំពេញបាននូវកាតព្វកិច្ចជាអន្តរជាតិ ក្នុងការគោរពសិទ្ធិ[៤៥] ។ បច្ចុប្បន្ននេះ អ្នកប្រើប្រាស់តំបន់ដីសើមជាច្រើន បានលើកឡើងថាការភ័យខ្លាចពីការបណ្តេញចេញ នៅខណៈដែលពួកគេមិនមានប្លង់កម្មសិទ្ធិដីធ្លី នៅកន្លែងដែលពួកគេកំពុងរស់នៅ ប៉ុន្តែមិនទាន់បានទទួលបានការប្រឹក្សាយោបល់ពីអាជ្ញាធរ អំពីស្ថានភាពនៃភាពជាម្ចាស់កម្មសិទ្ធិរបស់ពួកគេ។

---

[៤០] មាត្រា ១៦ នៃច្បាប់ភូមិបាល ឆ្នាំ ២០០១

[៤១] ដូចខាងលើ

[៤២] មាត្រា ១ ព្រះរាជក្រឹត្យលេខ ៣៣៩ ស្តីពីគោលការណ៍ និងបទបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ឆ្នាំ ២០០៦

[៤៣] មាត្រា ១ និងជំពូកទី ៦ នៃអនុក្រឹត្យស្តីពី វិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គល

សាធារណៈ (អនុក្រឹត្យលេខ ១២៩ ឆ្នាំ ២០០៦)

[៤៤] ដោយយោងតាមការិយាល័យអង្គការសហប្រជាជាតិនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ការទទួលបានលំនៅឋានសមរម្យ គឺ ១) ទទួលបានសុវត្ថិភាពផ្លូវច្បាប់លើភាពជាម្ចាស់កម្មសិទ្ធិ ២) ទទួលបានសេវាសាធារណៈ សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធ ៣) តម្លៃសមរម្យ ៥) អាចទៅដល់ ៦) ទីតាំងដែលអាចងាយស្រួលទទួលបានសេវាផ្សេងៗនៃការទទួលបានលំនៅឋានសមរម្យ ជាពិសេសឱកាសរកការងារធ្វើ និង ៧) ភាពគ្រប់គ្រាន់ផ្នែកវប្បធម៌។ ការិយាល័យអង្គការសហប្រជាជាតិនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស សលាកប័ត្រព័ត៌មានលេខ ២១ សិទ្ធិក្នុងការទទួលបានលំនៅឋានសមរម្យ ខែវិច្ឆិកា ឆ្នាំ២០០៩ Fact Sheet No. 21/Rev.1.

[៤៥] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (១៩៦៦) មាត្រា ១១

## តារាងលេខ ១៖ ក្រុមហ៊ុនពាក់ព័ន្ធនឹងគម្រោងទីក្រុងរណប អាយ អិន ជី ស៊ីធី ឬគម្រោងអភិវឌ្ឍផ្សេងទៀត

| ក្រុមហ៊ុន | ការពិពណ៌នាគម្រោង |
|---|---|
| អាយ អិន ជី ហូលឌីង (ING Holdings) | លំនៅឋាន រោងចក្រ គមនាគមន៍ ហេដ្ឋារចនាសម្ព័ន្ធ |
| អ៊ីអន ម៉ល (AEON Mall) ទី ៣* | ផ្សារលក់ទំនិញ (១៧,៤ ហិកតា)[៤៦] |
| បុរី ប៉េងហួត | វីឡា (+១.០០០ល្វែង) |
| បុរី ជីបម៉ុងឡៀន | វីឡា (៦.៤៥០ ល្វែង)[៤៧] |
| ជីបម៉ុង គ្រុប | វីឡា ឬផ្សារទំនើប |
| សាលាអន្តរជាតិភ្នំពេញ (ISPP) | សាលាឯកជនអន្តរជាតិ |
| លីងណាន ហ្គាឌិន (Lingnan Garden)* | សំណង់ខុនដូរ |
| ស្តារ អូតូ ខេមបូឌា (Star Auto Cambodia Mercedes – Benz) | ហាងលក់រថយន្ត |
| អ៊័រគីដេវីឡា | មិនទាន់បញ្ជាក់ អាចនឹងជាលំនៅឋាន |
| អឺបេន វីលេក (Urban Village)* | អគារខុនដូរ (៤.០០០ យូនីត[៤៨] ) |
| អ អេន អេហ្វ ស៊ីធី (R & F City)* | អគារខុនដូរ (៣.៨៥០ យូនីត[៤៩] ) |
| វើសែល ស្វែរ (Versailles Square)* | អគាររអាជាតមិន |
| ភីអេក អ៊ីកូ ម៉ល (PH Eco Mall) | ផ្សារទំនើប |
| ម៉ារីថាម គ្រុប (Maritime Group) | អគារការិយាល័យ ឬអាជាតមិន |

** ក្រុមហ៊ុនអន្តរជាតិ ឬក្រុមហ៊ុនមេ អន្តរជាតិ*

### រោងចក្រប្រព្រឹត្តកម្មទឹកកខ្វក់របស់អង្គការ ចៃកា (JICA)

ទោះជាមិនមានក្រុមហ៊ុន ឬគម្រោងណាមួយ មានគោលដៅបំផ្លាញតំបន់ដីសើមក៏ដោយ ក៏ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុននឹងសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកកខ្វក់មួយ នៅលើដីមួយផ្នែកក្នុងតំបន់ដីសើមនេះ ក្រោមការគ្រប់គ្រងរបស់សាលារាជធានីភ្នំពេញ។ រោងចក្រនេះនឹងធ្វើប្រព្រឹត្តកម្មទឹកកខ្វក់ចំនួន ៥.០០០ ម៉ែត្រគូប ក្នុងមួយថ្ងៃ[៥០] និងមានដើមទុនដំបូងចំនួន ២៦លានដុល្លារអាមេរិក បន្ថែមពីលើតម្លៃនៃការជួសជុល ថែទាំ បណ្តុះបណ្តាលបុគ្គលិកប្រាក់បៀវត្សរ៍របស់បុគ្គលិក និងការពង្រីកទីតាំង ប្រសិនបើចាំបាច់ដែលចំណាយទាំងនេះនឹងត្រូវធ្លាក់ក្នុងបន្ទុករបស់រាជរដ្ឋាភិបាលកម្ពុជា ឬសាលារាជធានីភ្នំពេញ នាថ្ងៃអនាគត។

ទឹកកខ្វក់ និងទឹកភ្លៀង ហូរចូលទៅក្នុងតំបន់ដីសើម មានចំនួនប្រមាណ៣៧.០០០ ម៉ែត្រគូបក្នុងមួយថ្ងៃ ដែលនេះអាចជាចំនួនអប្បបរមា។ដូចនេះ រោងចក្រប្រព្រឹត្តកម្មទឹកកខ្វក់របស់អង្គការចៃកាមានសមត្ថភាពធ្វើប្រព្រឹត្តកម្មទឹកកខ្វក់មិនដល់ទៅ ២%ផង នៃចំនួនទឹកកខ្វក់និងទឹកភ្លៀងសរុបដែលហូរចូលតំបន់ដីសើមបឹងទំពុន/ជើងឯក។ នេះបង្ហាញឱ្យឃើញថារោងចក្រប្រព្រឹត្តកម្មនេះនឹងមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការចម្រោះទឹកនិងសាកសមនឹងតម្លៃ ប្រសិនជាមិនរក្សាទុកបឹងជើងឯកនោះទេ។ ប្រសិនបើមិនមានផ្ទៃបឹងចំនួន ៥២០ ហិកតានោះទេ ទន្លេបាសាក់ ទន្លេដទៃទៀតនិងរាជធានីភ្នំពេញ អាចនឹងជួបប្រទះការបំពុលដោយសារទឹកកខ្វក់ដែលមិនបានធ្វើប្រព្រឹត្តកម្មចំនួន ៣៦៥.០០០ ម៉ែត្រគូប ជារៀងរាល់ថ្ងៃ។

អង្គការចៃកាបានចេញផ្សាយ របាយការណ៍វាយតម្លៃ ហេតុប៉ះពាល់សម្រាប់គម្រោងរោងចក្រប្រព្រឹត្តកម្មទឹករបស់ខ្លួន ដែលមានចំណងជើងថា "របាយការណ៍ ស្តីពីការត្រៀមស្ទង់មតិអំពីគម្រោងអភិវឌ្ឍន៍ប្រព័ន្ធទឹកកខ្វក់ នៅក្នុងរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា"[៥១]។ របាយការណ៍នេះ មិនបានលើកឡើងនូវចំនួននៃទឹកកខ្វក់សរុប ដែលហូរចូលក្នុងប្រព័ន្ធតំបន់ដីសើមមិនបានពិភាក្សាទៅលើផលប៉ះពាល់សំខាន់ៗ នៃការបាត់បង់តំបន់ដីសើមដោយសារគម្រោងអភិវឌ្ឍន៍ទីក្រុងរណប អាយ អិន ជី ស៊ីធី និងគម្រោងអភិវឌ្ឍន៍ផ្សេងទៀត មិនបានធ្វើការប្រឹក្សាយោបល់ឱ្យបានត្រឹមត្រូវជាមួយអង្គការមិនមែនរដ្ឋាភិបាលនានា ហើយបានលើកឡើងថាសមភាពយេនឌ័រលែងជាបញ្ហាធ្ងន់ធ្ងរនៅកម្ពុជាទៀតទេ។[៥២] រោងចក្រប្រព្រឹត្តកម្មទឹកកខ្វក់របស់អង្គការចៃកា នឹងមិនអាចធ្វើប្រព្រឹត្តកម្មទឹក ដែលហូរចូលឱ្យមានប្រសិទ្ធភាពនោះទេ និងអាចត្រូវបានក្រុមហ៊ុន និងអ្នកគាំទ្រយកធ្វើជាលេសសម្រាប់ការបំផ្លិចបំផ្លាញតំបន់ដីសើមទាំងនេះ។

[៤៦]គេហទំព័រអ៊ី អន ម៉ល៖ https://www.aeonmall.com/en/business/list.html

[៤៧] សាលាក្រុងប៉ារីស និងសាលារាជធានីភ្នំពេញ (ឆ្នាំ២០១៨)៖ ការសិក្សាអំពីការពង្រីក និងការផ្លាស់ប្តូរនៃរាជធានីភ្នំពេញ ទំព័រទី ៨៣

[៤៨] គេហទំព័រក្រុមហ៊ុន អឺបេន វីលេជ៖ http://villagephnompenh.com/

[៤៩] សាលាក្រុងប៉ារីស និងសាលារាជធានីភ្នំពេញ (ឆ្នាំ២០១៨)៖ ការសិក្សាអំពីការពង្រីក និងការផ្លាស់ប្តូរនៃរាជធានីភ្នំពេញ ទំព័រទី ៨៣

[៥០] កិច្ចសម្ភាសជាមួយចៃកា ឆ្នាំ២០១៩

[៥១] អង្គការចៃកា "របាយការណ៍ស្តីពីការត្រៀមស្ទង់មតិអំពីគម្រោងអភិវឌ្ឍន៍ប្រព័ន្ធទឹកកខ្វក់នៅក្នុងរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា" ២០១៩

[៥២] អង្គការចៃកា "របាយការណ៍ស្តីពីការត្រៀមស្ទង់មតិអំពីគម្រោងអភិវឌ្ឍន៍ប្រព័ន្ធទឹកកខ្វក់នៅក្នុងរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា" ២០១៩ សូមមើលទំព័រទី ១ ដល់ទី ៦៥ ទាក់ទងនឹងសមភាពយេនឌ័រ

# ពេលវេលានៃការបាត់បង់ ផ្ទៃបឹងទំពុន ឬបឹងជើងឯក



# ផែនទីទី ៣៖ ការកំណត់ផ្ទៃបឹងទំពុន ឬជើងឯកត្រឹម ៥២០ ហិកតាដើម្បីរក្សាទុកក្នុងឆ្នាំ២០០៨




តំបន់ដីសើមបឹងទំពុន ឬជើងឯក ជាតំបន់ធម្មជាតិមានទំហំ ១៥០០-២៥០០ហិកតា

(គ្មានការកំណត់ព្រំប្រទល់តាមផ្លូវច្បាប់)

បឹងជើងឯក (២០០៨) មានទំហំ ៥២០ហិកតា

ជាធម្មតាតំបន់ដីបឹងទំពុន ឬជើងឯកមានទំហំសរុបប្រហែល ១៥០០ ទៅ ២៥០០ ហិកតានៅប៉ែកខាងត្បូងនៃរាជធានីភ្នំពេញ។ ដោយមិនទាន់មានការពន្យល់ជាផ្លូវការណាមួយថា ហេតុអ្វីបានជាផ្ទៃបឹងទាំងមូលមិនត្រូវបានការពារ និងអភិរក្សទាំងអស់ក្នុងឆ្នាំ២០០៨។ តាមច្បាប់ភូមិបាល ឆ្នាំ២០០១ ទ្រព្យសម្បត្តិណាដែលមានប្រភពពីធម្មជាតិ ដូចជាព្រៃឈើ ផ្លូវទឹក បឹងធម្មជាតិ ច្រាំងទន្លេ និងសមុទ្រ ដែលនាវាអាចអណ្តែតបាន ឬទ្រព្យសម្បត្តិដែលត្រូវបានបង្កើតមានជាសភាពសម្រាប់ការប្រើប្រាស់ជាសាធារណៈដូចជា ផ្លូវថ្នល់ ផ្លូវរទេះគោ សួនច្បារ និងសួនសាធារណៈ និងដីបម្រុងទុកជាដើម ។[៩៣]

ផ្ទៃដីបឹងស្របច្បាប់ត្រូវបានកំណត់សម្រាប់បឹងជើងឯកដោយអនុក្រឹត្យលេខ ១២៤ ក្នុងឆ្នាំ ២០០៨។ ទោះបីដីសើមត្រូវបានគេប៉ាន់ស្មានថាមានទំហំជិត ២,៨៥០ ហិកតាមុនឆ្នាំ ២០០៨ ក៏ដោយ បឹងនេះត្រូវបានកំណត់ថាមានតែ ៥២០ ហិកតាប៉ុណ្ណោះ។

---

[៩៣] មាត្រ ១៥ នៃច្បាប់ភូមិបាលឆ្នាំ២០០១

# ផែនទីទី ៤៖ ការកែសម្រួលផ្ទៃបឹងទំពុន ឬជើងឯកលើកដំបូងក្នុងឆ្នាំ២០១២




## ឆ្នាំ ២០១២ ទំហំផ្ទៃបឹងនៅសល់ ៥០៣ ហិកតា

នៅខែកុម្ភៈឆ្នាំ ២០១២ ផ្ទៃបឹងត្រូវបានកែសម្រួល។ ផ្ទៃបឹង ១៧ ហិកតាត្រូវបានធ្វើកាត់ចេញ តាមរយៈអនុក្រឹត្យលេខ ២៦។ មិនមានការបញ្ជាក់ច្បាស់នៅក្នុងអនុក្រឹត្យថាទីតាំងនេះត្រូវបានជួលឱ្យក្រុមហ៊ុនណាមួយធ្វើនោះទេ ប៉ុន្តែបច្ចុប្បន្នយើងឃើញក្រុមហ៊ុនជីប ម៉ុង កំពុងសាងសង់នៅទីនោះ។

# ផែនទីទី ៥៖ ការកែសម្រួលផ្ទៃបឹងទំពុន ឬជើងឯកលើកទី២ ក្នុងឆ្នាំ២០១៧




ឆ្នាំ ២០១៧ ទំហំផ្ទៃបឹងនៅសល់ ៤៥៦ ហិកតា

នៅខែឧសភាឆ្នាំ ២០១៧ ផ្ទៃបឹងទំហំ ៤៧ ហិកតាត្រូវបានកាត់ និងផ្តល់ទៅឱ្យប្រជាពលរដ្ឋ នៅភូមិខ្វា តាមរយៈអនុក្រឹត្យលេខ ៧០ ។ ទោះយ៉ាងណានៅពេលអ្នកស្រាវជ្រាវព្យាយាមទាក់ទងសាកសួរប្រជាពលរដ្ឋរស់នៅតំបន់នោះ អ្នកឆ្លើយសំណួរបាននិយាយថាពួកគេមិនបានដឹងអំពីការផ្តល់ដីណាមួយដល់ប្រជាពលរដ្ឋនៅភូមិខ្វានោះទេ។

## ផែនទីទី ៦៖ ការកែសម្រួលផ្ទៃបឹងទំពុន ឬជើងឯកលើកទី៣ ក្នុងឆ្នាំ២០១៨




### ខែមករា ឆ្នាំ២០១៨ ទំហំផ្ទៃបឹងនៅសល់ ៤២៦ ហិកតា

នៅឆ្នាំ ២០១៨ ផ្ទៃបឹងត្រូវបានកែសម្រួលម្តងទៀត និងផ្តល់ឱ្យក្រុមផ្សេងៗគ្នាចំនួន ៤ លើក។ ទីមួយ តាមរយៈអនុក្រឹត្យលេខ ៥ ក្នុងខែមករា ផ្ទៃបឹងចំនួន ៣០ ហិកតាត្រូវបានប្រគល់ទៅឱ្យក្រុមហ៊ុន អាយ អិន ជី ហូលឌីង ជាការដោះដូរដីរបស់ក្រុមហ៊ុនចំនួន ១០ ហិកតាដែលក្រុមហ៊ុនបានផ្តល់ទៅក្រសួងមហាផ្ទៃ។

# ផែនទីទី ៧៖ ការកែសម្រួលផ្ទៃបឹងទំពុន ឬជើងឯកលើកទី៤ ក្នុងឆ្នាំ២០១៧




ខែកុម្ភៈឆ្នាំ ២០១៨ ទំហំផ្ទៃបឹងនៅសល់ ៣៧៩ ហិកតា

នៅខែកុម្ភៈឆ្នាំ ២០១៨ តាមរយៈអនុក្រឹត្យលេខ ១២ ផ្ទៃដីជាង ៤៧ ហិកតាត្រូវបានកាត់ចេញ និងប្រគល់ឱ្យក្រុមហ៊ុនអ័រគីដេវីឡាចំនួនជាង ៣៧ ហិកតា និងបុគ្គលឯកជនជិត ១០ ហិកតា។

# ផែនទីទី ៨៖ ការកែសម្រួលផ្ទៃបឹងទំពុន ឬជើងឯកលើកទី៥ ក្នុងឆ្នាំ២០១៨




**ខែវិច្ឆិកាឆ្នាំ ២០១៨ ទំហំផ្ទៃបឹងនៅសល់ ១៨៩ ហិកតា**

ផ្ទៃបឹងចំនួន ១៩០ហិកតាបន្ថែមទៀតត្រូវបានកាត់ និងផ្តល់ឱ្យក្រុមហ៊ុនអាយអិនជីហូលឌីងតាមរយៈអនុក្រឹត្យលេខ ១៤៨ សម្រាប់ការអភិវឌ្ឍ។ ក៏ប៉ុន្តែថ្មីៗនេះ ដីនេះត្រូវបានដកហូតវិញ និងប្រគល់ឱ្យបុគ្គលផ្សេងទៀតសម្រាប់ធ្វើការអភិវឌ្ឍ[៥៤]។

[៥៤] ហ្វេសប៊ុក, ឆ្នាំ២០១៩៖ http://m.en.freshnewsasia.com/index.php/en/localnews/14701-2019-07-22-06-03-39.html

## ផែនទីទី ៩៖ ការកែសម្រួលផ្ទៃបឹងទំពុន ឬជើងឯកលើកទី៦ ក្នុងឆ្នាំ២០១៨




### ខែធ្នូ ឆ្នាំ២០១៨ ទំហំផ្ទៃបឹងនៅសល់ ១០៧ ហិកតា

ទីបំផុតនៅខែធ្នូឆ្នាំ ២០១៨ អនុក្រឹត្យលេខ ១៦៨ បានកាត់ផ្ទៃបឹងជិត២០ ហិកតា បន្ថែមទៀត និងផ្តល់ជូនសាលារាជធានីភ្នំពេញសម្រាប់សាងសង់ស្ថានីយប្រព្រឹត្តកម្មទឹកកង្វក់ដែលកំពុងត្រូវបានសាងសង់ដោយមានមូលនិធិគាំទ្រនិងជំនួយបច្ចេកទេសពីចៃកា។ តាមរយៈអនុក្រឹត្យលេខ ១៤៨ បានបង្ហាញក្នុងមាត្រា ៣ ថា ផ្ទៃបឹងដែលនៅសេសសល់មានចំនួន ១០៧ ហិកតាប៉ុណ្ណោះ។ មានន័យថាផ្ទៃបឹងប្រមាណជិត ៨០ភាគរយត្រូវបានកាត់ និងប្រគល់ដល់ក្រុមផ្សេងៗ ចាប់តាំងពីការបោះបង្គោលផ្លូវការក្នុងឆ្នាំ ២០០៨ ។

ចាប់តាំងពីឆ្នាំ២០០៨ នៅពេលដែលបឹងត្រូវបានគេវាស់វែងព្រំប្រទល់ត្រឹម ៥២០ ហិកតា ទំហំបឹងត្រូវបានកាត់បន្ថយអស់ប្រមាណ ៤១៣ ហិកតា។ នៅក្នុងរបាយការណ៍មួយ ដែលត្រូវបានចុះហត្ថលេខាដោយអភិបាលសាលារាជធានីភ្នំពេញ លោក ឃួង ស្រេង វាបានបង្ហាញថា បឹងជើងឯកត្រូវតែរក្សាទុកយ៉ាងតិច ៤៨០ ហិកតា ដើម្បីជៀសវាងពីហានិភ័យ នៃផលវិបាកផ្នែកបរិស្ថានធ្ងន់ធ្ងរ[៥៩]។ បច្ចុប្បន្ននេះ មានតែ ១០៧ ហិកតា ប៉ុណ្ណោះនៃផ្ទៃបឹងអាចនឹងត្រូវបានរក្សាទុក ។

---

[៥៩] សាលាក្រុងប៉ារីស និងសាលារាជធានីភ្នំពេញ ការសិក្សាអំពីការពង្រីក និងការផ្លាស់ប្តូរនៃរាជធានីភ្នំពេញ (ឆ្នាំ២០១៨) ទំព័រទី ៤០

## ផែនទីទី ១០៖ ផ្ទៃបឹងធម្មជាតិ និងផ្ទៃបឹងទំពុន ឬជើងឯកដែលនៅសល់ក្រោមកាការពារដោយច្បាប់បច្ចុប្បន្ន




តំបន់ដីសើម៖ *តំបន់ដីសើម(ក្រហមស្រាល) ឥលូវត្រូវបានកាត់បន្ថយពីជាង១.៥០០ ហិកតា មកត្រឹមតែ ១០៧ ហិកតា (ខៀវ)*

# ៥. ការរកឃើញសំខាន់ៗ



## សិទ្ធិមនុស្ស និងផលប៉ះពាល់សង្គម

"វាពិបាកនៅពេលដែលគេចាក់ដីលុបបឹង ហើយខ្ញុំមិនដឹងថានឹងប្រកបរបរអ្វីប្រចាំថ្ងៃនោះទេ"

កសិករនៅក្នុងតំបន់បឹងទំពុន

ប្រជាពលរដ្ឋប្រមាណមួយពាន់គ្រួសារ អាចនឹងត្រូវទទួលរងផលប៉ះពាល់ដោយផ្ទាល់ ឬកំពុងទទួលរងផលប៉ះពាល់ ដោយគម្រោងទីក្រុងរណប អាយ អិន ជីស៊ីធី ឬគម្រោងដទៃទៀតដែលកំពុងដំណើរការនៅក្នុងតំបន់ដីសើមបឹងទំពុន ឬជើងឯក។ កម្ពុជាបានផ្ដល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិជាច្រើន ដែលធានាថាសិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជាត្រូវតែ គោរព ការពារ និងបំពេញដោយរាជរដ្ឋាភិបាលកម្ពុជា[៥៦]។ ផលប៉ះពាល់ខាងក្រោមនេះបង្ហាញពីបញ្ហាគួរឱ្យកត់សម្គាល់មួយចំនួន ដែលនៅតែបន្តកើតមានឡើងនៅក្នុងការការពារ និងបំពេញនូវសិទ្ធិរបស់អ្នកប្រើប្រាស់តំបន់ដីសើម។ ប្រជាពលរដ្ឋជាច្រើនគ្រួសារ ដែលកំពុងរស់នៅក្នុងតំបន់ដីសើមគឺជាគ្រួសារដែលងាយរងគ្រោះ ហើយអាចនឹងទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារកម្រិតនៃការអប់រំទាប កង្វះខាតការគាំទ្រផ្នែកសន្តិសុខសង្គម ការលម្អៀងផ្អែកលើយេនឌ័រ និងការជំពាក់បំណុល។ ភាគច្រើននៃគ្រួសារទាំងនោះមិនមានប័ណ្ណកម្មសិទ្ធិដីធ្លីនោះទេ ដែលធ្វើឱ្យភាពជាម្ចាស់កម្មសិទ្ធិលើដីធ្លីរបស់អ្នកទាំងនោះមិនមានសុវត្ថិភាព និងងាយរងគ្រោះដោយការបណ្ដេញចេញ។ គ្រួសារដែលអាស្រ័យផលលើបឹងដូចជា ដាំដំណាំលើទឹក នេសាទ និងការប្រមូលផលខ្យងនឹងត្រូវបាត់បង់ប្រភពចំណូល ដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅប្រចាំថ្ងៃ ដោយសារការលុបបឹង។ ការពិគ្រោះយោបល់ជាមុន មិនត្រូវបានធ្វើឡើងជាមួយក្រុមគ្រួសារទាំងនោះទេ ដែលអ្នកទាំងនោះ មិនបានដឹងថាអ្វីជាការអភិវឌ្ឍសម្រាប់ពួកគេ និងក្រុមគ្រួសាររបស់ពួកគេនោះទេ។ ជាចុងក្រោយ ទឹកជំនន់នឹងបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ក្រុមប្រជាពលរដ្ឋដែលរស់នៅតាមបណ្ដោយផ្លូវទឹកចេញពីបឹង និងក្នុងតំបន់ដែលមិនមានប្រព័ន្ធបង្ហូរទឹក និងការពារទឹកជំនន់ ។

វាអាចនឹងមានផលប៉ះពាល់ធ្ងន់ធ្ងរលើគុណភាពនៃជីវិតរបស់ពលរដ្ឋប្រមាណពី ១ ទៅ ២ លាននាក់ ដែលរស់នៅក្នុងរាជធានីភ្នំពេញ ក្រុងតាខ្មៅ និងតាមបណ្ដោយច្រាំងទន្លេមេគង្គ និងទន្លេបាសាក់ ។

[៥៦] កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (១៩៦៦) អនុសញ្ញាអន្តរជាតិស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (១៩៦៩) អនុសញ្ញាពាក់ព័ន្ធនឹងឋានៈនៃជនភៀសខ្លួន (១៩៥១) អនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (១៩៧៩) អនុសញ្ញាស្ដីពីសិទ្ធិកុមារ (១៩៨៩) អនុសញ្ញាស្ដីពីសិទ្ធិជនពិការ (២០០៨)

ប្រជាពលរដ្ឋទាំងនេះ អាចនឹងត្រូវរងគ្រោះដោយទឹកជំនន់ ការបំពុលទឹក ការបំផ្លាញជម្រកសត្វ និងការបាត់បង់ជីវភាពរស់នៅរបស់ពួកគេ។ ការសិក្សានេះ មិនមានលទ្ធភាពធ្វើការស្រាវជ្រាវគ្រប់ជ្រុងជ្រោយទៅលើផលប៉ះពាល់នៃគម្រោងទីក្រុងរណប អាយ អិន ជី ស៊ីធី និងគម្រោងអភិវឌ្ឍដទៃទៀតនោះទេ ប៉ុន្តែការសិក្សានេះនឹងផ្តោតលើ ក្រុមពលរដ្ឋដែលរងផលប៉ះពាល់ដោយផ្ទាល់ពីគម្រោងអភិវឌ្ឍន៍ ។

## *អ្នកចូលរួមការស្ទង់មតិ*

៧៧% នៃអ្នកផ្តល់បទសម្ភាសជាស្ត្រី ហើយមាន៣២% នៃក្រុមគ្រួសារដែលផ្តល់បទសម្ភាស មានស្ត្រីជាមេគ្រួសារ។ មូលហេតុនៃការទទួលបានអ្នកផ្តល់បទសម្ភាសភាគច្រើន ជាស្ត្រីដែលអ្នកទាំងនោះនៅផ្ទះនៅពេលដែលក្រុមអ្នកស្រាវជ្រាវធ្វើបទសម្ភាស។ នេះអាចបណ្តាលមកពីប្រពៃណីស្ត្រីនៅផ្ទះ និងមនុស្សប្រុសក្នុងសហគមន៍ភាគច្រើន ធ្វើចំណាកស្រុករកការងារធ្វើ។ អាយុជាមធ្យមនៃអ្នកផ្តល់បទសម្ភាស គឺ ៤៥ ឆ្នាំ ដែលអ្នកផ្តល់បទសម្ភាសក្មេងបំផុតមានអាយុ ១៨ ឆ្នាំ ហើយចាស់បំផុតមានអាយុ ៧៥ ឆ្នាំ ។

គ្រួសារដែលផ្តល់បទសម្ភាស រស់នៅក្នុងតំបន់ដីសើម ឬប្រើប្រាស់តំបន់នោះដោយផ្ទាល់ ភាគច្រើនបានរស់នៅ ឬប្រើប្រាស់អស់រយៈពេលជាង២០ ឆ្នាំមកហើយ។ សហគមន៍មួយចំនួន ដែលបានកាន់កាប់ដីធ្លីនៅទីនោះជាយូរមកហើយនោះ មានដូចជា សហគមន៍ព្រែកតាគង់មួយ(១៩៨៦) សហគមន៍ព្រែកតាគង់ ៦០ម៉ែត្រ (១៩៩០) សហគមន៍ព្រែកតាគង់បី (១៩៩០) សហគមន៍ព្រែកតានូមួយ (១៩៨១) សហគមន៍ព្រែកតានូ (១៩៩៩) និងសហគមន៍ជើងឯក (១៩៩៩)។ លើសពីនេះ មានសហគមន៍ជាច្រើនទៀត ដែលមិនមានឈ្មោះផ្លូវការ និងគ្រួសារជាច្រើនដែលមិននៅក្នុងសហគមន៍ណាមួយ ឬនៅក្នុងសហគមន៍ដែលមិនមានឈ្មោះផ្លូវការ ក៏ត្រូវបានរួមបញ្ចូលទៅក្នុងការស្រាវជ្រាវនេះដែរ។ ភាគច្រើននៃគ្រួសារទាំងនោះ (៨៦%) បានរស់នៅក្នុងតំបន់ដីសើមនេះយ៉ាងតិច ៥ ឆ្នាំ។

ច្រើនជាងពាក់កណ្តាលនៃគ្រួសារទាំងអស់ (៥១%) រស់នៅដោយពឹងផ្អែកលើតំបន់ដីសើម សម្រាប់ជីវភាពរស់នៅរបស់ពួកគេ ហើយពួកគេបានរស់នៅទីនោះ ព្រោះពួកគេមិនអាចរកលំនៅឋាន នៅតំបន់ផ្សេងបាន។ នៅពេលធ្វើការសាកសួរថា ហេតុអ្វីអ្នកផ្តល់បទសម្ភាសទាំងនោះ ទៅរស់នៅក្នុងតំបន់ដីសើម ៦៦% បានលើកឡើងពីឱកាសផ្នែកសេដ្ឋកិច្ច ដែលតំបន់ដីសើមបានផ្តល់ឱ្យ។ អ្នកផ្តល់បទសម្ភាសមួយចំនួន បានប្រាប់ថាខ្លួនបានរស់នៅក្នុងតំបន់ដីសើមអស់ជាច្រើនឆ្នាំ រីឯអ្នកផ្តល់បទសម្ភាសដទៃទៀតមានទំនាក់ទំនងផ្នែកប្រវត្តិសាស្ត្រជាមួយតំបន់ដីសើម ដោយបានរស់នៅក្នុងតំបន់នោះតាំងពីមុនឆ្នាំ ១៩៧០[៩៧] ឬក្រោយពីការដួលរលំរបបខ្មែរក្រហម។

នៅខណៈដែល សហគមន៍មួយចំនួននៅក្នុងតំបន់នេះ បានរៀបចំជាសហគមន៍ និងធ្វើការងារតស៊ូមតិជាបន្តបន្ទាប់ ទាមទារឱ្យមានការគោរពសិទ្ធិមនុស្សរបស់អ្នកទាំងនោះ សហគមន៍ដទៃទៀតមិនបានរៀបចំជាសហគមន៍ឱ្យបានល្អដោយសារសមាជិកនៅដាច់ពីគ្នា។ គ្រួសារភាគច្រើនរស់នៅមាត់បឹងដែលនៅក្បែរសហគមន៍ដទៃទៀតដែលមានជីវភាពធូរធារ និងមានប័ណ្ណកម្មសិទ្ធិស្របច្បាប់លើដីរបស់ពួកគេ។ គ្រួសារមួយចំនួនតូចរស់នៅដោយផ្ទាល់នៅក្នុងតំបន់បឹង ដែលមួយចំនួនរស់លើដីកោះ ឬផ្ទះដែលមានសសរខ្ពស់ផុតពីផ្ទៃទឹក ហើយជានិច្ចកាលតែងតែនៅដាច់ឆ្ងាយពីសេវាសាធារណៈសំខាន់ៗ ព្រោះតែភាពដាច់ស្រយាលនៃលំនៅឋានរបស់អ្នកទាំងនោះ។

បើយោងតាមនិយមន័យផ្លូវការថ្នាក់ជាតិ[៩៨] មានគ្រួសារសហគមន៍មួយចំនួនជាជនរងគ្រោះ ហើយមានតិចជាង ២០% នៃគ្រួសារទាំងនោះផងដែលមានប័ណ្ណក្រីក្រ[៩៩]។ ជាមធ្យមនៃគ្រួសារដែលបានសម្ភាស មាន១,៥ គ្រួសាររស់នៅក្នុងមួយខ្នងផ្ទះ។ អ្នកផ្តល់បទសម្ភាសចំនួន ៥៥ នាក់ (១២%) បាននិយាយថាមានសមាជិកម្នាក់ក្នុងគ្រួសារ ដែលមានបាត់បង់កាយសម្បទា (ជើង ឬភ្នែក ដែលជាចម្លើយពីរត្រូវបានលើកឡើងច្រើនជាងគេ នៅក្នុងបទសម្ភាសនៅសហគមន៍) ។ លើសពីនេះ ប្រជាពលរដ្ឋចំនួន ៣១ គ្រួសារ (៧%) មានមនុស្សចាស់ម្នាក់ដែលមិនអាចទៅធ្វើការងារបាន ហើយត្រូវការអ្នកមើលថែ ។

គ្រួសារដែលផ្តល់បទសម្ភាសទាំងនោះ មានកម្រិតអប់រំក្នុងប្រព័ន្ធ (ចូលរៀនសាលារដ្ឋ) ខុសៗគ្នា។ មានតែ ១០% នៃគ្រួសារទាំងអស់ប៉ុណ្ណោះដែលមានសមាជិកគ្រួសារម្នាក់បញ្ចប់កម្រិតបឋមសិក្សា ហើយ ៣០% នៃអ្នកផ្តល់បទសម្ភាសមិនបានទទួលបានការអប់រំក្នុងប្រព័ន្ធ (ចូលរៀនសាលារដ្ឋ) នោះទេ ។ ប្រភពចំណូលសម្បូររបស់គ្រួសារអ្នកផ្តល់បទសម្ភាស មានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងតំបន់ដីសើម (សូមមើលជីវភាព) ដែលមានន័យថាគ្រួសារជាច្រើន ពឹងផ្អែកលើទីតាំងរស់នៅរបស់ពួកគេ ដើម្បីប្រកបរបរចិញ្ចឹមជីវិត។

---

[៩៧] អ្នកផ្តល់បទសម្ភាសភាគច្រើន ដែលមានទំនាក់ទំនងជាមួយតំបន់នេះតាំងពីមុនឆ្នាំ ១៩៧០ គឺមកពីតំបន់តាខ្មៅ

[៩៨] យោងតាមស្តង់ដានីតិវិធីប្រតិបត្តិការទទួលយកដីធ្លី និងការផ្លាស់ទីលំនៅថ្មីដោយមិនស្ម័គ្រចិត្តសម្រាប់គម្រោង ដែលទទួលបានហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជាឆ្នាំ ២០១៨ ដែលត្រូវបានអនុម័តតាមរយៈមាត្រា ១ នៃអនុក្រឹត្យលេខ ២២ ស្តីពីការអនុម័តស្តង់ដានីតិវិធីប្រតិបត្តិការទទួលយកដីធ្លី និងការផ្លាស់ទីលំនៅថ្មីដោយមិនស្ម័គ្រចិត្តសម្រាប់គម្រោងដែលទទួលបានហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជាឆ្នាំ ២០១៨

[៩៩] ប័ណ្ណក្រីក្រ គឺជាកម្មវិធីរបស់រាជរដ្ឋាភិបាល ដែលកំណត់គ្រួសារក្រីក្រ និងផ្តល់ដល់ពួកគេនូវប័ណ្ណក្រីក្រ សម្រាប់ប្រើប្រាស់ក្នុងការទទួលបានសេវាសង្គមដូចជា ការថែទាំសុខភាព ការអប់រំ និងទឹកស្អាត

### *បំណុល*

អ្នកផ្តល់បទសម្ភាសចំនួន ២៩៤នាក់ (៦២%) បានប្រាប់ថាពួកគាត់បានជាប់បំណុលគេ។ ទំហំឥណទានជាមធ្យមគឺ ៣.៨២៦,១៨ ដុល្លារអាមេរិក ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ចំនួនអ្នកខ្ចីខ្ពស់បំផុត ២% ត្រូវបានដកចេញ)[៦០] ។ មានអ្នកផ្តល់បទសម្ភាសជាប់បំណុលតែ ៥២% ប៉ុណ្ណោះដែលបាននិយាយថា ពួកគាត់អាចសងបំណុលរបស់គាត់ទាន់ពេលវេលា។ បញ្ហាពាក់ព័ន្ធនឹងការសងបំណុល រួមមានការរំលោភបំពាននានាដូចជាធ្វើឱ្យកូនបំណុលហូបអាហារមិនគ្រប់គ្រាន់ (៩៤នាក់) ឱ្យកូនឈប់រៀនដើម្បីធ្វើការសងបំណុលគេ (៣២នាក់) និងបាត់បង់ដីធ្លីធ្វើជាទ្រព្យបញ្ចាំសម្រាប់ប្រាក់កម្ចី។ អ្នកផ្តល់បទសម្ភាស ៦៤នាក់ បានដាក់ប្លង់ដីស្រែ ឬចំការ ដើម្បីទទួលបានប្រាក់កម្ចី ហើយ ៧០គ្រួសារទៀត បានដាក់ប្លង់ដីឬលិខិតបញ្ជាក់ពីការកាន់កាប់ ឬប្រើប្រាស់ដីធ្លីរបស់ពួកគេដើម្បីបានប្រាក់កម្ចី។ ដោយពិចារណាពីភស្តុតាងមួយចំនួនរបស់អង្គការសមាគមធាងត្នោត និងអង្គការ លីកាដូ ដែលបានរកឃើញពីការជាប់ទាក់ទងរវាងការបាត់បង់ដីធ្លី និងការផ្តល់ប្រាក់កម្ចីគ្មានក្រមសីលធម៌ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ[៦២] ក៏ដូចជាការរាយការណ៍ពីអ្នកផ្តល់បទសម្ភាសចំនួន១៤នាក់ ដែលបានបាត់បង់ដីធ្លីដោយសារមិនអាចសងប្រាក់កម្ចីបាន ឬភ័យខ្លាចមិនអាចសងប្រាក់កម្ចីដោយប្លង់ដី និង



(១៤នាក់)។បញ្ហាផ្សេងទៀតដែលត្រូវបានលើកឡើង រួមមានការធ្វើការងារច្រើនកន្លែងចាប់តាំងពីជំពាក់បំណុលគេមក (៩៣នាក់) និងមិនមានប្រាក់គ្រប់គ្រាន់ដើម្បីចំណាយលើការថែទាំសុខភាព (៨នាក់)។ ក្នុងចំណោម ២៩៤នាក់ ដែលត្រូវបានសម្ភាសថា មានជាប់បំណុល មានតែ ៤៣នាក់ (១៤%) ប៉ុណ្ណោះ ដែលបាននិយាយថាពួកគេមិនមានបញ្ហាធ្ងន់ធ្ងរពាក់ព័ន្ធនឹងការសងបំណុលនោះទេ។

លើសពីនេះ អ្នកផ្តល់បទសម្ភាសជាច្រើន បានប្រើប្រាស់លិខិតបញ្ជាក់ពីការកាន់កាប់ ឬប្រើប្រាស់ដីធ្លី[៦១] ឬលិខិតបញ្ជាក់អត្តសញ្ញាណ ដើម្បីលិខិតបញ្ជាក់ពីការកាន់កាប់ឬប្រើប្រាស់ដីធ្លី ត្រូវបានគេប្រើប្រាស់ ដើម្បីធានាដល់ការសងប្រាក់កម្ចី។ ការណ៍នេះ គួរឱ្យព្រួយបារម្ភខ្លាំងសម្រាប់សុវត្ថិភាពនៃភាពជាម្ចាស់កម្មសិទ្ធិរបស់គ្រួសារប្រជាពលរដ្ឋដែលបានខ្ចីប្រាក់ទាំងនោះ។ ការប្រើប្រាស់ឯកសារ ឬលិខិតបញ្ជាក់អត្តសញ្ញាណ រួមមានអត្តសញ្ញាណប័ណ្ណសៀវភៅគ្រួសារ លិខិតឆ្លងដែន ដើម្បីធានាដល់ការសងប្រាក់ ត្រូវបានលើកឡើងដោយអ្នកផ្តល់បទសម្ភាសចំនួន ៩៧ នាក់ ។

---

[៦០] ទំហំប្រាក់កម្ចីជាមធ្យមនៅកម្ពុជាក្នុងឆ្នាំ២០២០ គឺ ៣៨០៤ ដុល្លារអាមេរិក, ស្រង់ពីសារព័ត៌មាន នីកេ អាស៊ាន រីវ្យូ (Nikkei Asian Review), S Turton 'Hun Sen to Cambodian banks: Seize property if borrowers won't pay' (2020).

[៦១] លិខិតបញ្ជាក់ពីការកាន់កាប់ ឬប្រើប្រាស់ដីធ្លី សំដៅទៅលើភស្តុតាងដែលដី ឬផ្ទះ ត្រូវបានទិញ ឬកាន់កាប់ដោយបុគ្គល ប៉ុន្តែមិនប្រាដកថាផ្តល់នូវសិទ្ធិកាន់កាប់ទ្រព្យស្របច្បាប់នោះទេ

[៦២] អង្គការសមាគមធាងត្នោត និងអង្គការលីកាដូ៖ ការធ្វើឱ្យខូចខាតទ្រព្យដាក់បញ្ចាំ( ២០១៩).

## *ការវិភាគលើបញ្ហាយេនឌ័រ*

អ្នកផ្តល់បទសម្ភាសមួយចំនួន បានលើកឡើងថាបុរសតែងតែធ្វើចំណាកស្រុកចេញពីរាជធានីភ្នំពេញ ដើម្បីទៅរកការងារធ្វើ។ នៅក្នុងសហគមន៍មួយ ស្ត្រីភាគច្រើនដើររកខ្យង និងដាំដំណាំលើទឹកនៅពេលដែលមានចំការដំណាំនៅលើផ្ទៃទឹកក្នុងបឹង។ ចាប់តាំងពីមានការចាក់ដីលុបបឹង សហគមន៍បានលើកឡើងថាស្ត្រីជាច្រើន ឥឡូវនេះ ភាគច្រើនទៅធ្វើការនៅក្នុងរោងចក្រនានា ឬគ្មានការងារធ្វើ ហើយរស់នៅដោយពឹងផ្អែកលើចំណូលរបស់ស្វាមីពួកគេ។ នៅក្នុងសហគមន៍ដទៃទៀត ទាំងបុរស និងស្ត្រីធ្វើការងារដាំដំណាំលើផ្ទៃទឹក ឬដើរប្រមូលខ្យង។ ការនេសាទត្រីភាគច្រើន ត្រូវបានធ្វើដោយបុរស ខណៈដែលការងាររោងចក្រ ភាគច្រើនត្រូវបានធ្វើដោយស្ត្រី។

ស្ត្រីក៏ទទួលរងផលប៉ះពាល់ដោយសារទឹកជន់លិចខ្លាំងដែរ។ ក្នុងករណីខ្លះស្ត្រីបានលើកឡើងថាពួកគេទាំងនោះ ព្យាយាមធ្វើដំណើរកាត់ទឹកជន់លិចដោយទូក (ធ្វើពីដបប្លាស្ទិច) ឬបីកូនទៅសាលារៀន ខណៈដែលបុរសជាប្តីជាទូទៅ បើកបរម៉ូតូកាត់ទឹកជំនន់ ឬមិនឆ្លងកាត់ទឹកជំនន់ជាប្រចាំដូចពួកគាត់ឡើយ។ ស្ត្រីមួយចំនួនបានប្រាប់ថា វាជាការងាររបស់ពួកគេក្នុងការធានាថាកូនៗរបស់ពួកគេ បានទៅដល់សាលារៀនដោយសុវត្ថិភាព ហើយជារឿយៗធ្វើឱ្យស្ត្រីទាំងនោះស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ដូចជាត្រូវដើរកាត់ទឹកកខ្វក់ ដើម្បីជូនកូនទៅរៀន។ ស្ត្រីម្នាក់បានប្រាប់ថាស្បែករបស់គាត់តែងតែឡើងកន្ទួលដោយសារប៉ះទឹកកខ្វក់ ហើយបានបញ្ជាក់ថាកាលមុនពេលមិនទាន់ចាក់ដីបំពេញបឹង ភូមិរបស់គាត់មិនដែលមានទឹកជន់លិចជាប្រចាំឡើយ។ សហគមន៍ជាច្រើន មិនមានភ្លើងបំភ្លឺផ្លូវនោះទេ ហើយស្ត្រីជាច្រើនជាកម្មកររោងចក្រធ្វើដំណើរត្រឡប់មកផ្ទះវិញនៅពេលយប់ បានប្រាប់ថាពួកគេពេលខ្លះមិនមានអារម្មណ៍សុវត្ថិភាពនោះទេ។

ស្ត្រីក៏រកចំណូលបានតិចជាងបុរសផងដែរ។ ជាទូទៅស្ត្រីរកបានតិចជាងបុរសប្រមាណ ១០០ ដុល្លារអាមេរិក។ លើសពីនេះស្ត្រីហាក់ដូចជាជាប់បំណុលជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬអ្នកចងការប្រាក់ឯកជនច្រើនជាងបុរស ប៉ុន្តែនៅក្នុងទំហំកម្ចីតូចជាង។ ទំហំកម្ចីជាមធ្យមរបស់ស្ត្រី គឺ ២០% តិចជាងទំហំកម្ចីជាមធ្យមរបស់បុរស។ គួរឱ្យកត់សម្គាល់ផងដែរថាភាគច្រើនកម្ចីត្រូវបានយកដោយស្ត្រីនៅក្នុងគ្រួសារ ប៉ុន្តែសមាជិកជាច្រើននាក់ក្នុងគ្រួសាររួមគ្នាសងនូវកម្ចីទាំងនោះ។

## *សិទ្ធិក្នុងការទទួលបានលំនៅឋានសមរម្យ*[៦៣]

អនុសញ្ញាអន្តរជាតិសំខាន់ៗចំនួន ៥ ដែលប្រទេសកម្ពុជា បានផ្តល់សច្ចាប័ន ហើយទទួលស្គាល់សិទ្ធិក្នុងការទទួលបានលំនៅឋានសមរម្យ គឺជាការការពារស្របច្បាប់មួយយ៉ាងសំខាន់ ទៅនឹងការបណ្តេញចេញដោយមិនមានសំណងសមរម្យ។[៦៤] ប្រទេសកម្ពុជាមានកាតព្វកិច្ចធានាថាពលរដ្ឋ ដែលកំពុងទទួលបាននូវសិទ្ធិទទួលបានលំនៅឋានសមរម្យ មិនត្រូវរងគ្រោះតាមរយៈការបង្កើនលទ្ធភាពនៃទឹកជំនន់លិចលង់ ការបណ្តេញចេញដោយបង្ខំ ឬសកម្មភាពដទៃទៀតដែលរារាំងដល់ការទទួលបានសិទ្ធិក្នុងការទទួលបានលំនៅឋានសមរម្យនោះទេ។[៦៥] រាជរដ្ឋាភិបាលកម្ពុជាមានកាតព្វកិច្ចធានាថា អង្គភាពរបស់ខ្លួននឹងមិនចូលរួមក្នុងការបណ្តេញសហគមន៍ទាំងនោះចេញពីដីធ្លីដោយបង្ខំនោះទេ ហើយប្រសិនបើមានការបណ្តេញចេញដោយបង្ខំ រាជរដ្ឋាភិបាលគួរចាត់វិធានការទៅលើជនដែលប្រព្រឹត្តនោះ។[៦៦] លើសពីនេះទៅទៀត សិទ្ធិក្នុងការទទួលបានសេរីភាពពី"ការអន្តរាគមន៍តាមទំនើងចិត្ត ឬខុសច្បាប់" ទៅលើលំនៅឋានរបស់ជនណាម្នាក់ត្រូវបានការពារតាមមាត្រា ១៧.១ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ (ICCPR) (១៩៦៦)។ ទោះបីជាបែបនេះ ក្តីភ្នាក់ងាររបស់រដ្ឋដូចជានគរបាលបានប្រាប់គ្រួសារខ្លះដែលរស់នៅក្នុងតំបន់នេះថាពួកគេនឹងត្រូវបានគេបណ្តេញចេញនៅថ្ងៃអនាគត។

ប្រជាពលរដ្ឋជាច្រើនគ្រួសារ នឹងប្រឈមមុខនឹងការបណ្តេញចេញ ឬរងសម្ពាធឱ្យរើទីលំនៅ ព្រោះតែគម្រោងទីក្រុងរណប អាយ អិន ជី ស៊ីធីនិងគម្រោងអភិវឌ្ឍដែលពាក់ព័ន្ធនៅក្នុងតំបន់នេះ។ ជាការគួរឱ្យត្រេកអរប្រជាពលរដ្ឋនៅសហគមន៍មួយ នៅក្នុងតំបន់នៃគម្រោងអភិវឌ្ឍន៍គឺសហគមន៍ព្រែកតាគង់១ បច្ចុប្បន្នទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីសម្រាប់ផ្ទះរបស់ពួកគេ ប៉ុន្តែសហគមន៍ផ្សេងទៀត មិនទាន់ទទួលបានព័ត៌មានអំពីស្ថានភាពភាពជាម្ចាស់កម្មសិទ្ធិលើដីធ្លីរបស់ពួកគេទេ។ ប្រជាពលរដ្ឋនៅសហគមន៍ព្រែកតាគង់១ បានទាមទារឱ្យអាជ្ញាធរផ្តល់ប័ណ្ណកម្មសិទ្ធិលើដីធ្លីរបស់ពួកគាត់ជាយូរយាណាស់មកហើយ ប៉ុន្តែប្រជាសហគមន៍ដទៃទៀតដូចជាព្រែកតាគង់ផ្លូវ៦០ម៉ែត្រ ដែលបានទាមទារដូចគ្នា ជាយូរមកហើយ មិនទាន់ទទួលបានប្លង់ដីនោះទេ ដែលសហគមន៍នេះរស់នៅក្នុងស្ថានភាពដូចគ្នាពាក់ព័ន្ធនឹងព្រំប្រទល់នៃតំបន់ប និងផ្ទះរបស់ពួកគេ។

---

[៦៣] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (១៩៤៨) មាត្រា ២៥(១)

[៦៤] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (១៩៦៦) មាត្រា ១១ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (១៩៦៩) មាត្រា ៥(ង) (៣) អនុសញ្ញាស្តីពីឋានៈនៃជនភៀសខ្លួន (១៩៥១) មាត្រា ២៥(១) អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (១៩៧៩) មាត្រា ១៤(២) អនុសញ្ញាស្តីពីសិទ្ធិកុមារ (១៩៨៩) មាត្រា ២៧ (៣) អនុសញ្ញាស្តីពីកិច្ចការពារសិទ្ធិជនពិការ (២០០៨) មាត្រា ២៨(១)

[៦៥] ដូចខាងលើ

[៦៦] គណៈកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ "សេចក្តីអធិប្បាយទូទៅលេខ ៧៖ សិទ្ធិទទួលបានលំនៅឋានសមរម្យ (មាត្រា ១១(១) នៃកតិកាសញ្ញា)៖ ការបណ្តេញចេញដោយបង្ខំ" (១៩៩៧) កថាខណ្ឌទី៨

នៅពេលសាកសួរពីមូលហេតុ ដែលសហគមន៍ព្រែកតាគង់១ ទទួលបានប្លង់កម្មសិទ្ធិដីធ្លី អ្នកផ្តល់បទសម្ភាសជាច្រើន ក្នុងសហគមន៍បានប្រាប់អ្នកស្រាវជ្រាវថា រាជរដ្ឋាភិបាលទទួលស្គាល់ការកាន់កាប់យូរឆ្នាំរបស់ពួកគេនៅក្នុងតំបន់នោះ។ អ្នកផ្តល់បទសម្ភាស មិនបានលើកឡើងពីយន្តការច្បាប់ណាមួយ ដែលត្រូវបានប្រើប្រាស់ក្នុងនីតិវិធី នៃការផ្តល់ប័ណ្ណកម្មសិទ្ធិនោះទេ។ សហគមន៍ជាច្រើន បានសម្តែងការមិនពេញចិត្តទៅលើអ្វីដែលពួកគេបានឃើញថាជាការអនុវត្តច្បាប់ ដែលមិនស្មើភាពគ្នា ចំពោះបញ្ហាពាក់ព័ន្ធនឹងភាពជាម្ចាស់កម្មសិទ្ធិនៅក្នុងតំបន់នោះ។

មានអ្នកផ្តល់បទសម្ភាសចំនួនតែ ១៨% ប៉ុណ្ណោះ ដែលបាននិយាយថាពួកគេមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុសម្រាប់លំនៅឋានរបស់ពួកគេ។[៦៧] ជាង៨០% នៃអ្នកផ្តល់បទសម្ភាសទាំងអស់បានរស់នៅតាមជុំវិញបឹង។ ក្នុងចំណោមអ្នកទាំងនេះ ភាគច្រើនរស់នៅជាប់ ឬលើផ្ទៃបឹង។ អ្នកដទៃទៀតរស់នៅតាមបណ្តោយព្រែក ឬប្រឡាយដែលហូរចេញពីតំបន់បឹង។ ច្បាប់ភូមិបាល ឆ្នាំ២០០១ បានចែងថា ការកាន់កាប់ដីសាធារណៈរបស់រដ្ឋ រួមមានបឹង និងទន្លេគឺត្រូវបានហាមឃាត់[៦៨] ហើយប្រជាពលរដ្ឋក្នុងសហគមន៍មួយចំនួន ដែលបានរស់នៅនៅក្នុងតំបន់នេះ បាននិយាយថាពួកគេនឹងមិនទទួលបានប្លង់ដីនោះទេ ដោយសាររដ្ឋជាម្ចាស់កម្មសិទ្ធិលើដីដែលជាទីតាំងលំនៅឋានរបស់ពួកគេ។

ក្នុងចំណោមអ្នកផ្តល់បទសម្ភាសចំនួន ៤៦៩នាក់ មាន ៧៩នាក់ (១៦%) បានឮពាក្យចចាមអារ៉ាមថា ពួកគេអាចនឹងត្រូវបានគេបណ្តេញចេញ ហើយ ៨៤នាក់ទៀត (១៧%) ត្រូវបានគេនិយាយប្រាប់ (ភាគច្រើនអាជ្ញាធរមូលដ្ឋាននិយាយប្រាប់) ថាពួកគេនឹងត្រូវបានគេបណ្តេញចេញឆាប់ៗនេះ។ ទោះបីជាមានពាក្យចចាមអារ៉ាមយ៉ាងនេះក៏ដោយ មិនមានអ្នកផ្តល់បទសម្ភាសណាម្នាក់ ទទួលបានការជូនដំណឹងអំពីការបណ្តេញចេញនោះទេ ដែលនេះធ្វើឱ្យពួកគេនៅបន្តមានអារម្មណ៍មិនមានសុវត្ថិភាពអំពីភាពជាម្ចាស់កម្មសិទ្ធិលើដីរបស់ពួកគេ និងមិនអាចមានផែនការទៅអនាគតបាននោះទេ។

[៦៧] “ប្លង់រឹង” ជាឯកសារដែលត្រូវបានទទួលស្គាល់ថ្នាក់ជាតិ ហើយផ្តល់នូវសិទ្ធិស្របតាមច្បាប់ក្នុងភាពជាម្ចាស់កម្មសិទ្ធិ

[៦៨] ច្បាប់ភូមិបាល ២០០១ មាត្រា ៤៣

## យន្តការអន្តរជាតិនានា

### យន្តការពិនិត្យជាសកលតាមកាលកំណត់ (UPR)[៦៩]

រាជរដ្ឋាភិបាលកម្ពុជាបានទទួលយកនូវអនុសាសន៍ជាច្រើនខាងក្រោម ដែលត្រូវបានលើកឡើងនៅក្នុងពេលមានយន្តការពិនិត្យជាសកលតាមកាលកំណត់ ស្តីពីកម្ពុជា គិតត្រឹមថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩៖

S - ១១០.៧០ បញ្ចប់ការធ្វើកំណែទម្រង់ដីធ្លី ដើម្បីសម្របសម្រួលការទទួលបាន ប្រើប្រាស់ និងអភិវឌ្ឍន៍ដីធ្លីរបស់បុគ្គល និងសហគ្រាសខ្នាតតូច និងមធ្យម។

S - ១១០.៧២ អនុវត្តគោលនយោបាយតាំងលំនៅឋានឱ្យមានភាពស្របគ្នា និងអនុវត្តនីតិវិធីសាមញ្ញក្នុងការផ្តល់ប័ណ្ណកម្មសិទ្ធិជាសមូហភាព ផ្តល់ការប្រឹក្សាយោបល់ជាមួយសហគមន៍ សង្គមស៊ីវិល និងក្រុមជនជាតិដើមភាគតិច។

S - ១១០.៧៣ ធានាថាជម្លោះដីធ្លីដែលមិនទាន់បានដោះស្រាយទាំងអស់ ការបណ្តេញចេញ និងការតាំងទីលំនៅថ្មីត្រូវបានដោះស្រាយដោយយុត្តិធម៌ តម្លាភាព តាមរយៈការចរចារ និងការផ្តល់សំណងសមរម្យ។[៧០]

លើសពីនេះ នៅក្នុងការធ្វើសេចក្តីអង្កេតចុងក្រោយទៅលើរបាយការណ៍យន្តការពិនិត្យជាសកលតាមកាលកំណត់លើកទី៦ ស្តីពីកម្ពុជា (២០១៩) គណកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងស្ត្រីភេទ (CEDAW) បានផ្តល់ជាអនុសាសន៍ចំនួន៦ ដែលមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានលំនៅឋាន (២០[ក]) ធានានូវការធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពក្នុងការទទួលបានលំនៅឋានតាមរយៈគោលនយោបាយជាតិ (២១[ខ]) ការផ្តល់នូវលទ្ធភាពទទួលបានលំនៅឋានដល់ស្ត្រីជនជាតិភាគតិចវៀតណាម ដែលកំពុងរស់នៅលើទូកតាមផ្ទៃទឹកបឹងទន្លេសាប (៣២, ៣៣[ក])។

### មេរោគកូវីដ ១៩ និងការបណ្តេញចេញ

នៅក្នុងកំណត់សម្គាល់ណែនាំអំពីមេរោគកូវីដ-១៩ អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិទទួលបានលំនៅឋានសមរម្យ លោក ឡេឡានី ហ្វារហា (Leilani Farha) បានកត់សម្គាល់ថា លំនៅឋានមានសារៈសំខាន់ក្នុងការការពារពីការឆ្លងរីករាលដាលនៃមេរោគ និងអំពាវនាវឱ្យបញ្ឈប់ការបណ្តេញចេញអំឡុងពេល និងក្រោយពេលមានការឆ្លងរាលដាលនៃមេរោគនេះ។ ដោយកត់សម្គាល់ពីភាពធ្ងន់ធ្ងរនៃផលវិបាកក្នុងស្ថានភាពបច្ចុប្បន្នទាក់ព័ន្ធនឹងមេរោគកូវីដ-១៩ អ្នករាយការណ៍ពិសេស មានការព្រួយបារម្ភ ដោយលើកឡើងថាការបណ្តេញចេញណាមួយនៅពេលនេះ គឺជាការផ្តន្ទាទោសប្រហារជីវិតលើអ្នកដែលត្រូវបានគេបណ្តេញចេញ។

សិទ្ធិទទួលបានលំនៅឋានសមរម្យមិនត្រូវបានអង្កេតជាទូទៅនៅតំបន់ដែលបានសម្ភាសនោះទេ។[៧១] ផ្ទះមានបន្ទប់មួយ ឬពីរ ដែលមានសមាជិករស់នៅជាមធ្យម ៦នាក់។ សម្ភារៈដែលសាងសង់ផ្ទះទាំងនោះ មានតម្លៃទាប ដូចជា ស័ង្កសី ដែក ឈើ និងឫស្សី។ អ្នកផ្តល់បទសម្ភាសបានលើកឡើងថា កម្តៅនិងទឹកជំនន់ ផ្តល់ផលប៉ះពាល់មកលើស្ថានភាពរស់នៅរបស់អ្នកទាំងនោះ។ ប្រជាពលរដ្ឋចំនួន ១៦៥ គ្រួសារ បាននិយាយថាទឹកជំនន់ក្នុងសហគមន៍របស់ពួកគេអាចដក់នៅរហូតជាងបួនសប្តាហ៍អំឡុងពេលរដូវវស្សា (សូមមើល ទឹកជំនន់)។ ទឹកជំនន់ផ្តល់ផលប៉ះពាល់គ្រោះថ្នាក់ដល់កុមារ ជាពិសេស ដែលកុមារទាំងនោះ ត្រូវបង្ខំចិត្តធ្វើដំណើរលើទឹកកខ្វក់ទាំងនោះទៅកាន់សាលារៀន។ ជាលទ្ធផល សហគមន៍មួយចំនួនបានលើកឡើងថា កុមារជាច្រើនមិនអាចទៅសាលារៀនបាននៅពេលមានទឹកជន់លិចសហគមន៍ម្តងៗ។ ទឹកជំនន់តែងតែធ្វើឱ្យកុមារជាច្រើនខកខានចូលរៀនជាច្រើនដង អំឡុងពេលរដូវវស្សា។[៧២]

---

[៦៩] ការពិនិត្យជាសកលតាមកាលកំណត់ (UPR) គឺជាដំណើរការពិសេសមួយ ដែលរួមមានការពិនិត្យទៅលើស្ថានភាពសិទ្ធិមនុស្សរបស់គ្រប់រដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិ។ការត្រួតពិនិត្យនេះ ជាដំណើរការដោយផ្អែកលើរដ្ឋ ដោយមានការគាំទ្រពីក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលផ្តល់ឱកាសដល់រដ្ឋជាសមាជិកទាំងអស់ បង្ហាញពីសកម្មភាពដែលពួកគេបានធ្វើ ដើម្បីធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសិទ្ធិនៅក្នុងប្រទេសរបស់ពួកគេ ហើយបំពេញនូវកាតព្វកិច្ចសិទ្ធិមនុស្សរបស់ពួកគេ។ ព័ត៌មានអំពីការពិនិត្យជាសកលតាមកាលកំណត់ នៅកម្ពុជា អាចរកបានតាម https://www.ohchr.org/EN/HRBodies/UPR/Pages/KHIndex.aspx

[៧០] ការពិនិត្យជាសកលតាមកាលកំណត់សម្រាប់កម្ពុជា ការឆ្លើយតបរបស់កម្ពុជាលើអនុសាសន៍មួយចំនួន វគ្គទី ៣២ ការត្រួតពិនិត្យលើកទី៣ ឆ្នាំ ២០១៩ អាចទាញយកបានតាម៖ https://www.upr-info.org/sites/default/files/document/cambodia/session_32_-_january_2019/2rps_cambodia.pdf

[៧១] យោងតាមការិយាល័យឧត្តមស្នងការនៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស សិទ្ធិទទួលបានលំនៅឋានសមរម្យ គឺ ១) ទទួលបានសុវត្ថិភាពផ្លូវច្បាប់លើភាពជាម្ចាស់កម្មសិទ្ធិ ២) ទទួលបានសេវាសាធារណៈ សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធ ៣) តម្លៃសមរម្យ ៥) អាចទៅដល់ ៦) ទីតាំងងាយស្រួលទទួលបានសេវាផ្សេងៗដែលផ្អែកនៃការទទួលបានលំនៅឋានសមរម្យ ជាពិសេសឱកាសរកការងារធ្វើ និង ៧) ភាពគ្រប់គ្រាន់ផ្នែកវប្បធម៌។ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ សលាកប័ត្រព័ត៌មានលេខ ២១ សិទ្ធិក្នុងការទទួលបានលំនៅឋានសមរម្យ ខែវិច្ឆិកា ឆ្នាំ២០០៩ Fact Sheet No. 21/Rev.1.

[៧២] កម្ពុជាបានផ្តល់សច្ចាប័នលើកតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (១៩៦៦) ដែលចែងថាការអប់រំគួរតែផ្តល់ឱ្យដល់កុមារទាំងអស់យោងតាមមាត្រា ១៣

៨៩គ្រួសារ (១៩%) បានលើកឡើងថា ពួកគេមិនមានសម្ភារៈបន្ទប់ទឹកប្រើប្រាស់នោះទេ ខណៈ ៣០៩គ្រួសារ (៦៦%) បាននិយាយថាភ្លើងអគ្គិសនីបំភ្លឺផ្លូវខូច ឬមិនមានភ្លើងអគ្គិសនីបំភ្លឺផ្លូវក្នុងសហគមន៍ ហើយ៣២៣គ្រួសារ (៦៩%) និយាយថាពួកគេមិនបានទទួលសេវាកម្មប្រមូលសំរាមនោះទេ។

ជាចំណុចវិជ្ជមាន អ្នកផ្តល់បទសម្ភាសជាច្រើន ហាក់ដូចជានៅកៀកនឹងសេវាសាធារណៈ និងទីកន្លែងសំខាន់ៗ ដូចជាផ្សារ សេវាសុខាភិបាលសាធារណៈ និងសាលារៀន។ ពាក់ព័ន្ធនឹងការបាត់បង់តំបន់បឹង អ្នកផ្តល់បទសម្ភាសម្នាក់បាននិយាយថា៖ "ខ្ញុំមិនចង់ផ្លាស់ប្តូរពីទីកន្លែងនេះទេ ដោយនៅទីនេះ យើងមានសាលារៀនល្អ និងងាយស្រួលរកការងារធ្វើ។ ដូចនេះខ្ញុំមិនចង់ឱ្យគេបណ្តេញចេញពីទីនេះទេ"។



## *សិទ្ធិទទួលបានសន្តិសុខសង្គម*[៧៣]

កម្ពុជាបានផ្តល់សច្ចាប័នលើកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ICESCR-១៩៦៦) នៅឆ្នាំ១៩៩២ ដោយទទួលស្គាល់សិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលបាននូវសន្តិសុខសង្គម។[៧៤] រាជរដ្ឋាភិបាលកម្ពុជា តាមរយៈការផ្តល់សច្ចាប័នរបស់ខ្លួន លើកាតិកាសញ្ញានេះ និងយោងតាមមាត្រា ២(១) ត្រូវតែចាត់វិធានការដែលមានប្រសិទ្ធភាព ដើម្បីឱ្យប្រជាពលរដ្ឋទទួលបានសិទ្ធិនេះដោយមិនមានការរើសអើង។[៧៥]

ទោះបីជាបែបនេះក៏ដោយ ក៏សេវាសង្គមនានា របស់អ្នកទាំងនោះមិនអាចទទួលបានដោយងាយស្រួលផងដែរ។ អ្នកផ្តល់បទសម្ភាសចំនួន ៣៩៣នាក់ (៨៤%) បាននិយាយថាពួកគេមិនមានសមាជិកគ្រួសារណាម្នាក់ដែលមានប័ណ្ណក្រីក្រនោះទេ។ ប័ណ្ណក្រីក្រ គឺជាកម្មវិធីជួយដល់គ្រួសារក្រីក្រ និងងាយរងគ្រោះឱ្យទទួលបាននូវសេវាសង្គមនានាដូចជាសុខភាព អប់រំ និងទឹកស្អាត។

---

[៧៣] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (១៩៤៨) មាត្រា ២២

[៧៤] កតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(១៩៦៦) មាត្រា ៩

[៧៥] គណៈកម្មាធិការស្តីពីសិទ្ធិសង្គម សេដ្ឋកិច្ច និងវប្បធម៌ "សេចក្តីអធិប្បាយទូទៅលេខ ១៩៖ សិទ្ធិក្នុងការទទួលបានសន្តិសុខសង្គម (មាត្រា ៩)" (២០០៧) កថាខណ្ឌទី៤

## ច្បាប់ និងបទបញ្ញត្តិ

### ‘សូមផ្តល់ជម្រកដល់ខ្ញុំ’

ទោះបីជាការកាន់កាប់លើទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋគឺជាអំពើខុសច្បាប់[៧៦]ហើយអ្នកកាន់កាប់ខុសច្បាប់តម្រូវឱ្យចាកចេញពីតំបន់ដែលខ្លួនកាន់កាប់ដោយបង្ខំ[៧៧] ក៏ដោយ ក៏នៅមានចំណុចស្រពេចស្រពិលទៅលើស្ថានភាពច្បាប់នៃប្រជាពលរដ្ឋដែលធ្វើកសិកម្មក្នុងតំបន់បឹងជើងឯក ឬបឹងទំពុន។ កសិករក្រីក្រជាច្រើនដាំដំណាំលើទឹកបានប្រើប្រាស់តំបន់បឹង ដើម្បីដាំដំណាំ និងបង់ថ្លៃជួលដីបឹងទៅ "ឧកញ៉ា" ឬ "អាជ្ញាធរ" ដើម្បីប្រើប្រាស់ដីនោះ។ លើសពីនេះទៅទៀត គ្រួសារដែលរស់នៅតំបន់បឹងមិនយល់ថាហេតុអ្វីពួកគាត់មិនអាចកាន់កាប់ដីដែលពួកគាត់កំពុងរស់នៅបាន ប៉ុន្តែក្រុមហ៊ុនឯកជនបែរជាអាចអភិវឌ្ឍន៍តំបន់ដែលនៅជុំវិញពួកគេទៅវិញ។ បច្ចុប្បន្ននេះ គ្រួសារច្រើនមិនបានទទួលព័ត៌មានគ្រប់គ្រាន់ដើម្បីស្វែងយល់អំពីសិទ្ធិរបស់ពួកគេយោងតាមក្របខណ្ឌច្បាប់ប្រទេសកម្ពុជា រហូតដល់ស្ថានភាពបានប្រែប្រួល ហើយការបណ្តេញចេញមិនត្រូវបានធ្វើឡើងឡើយ។

### ការកាន់កាប់ដោយខុសច្បាប់

"សារាចរស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់តាមរាជធានី ទីក្រុង និងទីប្រជុំជន"[៧៨] ឬសារាចរលេខ ០៣ បានកំណត់ពីអ្វីដែលយន្តការដោះស្រាយជម្លោះសម្រាប់សហគមន៍ដែលរស់នៅលើទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងសម្រាប់អាជ្ញាធរពាក់ព័ន្ធដើម្បីដោះស្រាយជម្លោះលើការកាន់កាប់ដីធ្លីដោយខុសច្បាប់។ សារាចរលេខ ០៣ កម្រត្រូវបានគេប្រើប្រាស់នៅក្នុងរាជធានីភ្នំពេញ។ គិតត្រឹមពេលចេញផ្សាយរបាយការណ៍នេះ សារាចរលេខ ០៣ មិនទាន់ត្រូវបានគេប្រើប្រាស់ជាមួយសហគមន៍ណាមួយដែលចូលរួមក្នុងការសិក្សានេះនៅក្នុងតំបន់បឹងទំពុនទេ។

### *សិទ្ធិក្នុងការទទួលបានការងារធ្វើ*[៧៩]

យោងតាមមាត្រា ៦ នៃកតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ កម្ពុជាបានទទួលស្គាល់សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការជ្រើសរើសដោយសេរីនូវការងាររបស់ខ្លួន។ រាជរដ្ឋាភិបាលមានកាតព្វកិច្ចធានាថាប្រជាពលរដ្ឋកម្ពុជា មិនត្រូវបានគេដកហូតសិទ្ធិនេះដោយអយុត្តិធម៌នោះទេ។[៨០] គួរឱ្យសោកស្តាយសិទ្ធិរបស់ពួកគាត់មិនត្រូវបានគេគោរព និងការពារសម្រាប់កសិករដាំដំណាំលើទឹក ដែលគ្រួសារអ្នកទាំងនោះបានធ្វើការងារលើតំបន់បឹងអស់ជាច្រើនជំនាន់មកហើយ ។

អ្នកផ្តល់បទសម្ភាសចំនួន ២៤២នាក់ (៥១%) ប្រឈមមុខដោយផ្ទាល់នឹងការបាត់បង់ប្រាក់ចំណូល នៅពេលបាត់បង់បឹង។ អ្នកផ្តល់បទសម្ភាសទាំងនេះ ប្រើប្រាស់បឹងដើម្បីប្រកបរបរនេសាទត្រី (២៥%) រើសខ្យង (១១%) និងដាំដំណាំលើទឹក (៥៩%)។ ភាគច្រើននៃប្រជាពលរដ្ឋកំពុងទទួលនូវផលប៉ះពាល់អវិជ្ជមានពីការបាត់បង់បឹង។ អ្នកផ្តល់បទសម្ភាសច្រើនជាង ៥០% បានលើកឡើងថារយៈពេល ៥ឆ្នាំចុងក្រោយនេះ ប្រាក់ចំណូលរបស់ពួកគេបានធ្លាក់ចុះ។ កសិករដាំដំណាំលើផ្ទៃទឹកបានលើកឡើងពីការបាត់បង់ដីដាំដំណាំ (បាត់បង់បឹង) ហើយគ្រួសារអ្នកនេសាទបានលើកឡើងពីទិន្នផលត្រីធ្លាក់ចុះថាជាមូលហេតុចម្បងដែលធ្វើឱ្យប្រាក់ចំណូលរបស់ពួកគាត់ធ្លាក់ចុះ។ នៅក្នុងករណីភាគច្រើនបំផុត កសិករជាច្រើន បានបាត់បង់ដីព្រោះតែការចាក់ដីខ្សាច់លុបបឹង ឬពេលខ្លះបាត់បង់ដីដោយសារការកាន់កាប់ដីដោយក្រុមហ៊ុនអភិវឌ្ឍន៍ទីក្រុងរណប អាយ អិន ជី ស៊ីធី នៅលើដីដែលពួកគាត់បានកាន់កាប់។

តំបន់មួយចំនួនក្នុងបឹងទំពុន ឬជើងឯកកំពុងត្រូវបានប្រើប្រាស់ជាតំបន់ដាំដំណាំលើផ្ទៃទឹក។ ជាមធ្យមកសិករនៅតំបន់នោះ អាចលក់ដំណាំបាន១.៦០០រៀល ក្នុងមួយគីឡូក្រាមនៅទីផ្សារ។ លើសពីនេះ ពួកគេអាចទុកខ្លះដើម្បីបរិភោគ ដែលមានជាមធ្យមប្រមាណ ៣% នៃដំណាំទាំងអស់របស់ពួកគេ។ ការនេសាទត្រី ការរកកង្កែប រកសត្វល្អិត ចិញ្ចឹមសត្វពាហនៈ និងរកបន្លែធម្មជាតិ ដើម្បីធ្វើជាម្ហូបអាហារ និងលក់ដើម្បីរកចំណូលបន្ថែមសម្រាប់គ្រួសារ។ កសិករក្នុងតំបន់ និងគ្រួសារនេសាទបានលើកឡើងថាត្រី

[៧៦] មាត្រា ៤៣ នៃច្បាប់ភូមិបាល ២០០១

[៧៧] មាត្រា ២៥៩ នៃច្បាប់ភូមិបាល ២០០១

[៧៨] សារាចរស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់តាមរាជធានី ទីក្រុង និងទីប្រជុំជន ២០១០

[៧៩] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (១៩៤៨) មាត្រា ២៣(១)(៣)

[៨០] កតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (១៩៦៦) មាត្រា ៦, គណៈកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ "សេចក្តីអធិប្បាយទូទៅលេខ ១៨៖ សិទ្ធិក្នុងការធ្វើការងារ" ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៥

ដែលរកបានកាន់តែតូចទៅៗនៅពេលបច្ចុប្បន្ននេះ ហើយពិបាករកថែមទៀតនៅភាគខាងជើងនៃបឹង។ គ្រួសារអ្នកនេសាទនៅក្នុងតំបន់បឹង បានប្រាប់អ្នកសម្ភាសថាកាលពីអតីតកាល អ្នកនេសាទទាំងនោះកត់សម្គាល់ឃើញថាមានត្រីខ្លះអាចមានទម្ងន់រហូតដល់ទៅ ៣០គីឡូក្រាម។

ប្រសិនបើកសិកររស់នៅក្នុងតំបន់បឹងមិនអាចប្រើប្រាស់តំបន់នេះដើម្បីរកប្រាក់ចំណូលបាននោះទេ ពួកគេនឹងត្រូវធ្លាក់ចូលក្នុងវិបត្តិបំណុល ឬគ្មានការងារធ្វើ។ អ្នកផ្តល់បទសម្ភាសជាច្រើន បាននិយាយថាពួកគគាត់រៀនចប់ត្រឹមថ្នាក់បឋមសិក្សា ហើយ ១៤០ នាក់ (៣០%) បាននិយាយថាពួកគាត់មិនដែលចូលសាលារៀននោះទេ។ នៅពេលកសិករដំណាំលើទឹក ត្រូវបានសាកសួរដោយអ្នកស្រាវជ្រាវ ថាតើពួកគេនឹងធ្វើអ្វីប្រសិនបើអាជ្ញាធរប្រាប់ពួកគាត់ឱ្យចាកចេញ ពួកគាត់បាននិយាយថាគាត់នឹងចាកចេញ ប៉ុន្តែពួកគាត់នឹងស្វែងរកបឹងផ្សេងទៀត ដែលពួកគាត់អាចរកការងារធ្វើនៅទីនោះ ពីព្រោះនេះជា "អ្វីដែលពួកគាត់អាចធ្វើបាន"។

ប្រមាណ ២៥% នៃគ្រួសារដែលមានស្ត្រីជាមេផ្ទះទាំងអស់ ពឹងផ្អែកលើរបរដែលផ្តល់ចំណូលពីតំបន់បឹង ជាចំណូលចម្បងក្នុងគ្រួសារ។ ប្រមាណ ២៣% នៃគ្រួសារទាំងអស់មានអ្នករកចំណូលចម្បង បានពីតំបន់បឹងនោះ។ នៅពេលសាកសួរថាហេតុអ្វីបានជាអ្នកផ្តល់បទសម្ភាសរស់នៅ និងធ្វើការនៅក្នុងតំបន់បឹង អ្នកផ្តល់បទសម្ភាស ៣០៩ នាក់ (៦៦%) បានឆ្លើយថា កត្តាសេដ្ឋកិច្ច គឺជាកត្តាចម្បងដែលពួកគេរស់នៅទីនោះ។ អ្នកផ្តល់បទសម្ភាសចំនួន ៨៤ នាក់ (១៨%) បាននិយាយថា ពួកគេមិនមានកន្លែងត្រូវទៅរស់នៅនោះទេ។

ទោះបីជាសហគមន៍មួយចំនួនបានប្រឈមមុខនឹងការចាក់ខ្សាច់ជុំវិញពួកគាត់ ប្រជាពលរដ្ឋមួយចំនួនទៀតគ្រាន់តែបាត់បង់លទ្ធភាពក្នុងការប្រើប្រាស់បឹងព្រោះតែការចាក់ខ្សាច់លុបបឹង និងបានចាកចេញពីតំបន់នោះទៅស្វែងរកការងារធ្វើ។ ការចាកចេញដោយខ្លួនឯង គឺជាការរំលោភសិទ្ធិមនុស្ស[៩១] ហើយរាជរដ្ឋាភិបាលកម្ពុជា គួរតែគោរពសិទ្ធិលំនៅឋានរបស់សហគមន៍ជាច្រើនដូចជាសហគមន៍ព្រែកតាគង់១។

### *សិទ្ធិទទួលបានម្ហូបអាហារ*[៩២]

មាត្រា ២៥ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស (១៩៤៨) និង មាត្រា ១១ នៃកតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានទទួលស្គាល់សិទ្ធិ ក្នុងការទទួលបានម្ហូបអាហារ និងសេរីភាពរួចផុតពីភាពអត់ឃ្លាន។ កម្ពុជាបានទទួលស្គាល់ និងចាត់វិធានការទប់ទល់នឹងការអត់ឃ្លាន តាមរយៈការសន្សំសំចៃម្ហូប និងប្រើប្រាស់ចំណេះដឹងផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៃផលិតកម្មអាហារ តាមរយៈការផ្តល់សច្ចាប័នរបស់ខ្លួនលើកតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌[៩៣]។សេចក្តីអធិប្បាយទូទៅលេខ ១២ (១៩៩៩) បានទទួលស្គាល់ថាសិទ្ធិក្នុងការទទួលបានអាហារអាចទទួលបាន នៅពេលដែលប្រជាពលរដ្ឋជាស្ត្រីបុរសកុមារនិងសហគមន៍ អាចទទួលបានអាហារទាំងផ្នែករាងកាយនិងសេដ្ឋកិច្ច។[៩៤] សហគមន៍រស់នៅតំបន់បឹងជាច្រើន ទទួលបានប្រភពអាហារដោយការដាំដំណាំលើផ្ទៃទឹកក្នុងតំបន់បឹង ក៏ដូចជាការនេសាទត្រី និងរកខ្យងជាដើម។ រាជរដ្ឋាភិបាលកម្ពុជា មានកាតព្វកិច្ចការពារសហគមន៍ពីការបាត់បង់លទ្ធភាពទទួលបានម្ហូបអាហារ ក៏ដូចជារក្សាទុកស្បៀងដើម្បីការពារពីការអត់ឃ្លាន។

សន្តិសុខស្បៀង អាចជាការព្រួយបារម្ភដ៏ខ្លាំងមួយ នៅពេលដែលតំបន់បឹងត្រូវបានបំផ្លិចបំផ្លាញស្រប ពេលដែលបឹងបានផ្តល់នូវទិន្នផលត្រី ខ្យងនិងដំណាំដាំដុះជាច្រើន។ ការបាត់បង់តំបន់បឹងធ្វើឱ្យទិន្នផលត្រី ខ្យង និងដំណាំទាំងនេះធ្លាក់ចុះ។ ហើយទាំងការធ្វើអាជីវកម្មខ្សាច់ និងការបំពុលទឹកនៅមុខព្រែកហូរចេញទៅទន្លេបាសាក់ នឹងធ្វើឱ្យត្រីជាច្រើនប្រភេទរងការគម្រាមកំហែងផងដែរ។ សម្រាប់សហគមន៍ខាងលើ សន្តិសុខស្បៀងអាចក្លាយជាការព្រួយបារម្ភដ៏ខ្លាំងមួយ និងជំរុញឱ្យសហគមន៍ធ្លាក់ក្នុងវិបត្តិសេដ្ឋកិច្ចធ្ងន់ធ្ងរ។ បច្ចុប្បន្ននេះ គ្រួសារជាច្រើនដែលពឹងផ្អែកលើតំបន់បឹងដើម្បីរកប្រាក់ចំណូល អាចប្រើប្រាស់ដំណាំលើផ្ទៃទឹកមួយផ្នែក និងខ្យងដែលរកបាន ហើយត្រីដែលនេសាទបានធ្វើជាម្ហូបអាហារប្រចាំថ្ងៃ។

---

[៩១]ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា២០០៩សេចក្តីអធិប្បាយសិទ្ធិមនុស្សនិងសេចក្តីណែនាំស្តីពីការបណ្តេញចេញនិងការតាំងលំនៅថ្មី" ទំព័រ៣១ (៥១)

[៩២] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (១៩៤៨) មាត្រា ២៥(១)

[៩៣] កតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (១៩៦៦) មាត្រា ១១(២)(ក)

[៩៤] គណកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ "សេចក្តីអធិប្បាយទូទៅលេខ ១២៖ សិទ្ធិទទួលបានម្ហូបអាហារគ្រប់គ្រាន់ (មាត្រា ១១)" (១៩៩៩) កថាខណ្ឌទី៦

## អឺបិន វីឡេក(Urban Village)



ប្រជាពលរដ្ឋនៅសហគមន៍ព្រែកតាគង់៦០ម៉ែត្រ ដំបូងបានមករស់នៅលើបឹងទំពុនក្រោយពីការដួលរលំនៃរបបខ្មែរក្រហម។ ដោយគ្មានកន្លែងសម្រាប់រស់នៅ ពួកគេបានសាងសង់ផ្ទះនៅលើបឹង។ អស់រយៈពេលជិត ៣០ ឆ្នាំមកហើយ ដែលពួកគាត់រស់នៅព័ទ្ធជុំវិញដោយទឹក ប៉ុន្តែសព្វថ្ងៃនេះពួកគាត់ត្រូវបានរស់នៅព័ទ្ធជុំវិញដោយខ្សាច់ និងបេតុង។

*"កាលពីដើមយើងមានបរិស្ថានស្រស់ស្អាត។ យើងដាំដំណាំលើទឹក យើងអាចរកខ្យង និងត្រី ហើយវាត្រជាក់ខ្លាំងណាស់ដោយសារតែខ្យល់ដែលបក់ចេញពីបឹង។" (ប្រសាសន៍របស់សមាជិកសហគមន៍ម្នាក់)*

សព្វថ្ងៃព្រែកតាគង់៦០ម៉ែត្រ ជាចំណុចទាបបំផុតនៅក្នុងតំបន់។ ដីឡូត៍ជិតខាងបានចាក់ខ្សាច់បំពេញ ហើយបច្ចុប្បន្នសហគមន៍នេះតែងតែជន់លិចដោយទឹកស្អុយខ្មៅកខ្វក់ដែលធ្វើឱ្យកុមារពិបាកទៅសាលារៀន។ ផ្ទះមួយចំនួន បានចាប់ផ្តើមខូចខាតដោយសារការចាក់ដីនៅជុំវិញ ហើយផ្ទះផ្សេងទៀតត្រូវបានខូចខាតដោយធ្លាក់ដុំថ្ម និងដែក ចេញពីអាគារដែលកំពុងសាងសង់នៅជាប់នឹងផ្ទះក្នុងសហគមន៍។ ម៉្យាងវិញទៀត គេបានប្រាប់ថាពួកគាត់ថាមិនអាចទទួលបានប្លង់កម្មសិទ្ធិ ប៉ុន្តែម្ចាស់អាគារធំៗនៅជាប់នឹងសាហគមន៍បែជាអាចសាងសង់ខុនដូទៅវិញ។

*"ឥឡូវវាក្លាយជាវាលខ្សាច់ទៅហើយ ហើយយើងក៏ទៅធ្វើការនៅរោងចក្រទៀត។ យើងលែងមានបឹងទៀតហើយ។ ពីមុនស្ត្រីរស់នៅអាស្រ័យផលក្នុងបឹង តែឥឡូវយើងត្រូវតែទៅធ្វើការនៅរោងចក្រវិញ បើមិនអ៊ីចឹងយើងហ្នឹងអត់មានការងារធ្វើទេ។ ប្រសិនបើយើងអត់ការងារធ្វើយើងនឹងរស់នៅពឹងលើប្តី។ វាងាយស្រួលណាស់នៅពេលដែលយើងមានបឹង។" (ស្ត្រីម្នាក់ក្នុងសហគមន៍និយាយ)*

សហគមន៍កំពុងបន្តទាមទារសិទ្ធិរស់នៅលើដីក្នុងសហគមន៍របស់ពួកគេ។ នៅឆ្នាំ២០១៨ អាជ្ញាធរបានហៅតំណាងសហគមន៍ម្នាក់ទៅសួរនាំ និងធ្វើកិច្ចសន្យាបន្ទាប់ពីបានរៀបចំទិវាលំនៅឋានពិភពលោក ប៉ុន្តែគាត់មិនភ័យខ្លាច ហើយនៅតែបន្តទាមទារសិទ្ធិឱ្យសហគមន៍របស់គាត់មកដល់សព្វថ្ងៃ។

*"យើងមិនចង់ឱ្យគេបណ្តេញចេញ ឬជម្លៀសទេ។ យើងចង់រស់នៅទីនេះ ជាកន្លែងដែលយើងកំពុងរស់នៅ ហើយយើងមានសិទ្ធិរស់នៅទីនេះ។"*



## សិទ្ធិក្នុងការចូលរួមក្នុងកិច្ចការសាធារណៈ[៩៥]

កម្ពុជាបានផ្តល់សច្ចាប័នលើកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ដូចនេះរាជរដ្ឋាភិបាល ត្រូវធានាថាប្រជាពលរដ្ឋកម្ពុជាមានសិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈ[៩៦] ។ យោងតាមគោលការណ៍ណែនាំសម្រាប់រដ្ឋស្តីពីការអនុវត្តឱ្យមានប្រសិទ្ធិ នៃសិទ្ធិក្នុងការចូលរួមក្នុងកិច្ចការសាធារណៈ (២០១៨) អនុសាសន៍សំខាន់មួយ ឆ្ពោះទៅការគោរពសិទ្ធិនេះ គឺតម្លាភាព និងភាពបើកចំហនៃការសម្រេចចិត្តរបស់រដ្ឋ។[៩៧] លើសពីនេះ សិទ្ធិក្នុង

"ការអភិវឌ្ឍ គឺល្អសម្រាប់អ្នកមានទ្រព្យសម្បត្តិ ប៉ុន្តែយើងមិនមែនជាអ្នកមាន វាមិនល្អប្រសើរសម្រាប់យើងទេ" - កសិករ

ការចូលរួមដោយផ្ទាល់ក្នុងការងារសាធារណៈ ដូចជារដ្ឋបាលសាធារណៈ និងការអនុវត្តគោលនយោបាយ គួរតែត្រូវបានទទួលស្គាល់ ដោយរដ្ឋាភិបាល។[៩៨] បច្ចុប្បន្ននេះ អ្នកផ្តល់បទសម្ភាសជាច្រើន បានដឹងព័ត៌មានតិចតួចអំពីសេចក្តីសម្រេចចិត្តលើគម្រោងអភិវឌ្ឍន៍នៅតំបន់បឹងទំពុន នៅពេលដែលមានការបូមខ្សាច់ និងចាក់ដីលុបបឹង ដែលត្រូវបានធ្វើឡើង ប៉ះពាល់ដល់អនាគតរបស់ពួកគេ ហើយមិនមានការចូលរួមពីពួកគេ។

ការសិក្សាមួយដែលធ្វើឡើងនៅក្នុងឆ្នាំ២០១៧ បានរកឃើញថា សហគមន៍ងាយរងគ្រោះនៅក្នុងបឹងមិនបានដឹងថាគម្រោងអភិវឌ្ឍន៍ អាយ អិន ជីស៊ីធី កំពុងដំណើរការនៅក្នុងតំបន់បឹងនោះទេ[៩៩] ។ នាពេលបច្ចុប្បន្ននេះអ្នកផ្តល់បទសម្ភាសអាចកំណត់បានថាពិតជាមានគម្រោងកំពុងត្រូវបានអភិវឌ្ឍនៅក្នុងតំបន់បឹងទំពុនមែន។ អ្នកផ្តល់បទសម្ភាស នៅពេលសួរថាតើពួកគាត់បានដឹងអ្វីខ្លះពីគម្រោងអភិវឌ្ឍន៍ ពួកគាត់អាចដឹងថាមានគម្រោងធំៗមួយចំនួនកំពុងដំណើរការ ដែលមានជាអាទិ៍ គម្រោងផ្សារទំនើបអ៊ីអន គម្រោងរោងចក្រប្រព្រឹត្តកម្មទឹកកខ្វក់របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (ចៃកា) គម្រោង អាយ អិន ជីស៊ីធី និងគម្រោងមួយចំនួនទៀតរបស់ក្រុមហ៊ុន ជីប ម៉ុង។ ជាការខកចិត្តបំផុត នៅពេលមានអ្នកផ្តល់បទសម្ភាសតែ ៤នាក់ប៉ុណ្ណោះ (< ១%) ដែលបានទទួលព័ត៌មានដោយផ្ទាល់ពីក្រុមហ៊ុនអភិវឌ្ឍន៍នៅតំបន់បឹងទំពុន។ ប្រជាពលរដ្ឋទាំងនេះ មកពីសហគមន៍ព្រែកតាគង់៦០ម៉ែត្រ និងបានជួបពិភាក្សាដោយផ្ទាល់ជាមួយក្រុមហ៊ុនអភិវឌ្ឍន៍គម្រោង អឺបិន វីឡេក (Urban Village)។ ការពិភាក្សានេះកើតឡើងនៅក្រោយពេលគម្រោងត្រូវដាក់ឱ្យដំណើរការ និងពុំមានប្រជាពលរដ្ឋណាម្នាក់ទទួលបានការពិគ្រោះយោបល់ពីក្រុមហ៊ុនឯកជននៅមុនពេលចាប់ផ្តើមអនុវត្តន៍គម្រោងនោះឡើយ។

សិទ្ធិទទួលបានព័ត៌មានពីគម្រោងអភិវឌ្ឍន៍ ដែលអាចប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់បឹងពិតជាមានសារៈសំខាន់

[៩៥] កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (១៩៦៦) មាត្រា ២៥

[៩៦] ដូចខាងលើ

[៩៧] ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស គោលការណ៍ណែនាំសម្រាប់រដ្ឋ ស្តីពីការអនុវត្តឱ្យមានប្រសិទ្ធិនៃសិទ្ធិក្នុងការចូលរួមក្នុងកិច្ចការសាធារណៈ (២០១៨) កថាខណ្ឌទី១៥

[៩៨] គណកម្មាធិការសិទ្ធិមនុស្ស សេចក្តីអធិប្បាយទូទៅលេខ ២៥ (១៩៩៦)

[៩៩] AsienHaus, (2018) ការអភិវឌ្ឍដោយលះបង់ប្រយោជន៍របស់ប្រជាពលមូលដ្ឋាន

ខ្លាំងណាស់សម្រាប់ពួកគាត់ ព្រោះការទទួលបានព័ត៌មានជាមុន អាចជួយពួកគាត់ឱ្យធ្វើការសម្រេចចិត្តចំពោះការរស់នៅក្នុងពេលអនាគត បានត្រឹមត្រូវ។ ការមិនទទួលបានព័ត៌មានជាមុន ធ្វើឱ្យប្រជាពលរដ្ឋទាំងនេះមិនអាចប្រើប្រាស់សិទ្ធិរបស់ខ្លួន ដូចមានចែងក្នុងច្បាប់រដ្ឋធម្មនុញ្ញ ដើម្បីដាក់ពាក្យប្តឹងក្រុមហ៊ុន និងអាចសម្តែងមតិដោយសេរីបានចំពោះគម្រោងអភិវឌ្ឍន៍ទីក្រុងរណបនេះ ។[៩០]

អ្នកផ្តល់បទសម្ភាសជាទូទៅ សម្លឹងឃើញការភិវឌ្ឍរាជធានីភ្នំពេញក្នុងផ្លូវវិជ្ជមាន ប៉ុន្តែពួកគាត់មិនសូវមានគំនិតសុទិដ្ឋិនិយមខ្ពស់ថា នឹងទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍនេះឡើយ។ នៅពេលសួរថា តើគម្រោងនេះនឹងប៉ះពាល់ដល់រាជធានីភ្នំពេញយ៉ាងដូចម្តេច អ្នកផ្តល់បទសម្ភាសបង្ហាញពីកង្វល់ចំពោះទឹកជំនន់ និងបានកត់សំគាល់ថា ផលប្រយោជន៍នឹងបានទៅក្រុមហ៊ុន មិនមែនបានទៅប្រជាពលរដ្ឋក្រីក្រដែលរស់នៅ និងប្រកបរបររកស៊ីចិញ្ចឹមជីវិតនៅក្នុងតំបន់បឹងអស់រយៈពេលជាច្រើនទសវត្សមកហើយនោះទេ។ អ្នកផ្តល់បទសម្ភាសមួយចំនួនចង់ដឹងថា ការបំផ្លាញបឹងនឹងផ្តល់ផលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគាត់យ៉ាងដូចម្តេចដើម្បីពួកគាត់អាចត្រៀមខ្លួនថាគួរធ្វើអ្វីបន្តទៀតនៅពេលអនាគត។ អ្នកផ្តល់បទសម្ភាសផ្សេងទៀត បានបង្ហាញពីការភ័យខ្លាចចំពោះការផ្លាស់ប្តូរទីលំនៅដែលអាចមានន័យផងដែរថា កូនៗរបស់ពួកគាត់នឹងមិនអាចចូលរៀនបានដោយងាយស្រួលដូចធម្មតាទេ ហើយពួកគាត់ក៏មិនអាចប្រកបរបររកស៊ីចិញ្ចឹមជីវិតដូចមុនបានដោយគ្មានបឹងនេះដែរ។

បើទោះជាអ្នកផ្តល់បទសម្ភាសភាគច្រើន មិនដែលទទួលបានការពិគ្រោះយោបល់ពីគម្រោងជាមួយក្រុមហ៊ុន ពួកគាត់ជាងពាក់កណ្តាល (៥៣%) គិតថាគម្រោង អាយ អិន ជីស៊ីធី ប្រហែលជាគម្រោងល្អ។ អ្នកផ្តល់បទសម្ភាសជាច្រើន មានអារម្មណ៍ថា គម្រោងអភិវឌ្ឍន៍ដូចគម្រោងទីក្រុងរណប អាយ អិន ជីស៊ីធី អាចផ្តល់ឱកាសសេដ្ឋកិច្ចនៅក្នុងតំបន់នោះ។ ប៉ុន្តែសហគមន៍នៅទិសឦសាននៃតំបន់បឹង ដែលរស់នៅក្បែរនឹងតំបន់ដែលត្រូវគេចាក់ខ្សាច់បំពេញ និងដែលទំនងជាបានឃើញ ឬទទួលរងគ្រោះដោយសារផលប៉ះពាល់នៃគម្រោងនេះដោយផ្ទាល់ មានគំនិតអវិជ្ជមានចំពោះគម្រោង អាយ អិន ជីស៊ីធី។ សមាជិកសហគមន៍ម្នាក់បាននិយាយថា៖ "មើលទៅល្អ ប៉ុន្តែវាមិនបានផ្តល់ផលប្រយោជន៍អ្វីច្រើនដល់យើងនោះទេ ។"

## ច្បាប់ និងបទបញ្ញត្តិ

### គម្រោងដែលទទួលមូលនិធិពីបរទេស

អនុក្រឹត្យលេខ ២២ បានប្រកាសឱ្យអនុវត្តន៍ជាផ្លូវការនូវនីតិវិធីប្រតិបត្តិស្តង់ដារ ដែលមានគោលបំណងធានាឱ្យបានថា នីតិវិធីផ្លាស់ទីលំនៅរបស់ប្រជាពលរដ្ឋ ត្រូវបានគេអនុវត្តន៍ដោយគោរពតាមស្តង់ដារត្រឹមត្រូវ[៩១] ។ ជារឿយៗ គម្រោងដែលទទួលមូលនិធិបរទេស តែងតែមាននីតិវិធីត្រឹមត្រូវ ដើម្បីគ្រប់គ្រងដំណើរការនៃការជម្លៀស និងការតាំងទីលំនៅថ្មី ដែលមានលក្ខណៈស្តង់ដារ។ ប៉ុន្តែសម្រាប់ក្រុមហ៊ុនអភិវឌ្ឍន៍ដូចជាផ្សារទំនើបអ៊ីអន និង អ អែន អេហ្វ ស៊ីធី (R&F City) ជាដើម នីតិវិធីដែលត្រូវអនុវត្តន៍ គឺត្រូវយោងតាមមាត្រា ២។[៩២]

### គោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស

ក្រុមហ៊ុនពាណិជ្ជកម្មមានកាតព្វកិច្ចគោរពសិទ្ធិមនុស្សតាមរយៈគោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស។[៩៣] ការទទួលខុសត្រូវរបស់ក្រុមហ៊ុនទាំងនេះរួមមាន ការចៀសវាងការរំលោភសិទ្ធិមនុស្ស ឬការធ្វើឱ្យការរំលោភបំពានកាន់តែធ្ងន់ធ្ងរឡើង ដែលបង្កឡើងដោយសារសកម្មភាពពាណិជ្ជកម្មរបស់ខ្លួន។ កាតព្វកិច្ចទាំងនេះក៏រួមបញ្ចូលផងដែរនូវការបន្ធូរបន្ថយ ឬការពារការរំលោភសិទ្ធិមនុស្ស ដែលពាក់ព័ន្ធទៅនឹងគម្រោងពាណិជ្ជកម្មរបស់ខ្លួនផងដែរ[៩៤] ។ ការសិក្សាស្រាវជ្រាវនេះលើកឡើងនូវឧទាហរណ៍មួយចំនួនរបស់ក្រុមហ៊ុនឯកជន ដែលមានដូចជា ក្រុមហ៊ុន អ អែន អេហ្វ គ្រុប (R & F Group) ក្រុមហ៊ុនផ្សារទំនើប អ៊ីអន ក្រុមហ៊ុនអឺបិន វីឡេក (Urban Village) ក្រុមហ៊ុន វើសែល ស្វេ (Versaille Square) ក្រុមហ៊ុន លីណាន ហ្គែលឌិន(Lingnan Garden) ក្រុមហ៊ុនម៉ាក់សេដេស(Mercedez Benz) សាលារៀនភ្នំពេញអន្តរជាតិ និងក្រុមហ៊ុនអន្តរជាតិមួយចំនួនទៀតដែលបានចូលរួមយ៉ាងសកម្ម ឬបានបង្កើតឱ្យមានករណីរំលោភសិទ្ធិមនុស្សរួចទៅហើយ។ រាល់ឯកសារពាក់ព័ន្ធ អត្ថបទស្រាវជ្រាវ ឬយុទ្ធសាស្ត្រកាត់បន្ថយបញ្ហាដែលក្រុមហ៊ុនមានដើម្បីបង្ការការរំលោភសិទ្ធិមនុស្សក្នុងទម្រង់ណាមួយ គួរប្រញាប់ផ្សព្វផ្សាយជាសាធារណៈ។ វាជាការទទួលខុសត្រូវរបស់ក្រុមហ៊ុន ដែលពាក់ព័ន្ធនៅក្នុងគម្រោងទាំងនេះ ដើម្បីអនុវត្តន៍នូវគោលការណ៍សិទ្ធិមនុស្ស។[៩៥]

---

[៩០] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣ មាត្រា ៣៩ និង ៤១

[៩១] អនុក្រឹត្យលេខ ២២ ស្តីពីការដាក់ឱ្យប្រើប្រាស់ស្តង់ដានីតិវិធីប្រតិបត្តិសម្រាប់ការដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ដែលទទួលបានហិរញ្ញប្បទានពីដៃគូរអភិវឌ្ឍន៍ ក្នុងព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៨

[៩២] ដូចខាងលើ មាត្រា ២

[៩៣] គោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស គឺជាកម្រងសេចក្តីណែនាំសម្រាប់រដ្ឋ និងក្រុមហ៊ុនឯកជនសម្រាប់បង្ការ ដោះស្រាយ និងផ្តល់សំណងដល់ការរំលោភសិទ្ធិមនុស្ស បង្កឡើងដោយការធ្វើធុរកិច្ច។ គោលការណ៍ទាំងនេះ ត្រូវបានលើកឡើងដោយអ្នកតំណាងពិសេសនៃអង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្សចន រ៉ូហ្គី (John Ruggie) និងគាំទ្រដោយក្រុមប្រឹក្សាសិទ្ធិមនុស្សនៅក្នុងខែមិថុនា ឆ្នាំ២០១១។ អាចរកបានតាម https://www.ohchr.org/documents/publications/guidingprinciplesbusinesshr_en.pdf

[៩៤] គោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស ២០១១ អង្គការសហប្រជាជាតិ ផ្នែកទី៣ ១៣(ក)(ខ)

[៩៥] ដូចខាងលើ

### សិទ្ធិក្នុងការទទួលបានទឹកស្អាត អនាម័យ[៩៦] និងសិទ្ធិទទួលបានសុខភាពល្អ[៩៧]

កម្ពុជាមានភារកិច្ចការពារសិទ្ធិពលរដ្ឋ ក្នុងការទទួលបានសុខភាពល្អ។ នៅពេលផ្តល់សច្ចាប័នលើកតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច វប្បធម៌ និងសង្គម កម្ពុជាបានយល់ព្រមធ្វើឱ្យប្រសើរឡើងនូវអនាម័យ និងការការពារពីជំងឺ។[៩៨] សិទ្ធិទទួលបានសុខភាពល្អ រួមមាន ទឹកស្អាតសម្រាប់ទទួលទាន និងអនាម័យ អាហារមានសុវត្ថិភាព មានសារជាតិចិញ្ចឹមគ្រប់គ្រាន់ និងលំនៅឋាន បរិយាកាសការងារល្អ និងបរិស្ថានល្អ ការអប់រំ និងព័ត៌មានស្តីពីសុខភាព និងសមភាពយេនឌ័រ។[៩៩] លើសពីនេះ រាជរដ្ឋាភិបាលកម្ពុជាទទួលខុសត្រូវក្នុងការផ្តល់នូវសេវាសុខាភិបាលដែលអាចទទួលបានដោយមិនមានការរើសអើង និងក្នុងការការពារសិទ្ធិក្នុងការបង្ការ ការព្យាបាល និងគ្រប់គ្រងជំងឺ។[១០០] ទោះបីជាយ៉ាងនេះក៏ដោយ រាជរដ្ឋាភិបាលកម្ពុជាបានអនុញ្ញាតឱ្យក្រុមហ៊ុន អាយ អិន ជី ស៊ីធី បន្តអនុវត្តន៍គម្រោងដោយមិនមានរោងចក្រប្រព្រឹត្តកម្មទឹកកខ្វក់ ឬផែនការការពារទឹកជំនន់ ដែលអាចឱ្យសាធារណជនពិនិត្យមើលបាន។

ប្រមាណជា ៧០% នៃទឹកភ្លៀង និងទឹកសម្អុយបានហូរចេញពីរាជធានីភ្នំពេញចូលទៅក្នុងតំបន់បឹងទំពុន ឬជើងឯក[១០១] មុនពេលហូរចូលទៅក្នុងទន្លេបាសាក់នៅឯក្រុងតាខ្មៅ។ បើយោងតាមរបាយការណ៍ដែលរៀបចំឡើងក្រោមកិច្ចសហប្រតិបត្តិការរបស់សាលារាជធានីភ្នំពេញ និងសាលាក្រុងប៉ារីស ដែលមានចំណងជើងថា ការពង្រីក និងការផ្លាស់ប្តូរនៃរាជធានីភ្នំពេញ និងបានបោះពុម្ពផ្សាយក្នុងឆ្នាំ២០១៩ បង្ហាញថាលទ្ធផលនៃការបាត់បង់តំបន់ដីសើមនឹងតម្រូវឱ្យមាននូវដំណោះស្រាយលើការរំដោះទឹកដែលមានបរិមាណពី ២៥ ទៅ ៣០ លានម៉ែត្រគូបក្នុងមួយឆ្នាំទៅកន្លែងផ្សេងមួយទៀត។[១០២] កង្វះកន្លែងរំដោះទឹកជាបណ្តោះអាសន្នអាចបង្កទៅជាការជន់លិចរយៈពេលខ្លីនៅតំបន់ទំនាបមួយចំនួននៅក្នុងរាជធានីភ្នំពេញ ឬការជន់លិចតំបន់ទំនាបខ្លះនៅតាមបណ្តោយមាត់ទន្លេក្នុងក្រុងតាខ្មៅ ឬក៏អាចជន់លិចតំបន់ទាំងពីរខាងលើនេះតែម្តង។

ទឹកជំនន់នៅក្នុងរាជធានីភ្នំពេញអាចបង្កជាគ្រោះមហន្តរាយ និងមានផលប៉ះពាល់ដ៏គ្រោះថ្នាក់ដល់ប្រជាពលរដ្ឋដោយសារតែទឹកទំនន់នេះផ្ទុកនូវសារធាតុគីមី[១០៣] និងទឹកកខ្វក់ដែលមិនទាន់បានធ្វើបន្សុទ្ធ។ ជំងឺផ្សេងៗដែលកើតចេញពីការប្រើប្រាស់ទឹកគ្មានអនាម័យ ការជន់លិចផ្ទះសម្បែង និងការខូចខាតហេដ្ឋារចនាសម្ព័ន្ធផ្លូវ សុទ្ធសឹងជាផលប៉ះពាល់ដែលអាចកើតមាន ប្រសិនបើរាជរដ្ឋាភិបាលមិនបានថែរក្សា និងអភិរក្សតំបន់បឹងទំពុន ឬពុំបានគិតគូររៀបចំយន្តការណាមួយដើម្បីកាត់បន្ថយហានិភ័យនេះ។ សហគមន៍នៅក្នុងតំបន់ដីសើម គឺជាក្រុមងាយរងគ្រោះបំផុតពីការជន់លិច និងត្រូវប្រឈមនឹងបញ្ហាទឹកជំនន់ជាប្រចាំ ដែលបង្កជាកាលំបាកដល់កូនៗរបស់ពួកគាត់ក្នុងការធ្វើដំណើរទៅសាលារៀន និងប្រឈមមុខខ្ពស់នឹងជំងឺផ្សេងៗ។

ទឹកជំនន់ក៏បង្កផលប៉ះពាល់ទៅលើយេនឌ័រផងដែរ ដោយមានស្ត្រីជាច្រើនបានរាយការណ៍ប្រាប់ឱ្យដឹងថាឥទ្ធិពលបង្កឡើងពីទឹកជំនន់ជារឿយៗប៉ះពាល់យ៉ាងខ្លាំងនៅក្នុងផ្ទះរបស់ពួកគេ ដែលស្ត្រីមានតួនាទីមើលការខុសត្រូវ។ ការដើរកាត់ទឹកជំនន់ដែលកខ្វក់ដើម្បីធានាថាកូនអាចទៅរៀនបាន ឬដើម្បីទៅទិញម្ហូបអាហារត្រូវបានរាយការណ៍ថាជាការលំបាកដែលកើតឡើងច្រើនចំពោះស្ត្រី ។

តំបន់ដែលងាយនឹងទទួលរងគ្រោះពីទឹកជំនន់លាតសន្ធឹងពីភាគខាងត្បូងនៃខណ្ឌដូនពេញ ខណ្ឌប្រាំពីរមករា និងខណ្ឌចំការមន ភាគខាងជើងនៃខណ្ឌទួលគោក ភាគខាងកើតនៃខណ្ឌដង្កោ និងភាគខាងលិចនៃផ្នែកខ្លះនៃខណ្ឌមានជ័យ។ តំបន់ងាយរងគ្រោះដោយសារទឹកជំនន់ទាំងនេះ រួមមានរោងចក្រជាង១០០ និងប្រជាពលរដ្ឋជាង ១.៥លាននាក់[១០៤] ព្រមទាំងសហគមន៍ដែលរស់នៅក្បែរតំបន់ដីសើមផងដែរ។ តំបន់ស្ថិតនៅខាងក្រៅរាជធានីភ្នំពេញដូចជាក្រុងតាខ្មៅ ក៏អាចប្រឈមនឹងហានិភ័យបង្កឡើងដោយទឹកជំនន់ និងទំនងជារងគ្រោះធ្ងន់ធ្ងរជាងគេនៅក្នុងរដូវវស្សានៅពេលចរន្តទឹកទន្លេបាសាក់ហូរបញ្ច្រាសមកវិញ។

---

[៩៦] កតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (១៩៦៦) មាត្រា ១១ និង១២

[៩៧] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (១៩៤៨) មាត្រា ២៥(១)

[៩៨] មាត្រា ១២(២)(ខ)(គ)

[៩៩] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងអង្គការសុខភាពពិភពលោក "សាលាកប័ត្រព័ត៌មានលេខ ៣១ សិទ្ធិក្នុងការទទួលបានសុខភាពល្អ" (២០០៨) ទំព័រ៣

[១០០] ដូចខាងលើ

[១០១] សាលាក្រុងប៉ារីស និងសាលារាជធានីភ្នំពេញ៖ ការសិក្សាអំពីការពង្រីក និងការផ្លាស់ប្តូរនៃរាជធានីភ្នំពេញ (ឆ្នាំ២០១៨) ទំព័រទី ៣៨

[១០២] ដូចខាងលើ ទំព័រ ២៧

[១០៣] អង្គការថៃកា "របាយការណ៍ស្តីពីការត្រៀមស្ទង់មតិអំពីគម្រោងអភិវឌ្ឍន៍ប្រព័ន្ធទឹកកខ្វក់នៅក្នុងរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា" ២០១៩ ទំព័រទី ២៦

[១០៤] សាលាក្រុងប៉ារីស និងសាលារាជធានីភ្នំពេញ៖ ការសិក្សាអំពីការពង្រីក និងការផ្លាស់ប្តូរនៃរាជធានីភ្នំពេញ (ឆ្នាំ២០១៨) ទំព័រទី ២៦

## ការការពារបរិស្ថាន

ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក បានចែងថាធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែគ្រប់គ្រងប្រកបដោយស្ថិរភាព ប៉ុន្តែច្បាប់នេះមិនបានលើកឡើងពីការគ្រប់គ្រងតំបន់ដីសើមនោះឡើយ[១០៥]។ មាត្រា ៧ ចែងពីការលើកកម្ពស់កិច្ចសហការរវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយនឹងស្ថាប័នឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីជាប្រយោជន៍ដល់ការការពារ និងអភិវឌ្ឍន៍ធនធានទឹក ប៉ុន្តែគេពុំដឹងច្បាស់ថាតើអង្គការមិនមែនរដ្ឋាភិបាលអាចចូលរួមនៅក្នុងដំណើរការនៃការកំណត់ព្រំប្រទល់បឹងជើងឯក ឬការផ្តល់សិទ្ធិអភិវឌ្ឍន៍ដល់ក្រុមហ៊ុន អាយ អិន ជី នោះឡើយ។ មាត្រា១៧ អនុញ្ញាតឱ្យក្រសួងធនធានទឹក និងឧតុនិយមរំសាយចោលនូវអាជ្ញាប័ណ្ណទាំងឡាយណាដែលពាក់ព័ន្ធនឹងធនធានទឹក ប្រសិនបើអាជ្ញាប័ណ្ណទាំងនោះអាចជះឥទ្ធិពលអវិជ្ជមានធ្ងន់ធ្ងរដល់សុខភាពសាធារណៈ ឬបរិស្ថាន ហើយមាត្រា២៣ បានអនុញ្ញាតឱ្យក្រសួងធនធានទឹក និងឧតុនិយមប្រកាសជាសាធារណៈនូវតំបន់ការពារធនធានទឹក នៅពេលប្រភពទឹក សំខាន់ត្រូវបានបំផ្លាញដោយសកម្មភាពរបស់មនុស្ស ឬនៅពេលកើតមានហានិភ័យនៃការចម្លងជំងឺជាដើម។[១០៦]

## សិទ្ធិក្នុងការទទួលបានទឹកស្អាត និងអនាម័យ

នៅក្នុងឆ្នាំ២០១០ មហាសន្និបាតអង្គការសហប្រជាជាតិបានទទួលស្គាល់សិទ្ធិទទួលបានទឹកស្អាតនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលេខ ៦៤/២៩២។ ទឹកបរិភោគស្អាត និងមានអនាម័យពិតជាមានភាពចាំបាច់ណាស់ដល់ការរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ប៉ុន្តែ គម្រោងបច្ចុប្បន្នដែលបានកំពុងបំផ្លាញតំបន់បឹងអាចធ្វើឱ្យប្រភពទឹកនៅក្នុងតំបន់ដែលប្រជាពលរដ្ឋរស់នៅត្រូវបានបំផ្លិចបំផ្លាញ។ ទឹកជំនន់នៅក្នុងរាជធានីភ្នំពេញអាចបង្កទៅជាការជំងឺរាគត្បាតនៅពេលទឹកសម្អុយ និងទឹកភ្លៀងជន់លិចផ្លូវ។ នៅពេលសួរថាតើគម្រោង អាយ អិន ជី ស៊ីធី អាចជួយប្រជាពលរដ្ឋកម្ពុជាបានដែរឬទេ អ្នកឆ្លើយតបបានលើកឡើងថា គម្រោងគួរតែគិតគូរអំពីការរៀបចំប្រព័ន្ធបង្ហូរទឹកសម្អុយឱ្យបានត្រឹមត្រូវដើម្បីការពារទឹកជំនន់។

### ផែនទីទី ១១៖ រយៈកម្ពស់ស្ថានភាពដីនៅរាជធានីភ្នំពេញ




*ទឹកក្រោមដីនៅក្នុងរាជធានីភ្នំពេញ៖តំបន់ពណ៌ក្រហមជាតំបន់ដែលគេប៉ាន់ស្មានថាងាយនឹងរងគ្រោះដោយសារទឹកជំនន់នៅពេលដែលតំបន់ដីសើមត្រូវបំផ្លាញ។*

ក្រុងតាខ្មៅជាតំបន់ងាយរងគ្រោះ ដោយសារទឹកជំនន់ខ្លាំងជាងគេ ព្រោះនៅក្នុងខែដែលភ្លៀងធ្លាក់ខ្លាំង ទឹកទន្លេបាសាក់ហូរប្រាលខ្លាំង និងលិចតំបន់បឹងទំពុន ឬជើងឯក។ នៅក្នុងរដូវវស្សា ទឹកទន្លេបាសាក់មានកម្ពស់ជាង៧ម៉ែត្រ ដោយពេលខ្លះវាអាចឡើងរហូតដល់៩ម៉ែត្រ។ មាត់ផ្លូវទឹកពីតំបន់ដីសើម ជាពិសេសតំបន់ស្ទឹងជ្រៅ ដែលហូរចូលទន្លេព្រែកត្នោតដែលស្ថិតនៅចំកណ្តាលក្រុងតាខ្មៅ មុនពេលហូរចូលទន្លេបាសាក់នៅក្នុងរដូវវស្សា (ពីខែមករា ដល់ខែឧសភា)។ ចរន្តទឹកហូរផ្លាស់ប្តូរ (សូមមើលផែនទីទី១២) នៅពេលបរិមាណទឹកទន្លេបាសាក់ឡើងដល់កម្រិតអតិបរមានៅក្នុងរដូវវស្សា (ពីខែមិថុនាដល់ខែវិច្ឆិកា)។ តំបន់ដីសើមបន្ទាប់មក ក៏មានកម្ពស់ទាបជាងកម្ពស់ទឹកទន្លេ ដូច្នេះតំបន់ទាំងនេះក៏មិនអាចបន្ធូរដោះទឹកចេញតាមស្ទឹងជ្រៅទៀតដែរ។ ទឹកទន្លេបាសាក់ក៏ចាប់ផ្តើមហូរខ្លាំងតាមទន្លេព្រែកត្នោត ដែលបញ្ចេញទឹកទៅតាមស្ទឹងជ្រៅនិងចុងក្រោយហូរចូលតំបន់បឹងទំពុន ឬជើងឯកដោយជួយការពារទឹកជំនន់នៅក្នុងក្រុងតាខ្មៅ និងរាជធានីភ្នំពេញបានយ៉ាងមានប្រសិទ្ធភាព។

---

[១០៥] មាត្រា ២ នៃច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[១០៦] ដូចខាងលើ មាត្រា ២៣

## ផែនទីទី ១២៖ រំហូរនៃទិសដៅទឹកក្នុងតំបន់បឹងទំពុន ឬជើងឯក




*រូបភាពទីបីៈ សញ្ញាព្រួញពណ៌ខៀវបង្ហាញពីទិសដៅនៃរំហូរទឹកទន្លេ នៅពេលដែលទឹកនៅតែមាននៅក្នុងតំបន់ដីសើមបឹងទំពុន ឬជើងឯកនិងហូរចូលទន្លេបាសាក់។ សញ្ញាព្រួញពណ៌ក្រហមបង្ហាញពីរំហូរទឹកទន្លេបញ្ច្រាសមកវិញ នៅក្នុងខែមួយចំនួននៃរដូវវស្សានៅពេលទឹកទន្លេបាសាក់ឡើងដល់កម្រិតខ្ពស់ល្មមដែលអាចឱ្យទឹកមួយផ្នែកហូរចូលស្ទឹងព្រែកត្នោត និងតំបន់ដីសើមផ្សេងទៀត។ បន្ទាត់ពណ៌ទឹកក្រូចបង្ហាញពីព្រំប្រទល់នៃគម្រោង អាយ អិន ជី ស៊ីធី។*

គម្រោងបច្ចុប្បន្នគ្របដណ្ដប់លើតំបន់ ដែលស្នើសុំសាងសង់ប្រឡាយទឹកដែលអាចរំដោះទឹកដែលនៅសល់ក្នុងតំបន់ដីសើមទៅស្ទឹងព្រែកត្នោតនៅឯក្រុងតាខ្មៅ (សូមមើលផែនទីទី១២ ) ។ តំបន់សាងសង់ប្រឡាយទឹកត្រូវកំណត់ព្រំដែនដោយទីតាំងព្រំប្រទល់នៅតាមបណ្ដោយស្ទឹងជ្រៅ និងជាលទ្ធផលត្រូវបានគេរំពឹងថាអាចនាំឱ្យគ្រួសារជាច្រើនដែលរស់នៅក្នុងតំបន់ដែលស្នើសុំសាងសង់ប្រឡាយទឹក (ប្រឡាយទឹកដូចបង្ហាញនៅក្នុងគ្រោងពណ៌ក្រហមនៅក្នុងផែនទីទី ១៣។ គម្រោងនេះបានបញ្ជាក់ដោយរបាយការណ៍រៀបចំដោយសាលារាជធានីភ្នំពេញ ដែលធ្វើការកត់សម្គាល់ថាគ្រួសារទាំងអស់ដែលរស់នៅតាមចំណុចនេះ ត្រូវតែរុះរើចេញ។[១០៧]គ្រួសារដែលរស់នៅតាមបណ្ដោយតំបន់ដែលបម្រុងទុកសម្រាប់ការស្ដារប្រឡាយទឹក ពុំទាន់ទទួលបានព័ត៌មានស្ដីពីផែនការបណ្ដេញពួកគេចេញនៅឡើយនោះទេ បើទោះជាបង្គោលព្រំដី ត្រូវបានគេបោះនៅលើទីតាំងនោះក៏ដោយ។ នៅពេលសាកសួរថា តើបង្គោលទាំងនោះត្រូវគេបោះដើម្បីអ្វី អ្នកផ្ដល់បទសម្ភាសនិយាយថាពួកគាត់មិនដឹងនោះទេ ឬនិយាយថាបង្គោលទាំងនោះត្រូវបានគេបោះដើម្បីសម្គាល់ព្រំប្រទល់ដីរបស់រដ្ឋ។

[១០៧] សាលាក្រុងប៉ារីស និងសាលារាជធានីភ្នំពេញ៖ ការសិក្សាអំពីការពង្រីក និងការផ្លាស់ប្ដូរនៃរាជធានីភ្នំពេញ (ឆ្នាំ២០១៨) ទំព័រ ៤៣

## ផែនទីទី ១៣៖ ទីតាំងប្រឡាយដែលត្រូវពង្រីក




*រូបភាពទីបួនៈ បន្ទាត់ពណ៌ក្រហមបង្ហាញផ្លូវទឹកដែលអាចត្រូវគេពង្រីកដើម្បីបង្កើតជាប្រលាយបង្ហូរទឹកនៅភាគខាងកើត។*

ប្រឡាយសម្រាប់រំដោះទឹកផ្សេងទៀត គ្រោងនឹងរៀបចំធ្វើបន្ថែមនៅភាគខាងលិចនៃគម្រោង និងប្រហែលជាអាចត្រូវបណ្តេញប្រជាសហគមន៍មួយដែលរស់នៅតំបន់នោះដោយបង្ខំ។ សហគមន៍នេះបានរស់នៅតាមបណ្តោយមាត់ប្រឡាយនេះអស់រយៈពេលជាង ៣០ឆ្នាំមកហើយ ហើយពួកគាត់ក៏មិនដឹងថានឹងមានគម្រោងនៅពេលខាងមុខនេះទេ ។



## ផលប៉ះពាល់លើបរិស្ថាន

តំបន់បឹងទំពុន ឬជើងឯកផ្តល់ជាជម្រកដល់ត្រី សត្វបក្សី និងសត្វព្រៃផ្សេងៗទៀតដែលជិតផុតពូជ ហើយវាក៏ជាតំបន់ប្រព្រឹត្តកម្មទឹកកខ្វក់ដ៏សំខាន់មួយរបស់រាជធានីភ្នំពេញ និងជាតំបន់ដែលជួយទប់ស្កាត់ទឹកជំនន់ផងដែរ។ ជាងនេះទៅទៀត ខ្សាច់ដែលត្រូវការដើម្បីចាក់បំពេញតំបន់នេះក៏អាចជះឥទ្ធិពលខ្លាំងដែរ នៅពេលដែលគេបូមវាពីបាតទន្លេ និងនៅតាមច្រាំងទន្លេបាសាក់ និងទន្លេមេគង្គ ដែលអាចនាំឱ្យមានការថយចុះនៃបរិមាណត្រី ការបាក់ស្រុតផ្ទះធ្លាក់ចូលទន្លេ ការបាត់បង់ជីវិត និងការកើនឡើងនៃហានិភ័យនៃទឹកជំនន់នៅទូទាំងប្រទេសកម្ពុជា[១០៨] ។

### ច្បាប់ និងបទបញ្ញត្តិ

#### ការការពារតាមផ្លូវច្បាប់ដើម្បីនិរន្តរភាពបរិស្ថាន

មាត្រា ៥៩ នៃរដ្ឋធម្មនុញ្ញ បានចែងថារដ្ឋត្រូវការពារបរិស្ថាន និងរៀបចំផែនការឱ្យបានច្បាស់លាស់ដើម្បីគ្រប់គ្រងធនធានធម្មជាតិ[១០៩] ។ ច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (១៩៩៦) មានគោលបំណងការពារបរិស្ថាន និងលើកកម្ពស់ការចូលរួមរបស់សាធារណៈនៅក្នុងការការពារ និងគ្រប់គ្រងធនធានធម្មជាតិ[១១០] ។ អត្ថន័យនៃ "ការចូលរួមរបស់សាធារណៈ" នៅក្នុងបរិបទនេះ មិនសូវមានភាពច្បាស់លាស់ និងរាល់ការសម្រេចចិត្តលើការគ្រប់គ្រងបរិស្ថាននៅក្នុងតំបន់ដីសើម តួយ៉ាងដូចជារោងចក្រប្រព្រឹត្តកម្មទឹកកខ្វក់របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិរបស់ជប៉ុន (ចៃកា) ឬការផ្តល់សិទ្ធិជួលបឹងជើង ឯកក្នុងរយៈពេលវែង ហាក់ដូចជាបានធ្វើការសម្រេចចិត្តដោយគ្មានការពិគ្រោះយោបល់ជាមួយសាធារណៈនោះទេ។ ច្បាប់បានកំណត់ថាផែនការគ្រប់គ្រង និងការពារបរិស្ថានថ្នាក់តំបន់ ឬថ្នាក់ជាតិត្រូវតែរៀបចំទុកជាមុន និងត្រូវត្រួតពិនិត្យសារឡើងវិញនៅក្នុងរយៈពេល៥ឆ្នាំម្តង និងស្ថិតក្រោមកាតព្វកិច្ចរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងបរិស្ថានដោយមានការសហការពីក្រសួង និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត[១១១] ប្រសិនបើចាំបាច់។

---

[១០៨] ខូហ៍ កេន (Koehnken, L) (២០១៨) ផលប៉ះពាលនៃការបូមខ្សាច់ដល់រចនាសម្ព័ន្ធនៃប្រព័ន្ធអេកូឡូស៊ី ដំណើរការ និងជីវចម្រុះនៅក្នុងទន្លេ មូលនិធិសត្វព្រៃពិភពលោក

[១០៩] រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ មាត្រា ៥៩

[១១០] មាត្រា ១ នៃច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦

[១១១] មាត្រា ២ ៣ ៤ និង ៥ នៃច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦

## ការបូមខ្សាច់

ការចាក់បំពេញតំបន់បឹងទំពុន ឬជើងឯកដែលប្រើដីខ្សាច់ដើម្បីបំពេញផ្ទៃបឹង ឬតំបន់ទំនាបសម្រាប់គម្រោងសាងសង់អគារ ត្រូវការខ្សាច់ក្នុងបរិមាណដ៏ច្រើនសន្ធឹកសន្ធាប់។ សម្រាប់គម្រោងមួយនេះ គេត្រូវបូមខ្សាច់ពីទន្លេ[១១២] ដែលបន្ទាប់មកត្រូវដឹកជញ្ជូនតាមសាឡង់នៅកាន់ចំណតណាមួយដែលនៅក្បែរទីតាំងគម្រោង និងបូមបញ្ជូនបន្តខ្សាច់នោះដោយលាយល្បាយទឹកទៅកាន់តំបន់គម្រោង (សូមមើលឧបសម្ព័ន្ធទី ៣) ។

បរិមាណខ្សាច់ ដែលត្រូវការដើម្បីចាក់បំពេញតំបន់នេះ មានចំនួនប្រមាណ៧៧.៦៦០.000 ម៉ែត្រគូប។ តួលេខនេះ គឺគ្រាន់តែជាការប៉ាន់ប្រមាណតាមវិធីធម្មតា ដោយយោងទៅលើទំហំអប្បបរមានៃខ្សាច់ដែលត្រូវការ ដើម្បីចាក់បំពេញទីតាំងគម្រោងឱ្យខ្ពស់ជាងកម្រិត ដែលអាចលិចលង់ដោយសារទឹកជំនន់ក្នុងគម្រោងប៉ុណ្ណោះ[១១៣] ។ គម្រោងនេះអាចនឹងត្រូវការបរិមាណខ្សាច់លើសពី ៧៧.៦៦០.000 ម៉ែត្រគូប។ ប៉ុន្តែផ្នែកខ្លះនៃតំបន់ដែលត្រូវចាក់បំពេញ ដោយប្រើដីជំនួសវិញ ដូច្នេះតួលេខពិតប្រាកដនៃបរិមាណខ្សាច់ដែលគេត្រូវការពិបាកកំណត់ឱ្យបានត្រឹមត្រូវណាស់ ដោយសារគេត្រូវការព័ត៌មានបន្ថែមដើម្បីផ្ទៀងផ្ទាត់។

ការបូមខ្សាច់ទន្លេ មានការជាប់ទាក់ទងនឹង ការព្រួយបារម្ភណ៍ពីបញ្ហាបរិស្ថាន និងបញ្ហាសិទ្ធិមនុស្សជាច្រើន[១១៤] ។ ការព្រួយបារម្ភណ៍ពីបរិស្ថានដែលទាក់ទងទៅនឹងការបូមខ្សាច់ រួមមានការបាក់ច្រាំងទន្លេ ហានិភ័យខ្ពស់នៃទឹកជំនន់ ការបាត់បង់ត្រី ការថយចុះនៃបរិមាណប្រភពទឹកក្រោមដី ការប្រែប្រួលនៃរំហូរទឹក ការបាត់បង់ដីធ្លី និងការបាត់បង់ជម្រករបស់សត្វព្រៃជាដើម[១១៥] ។ សហគមន៍នេសាទ សហគមន៍ដែលរស់នៅតាមបណ្តោយមាត់ទន្លេ និងសហគមន៍ដែលពឹងពាក់លើទឹកក្រោមដី គឺជាសហគមន៍ដែលប្រឈមនឹងហានិភ័យខ្ពស់ ដែលបង្កឡើងដោយផលប៉ះពាល់នៃការបូមខ្សាច់ទន្លេ[១១៦] ។

ក្រុមហ៊ុន ហេរ៉ូ ឃីង (Hero King) គឺជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនធំៗ ដែលកំពុងផ្គត់ផ្គង់ខ្សាច់ដល់គម្រោងចាក់បំពេញខ្សាច់ (សូមមើលឧបសម្ព័ន្ធទី ១)។ ក្រុមហ៊ុន ហេរ៉ូ ឃីង (Hero King) ទទួលបានអាជ្ញាប័ណ្ណបូមខ្សាច់ក្នុងទន្លេមេគង្គ[១១៧] និងខ្សាច់មួយចំនួនទៀត ដែលកំពុងបូមដើម្បីចាក់បំពេញតំបន់បឹងទំពុន ដែលត្រូវគេដឹកជញ្ជូនមកពីតំបន់ទន្លេមេគង្គ។ ជាងនេះទៅទៀតក្រុមហ៊ុន គ្លូប៊ល ហ្គ្រីន ខេមបូឌា អ៊ែនណឺជី ឌីវ៉េឡុបមេន ឯ.ក (Global Green Cambodia Energy Development Co., Ltd.,) ដែលបច្ចុប្បន្នកំពុងត្រូវគេរៀបចំរបាការណ៍ស្តីពីគម្រោងផ្គត់ផ្គង់ខ្សាច់ របស់ក្រុមហ៊ុននេះ ដោយពិនិត្យទៅលើសាឡង់ដឹកជញ្ជូនខ្សាច់ យ៉ាងហោចណាស់ក៏ចំនួនមួយគ្រឿងដែរ (សូមមើលឧបសម្ព័ន្ធទី១)។ សាឡង់ដឹកជញ្ជូនខ្សាច់របស់ក្រុមហ៊ុន ហេរ៉ូ ឃីង ក៏មានជាប់ពាក់ព័ន្ធទៅនឹងទីតាំងបូមខ្សាច់ដែលបានចូលរួមចំណែក ឬបង្កឱ្យមានការបាក់ច្រាំងទន្លេយ៉ាងច្រើនកន្លែងនៅតាមបណ្តោយមាត់ទន្លេមេគង្គ (សូមមើលឧបសម្ព័ន្ធទី២)។ គេពុំទាន់អាចបញ្ជាក់បាននៅឡើយថាតើ សាឡង់បូមខ្សាច់របស់ក្រុមហ៊ុន ហេរ៉ូ ឃីង ដែលមានវត្តមាននៅទីតាំងបូមខ្សាច់ខាងលើ ចូលរួមចំណែកដល់ការបាក់ច្រាំងទន្លេនៅក្នុងតំបន់ដែលកំពុងត្រូវគេបូមខ្សាច់ដើម្បីផ្គត់ផ្គង់ឱ្យគម្រោង អាយ អិន ជី ស៊ីធី ឬយ៉ាងណា។

---

[១១២] បទសម្ភាសជាមួយក្រុមហ៊ុនបូមខ្សាច់ ឆ្នាំ២០១៩ សម្ភាសជាមួយម្ចាស់សាឡង់បូមខ្សាច់ ឆ្នាំ២០១៩

[១១៣] ផ្ទៃក្រឡាសរុបរបស់បឹងទំពុន ដែលជាតួរលេខប្រហែល ដើម្បីចាក់បំពេញខ្សាច់គឺ ១៧.៣ គីឡូម៉ែត្រការ៉េ ជម្រៅគឺពី ១ ទៅ ២ ម៉ែត្រ ដូច្នេះគេអាចគណនាបាន ប្រវែង៣ម៉ែត្រជាកម្ពស់ខ្ពស់បំផុតសម្រាប់ការចាក់បំពេញខ្សាច់ដើម្បីធានាថាទីតាំងមាននេះកម្ពស់ខ្ពស់ជាងកម្រិតទឹកជំនន់។ ការគណនាគឺ១៧៣00000x៣=៥១,៩00,000ម៉ែត្រគីប។តំបន់ជើងឯកសរុបដែលត្រូវបានប៉ាន់ស្មានសម្រាប់ការចាក់បំពេញគឺ៣.៦៨គីឡូម៉ែត្រការ៉េ។ ជម្រៅជាមធ្យមអាចជ្រៅដល់ប្រវែង៦ម៉ែត្រ ក្នុងអំឡុងរដូវវស្សា ដូចច្នេះហើយ ជម្រៅអប្បរមាដែលត្រូវការសម្រាប់ការចាក់បំពេញខ្សាច់ ដើម្បីធានាថាទីតាំងស្ថិតនៅខ្ពស់ជាងនីវ៉ូទឹកជំនន់គឺ៧ម៉ែត្រ។ ការគណនាគឺ ៣៦៨0000x៧=២៥,៧៦0,000ម៉ែត្រគីប។ បរិមាណខ្សាច់សរុបដែលត្រូវការសម្រាប់ការចាក់បំពេញបឹង=៧៧,៦៦0,000[១១០] មាត្រា ១ នៃច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦ ម៉ែត្រគីប។ ជម្រៅយោងតាម JICA, (២០១៦), ការសិក្សាស្តីពីគម្រោងលើកកម្ពស់លូទឹកកខ្វក់និងលូទឹកស្អុយនៅក្នុងទីប្រជុំជននៃរាជធានីភ្នំពេញ, របាយការណ៍ចុងក្រោយ លេខ២។

[១១៤] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (២០១៦) របាការណ៍សង្ខេប ស្តីពីផលប៉ះពាល់សិទ្ធិមនុស្សដោយសារការបូមខ្សាច់នៅកម្ពុជា។

[១១៥] ខូហ៍ កេន (Koehnken, L)(២០១៨) ផលប៉ះពាល់នៃការបូមខ្សាច់លើជីវចម្រុះ ដំណើរការនិងរចនាសម្ព័ន្ធនៃប្រព័ន្ធអេកូឡូស៊ីនៅក្នុងទន្លេ បោះពុម្ពផ្សាយដោយមូលនិធិធនាគារពិភពលោក

[១១៦] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (២០១៦) របាការណ៍សង្ខេប ស្តីពីផលប៉ះពាល់សិទ្ធិមនុស្សដោយសារការបូមខ្សាច់នៅកម្ពុជា។

[១១៧] គេហទំព័ររបស់ក្រុមហ៊ុន ស៊ី អ៊ី អេស (CES): http://ces.com.kh/hero-king-co-ltd.

## កុមារីបុប្ផា កុមារីរ៉ូហ្សា និងកុមារាដារ៉ា

មានសត្វសេកមួយក្បាលទុំនៅលើដើមឈើខាងមុខផ្ទះរបស់បុប្ផា (អាយុ៧ឆ្នាំ) រ៉ូហ្សា (អាយុ៥ឆ្នាំ) និងដារ៉ា (អាយុ៤ឆ្នាំ)។ ដារ៉ា និងរ៉ូហ្សា ជាបងប្អូនបង្កើត ឯអ្នកទាំងពីរជាបងប្អូនជីដូនមួយជាមួយបុប្ផា។ ឪពុករបស់រ៉ូហ្សា និងដារ៉ា បានឆ្លងផ្លូវដើម្បីទៅចាប់សត្វសេកនោះ ប៉ុន្តែគាត់បានធ្លាក់ពីលើមែកឈើ បណ្តាលឱ្យរបួសបាក់ដៃ។ ម្តាយអ្នកទាំងពីរ នៅមើលថែឪពុកនៅផ្ទះក្រោយពេលធ្លាក់ពីលើមែកឈើ។ ម្តាយរបស់បុប្ផា កំពុងលក់បន្លែនៅផ្សារ ហើយឪពុករបស់នាង កំពុងធ្វើការងារជាកម្មករសំណង់។ ដូចនេះ អ្នកទាំងបី ដើរលេងដោយមិនមានអ្នកមើលថែ។

តាមផ្លូវភាគច្រើននៅក្បែរនោះ មានសភាពស្ងប់ស្ងាត់ ប៉ុន្តែក្មេងៗមិនខ្លាចក្នុងការដើរលេងនៅតាមផ្លូវទាំងនោះទេ។ ក្មេងៗ ដើរទៅលេងនៅកន្លែងបូមខ្សាច់ក្បែរនោះ ដែលនៅលើដីរបស់ក្រុមហ៊ុន សុខ ទៀង អ៊ីមផត អិចផត ខូ អិលធីឌី។ ប្រសិនបើមានសន្តិសុខយាមនៅទីនោះក៏ដោយ ពួកគេអាចនឹងមើលមិនឃើញក្មេងទាំងនោះ ឬមិនបានហាមឃាត់ក្មេងទាំងនោះចូលទៅទីតាំងបូមខ្សាច់នេះឡើយ។ ទីតាំងនោះ មិនមានទ្វារ ឬរបងការពារមិនឱ្យក្មេងចូលទេ ហើយសន្តិសុខ និងកម្មករដែលយាមបានដឹងថាមានក្មេងមកពីសហគមន៍ក្បែរនោះ តែងតែចូលទៅលេងខ្សាច់។

នៅពេលដែលឪពុកបុប្ផាមកដល់កន្លែងបូមខ្សាច់ ក្មេងទាំងនោះបានលង់ទឹកក្នុងរណ្តៅនៅទីតាំងបូមខ្សាច់ទៅហើយ។

តំបន់ទឹកដែលសាកសពកុមារ ត្រូវបានរកឃើញ



ខ្សាច់មកពីទន្លេត្រូវបានប្រើប្រាស់ដើម្បីចាក់បំពេញតំបន់ជាច្រើននៅក្នុងតំបន់បឹងទំពុន ឬជើងឯក តាមបណ្តោយមហាវិថីសម្តេចហ៊ុន សែន (ផ្លូវ៦០ម៉ែត្រ)។

*"ខ្ញុំលោតទៅក្នុងទឹក ខ្ញុំបានរកឃើញកូនស្រីខ្ញុំ (បុប្ផា) ... ហើយនិងក្មួយប្រុសខ្ញុំ (ដារ៉ា)។ ខ្ញុំរកនៅក្នុងទឹកអស់រយៈពេលប្រហែល ២០នាទី ទើបរកឃើញក្មួយស្រីខ្ញុំម្នាក់ទៀត (រ៉ូហ្សា)។ នៅពេលខ្ញុំរកឃើញនាង (រ៉ូហ្សា) នាងជាប់នៅក្នុងបំពង់ទុយោបូមខ្សាច់។" ឪពុកបុប្ផាបាននិយាយថា*

នគរបាល បានសាកសួរឪពុកម្តាយក្មេងទាំងបីអំពីហេតុការណ៍នោះ ដោយសួរថាមូលហេតុអ្វីបានជាមិនមានអ្នកនៅមើលថែក្មេងទាំងនោះ ហើយថាតើក្មេងៗ ចូលទៅលេង និងលង់ក្នុងរណ្តៅដោយរបៀបណា។ ឪពុកម្តាយ ត្រូវបានគេប្រាប់ថា នៅយប់នោះ កម្មករក្រុមហ៊ុនត្រូវបាននគរបាលកោះហៅទៅប៉ុស្តិ៍នគរបាល ដើម្បីសរសេររបាយការណ៍ហើយប៉ូលីសទទួលស្គាល់ថាកុមារបានស្លាប់នៅក្នុងការដ្ឋានបូមខ្សាច់របស់ក្រុមហ៊ុនសុខទៀងអ៊ីមផតអ៊ិចផតខូអិលធីឌីពិតប្រាកដមែន។[១១៨] ម្តាយរបស់រ៉ូហ្សា និងដារ៉ា កំពុងត្រូវការការព្យាបាលជំងឺផ្លូវចិត្តដោយកូនរបស់គាត់ទាំងពីរបានស្លាប់។

គិតត្រឹមពេលចេញផ្សាយរបាយការណ៍នេះ គឺមានរយៈពេលពីរខែហើយក្រោយការស្លាប់របស់ក្មេងទាំងបី ហើយកន្លែងបូមខ្សាច់នោះ នៅមិនទាន់មានរបងការពារក្មេងចូលលេងនៅឡើយ។ ក្មេងៗ តែងតែចូលទៅលេងខ្សាច់នៅទីនោះ។ អ្នកតំណាងក្រុមហ៊ុន មិនទាន់បានជួបគ្រួសារដែលបានបាត់បង់កូននោះទេ។

នៅពេលសាកសួរថាតើម្តាយបុប្ផា នឹងនិយាយយ៉ាងណាទៅកាន់ក្រុមហ៊ុន សុខ ទៀង អ៊ីមផត អិចផត ខូ អិលធីឌី នាងចង់ឱ្យពួកគេដាក់របង ដើម្បីការពារក្មេងៗ។ បច្ចុប្បន្ន នាងកំពុងមានផ្ទៃពោះ។

---

[១១៨] ឧបសម្ព័ន្ធទី៦

## ការបាត់បង់ជីវចម្រុះដោយសារការបំផ្លាញតំបន់ដីសើម

ការបាត់បង់ជីវចម្រុះ ការបាត់បង់រុក្ខជាតិ និងសត្វព្រៃគួរត្រូវគេគិតគូរមុនពេលបន្តដំណើរការគម្រោងទៅតាមផែនការកំណត់។ នាពេលបច្ចុប្បន្ន តំបន់ដីសើម គឺជាជម្រកពូជត្រីចំនួន៥២ប្រភេទ សត្វល្មូន និងថលជលិក (សត្វដែលអាចរស់នៅលើគោក និងក្នុងទឹក) ចំនួន ២០ប្រភេទ សត្វបក្សីចំនួន៤៣ប្រភេទ និងថនិតសត្វចំនួនពីរប្រភេទ។[១១៩] ពូជត្រីពីរប្រភេទ និង

> "តាមពិតទៅ ឥឡូវគ្មានត្រីទៀតទេ។ ត្រីមិនអាចរស់នៅក្នុងទឹកខ្មៅកខ្វក់ទៀតទេ។"
>
> នេះជាសម្ដីរបស់អ្នកនេសាទម្នាក់នៅតំបន់ដីសើម។

បក្សីមួយប្រភេទត្រូវបានអង្គការ ចៃកា បានរកឃើញនៅក្នុងការសិក្សារបស់ខ្លួនដែលធ្វើឡើងនៅក្នុងឆ្នាំ២០១៩[១២០] ថាជាប្រភេទពូជសត្វ ដែលកំពុងប្រឈមមុខនឹងការផុតពូជ។ អនុក្រឹត្យលេខ ១២៣ អនក្រ.បក[១២១] ចាត់ទុកពូជត្រីត្រសក់ក្រហម (Isok barb/Probarbus jullien) និងត្រីកាហោឬត្រីគល់រាំង(Giant barb/Catlocarpio siamensis) ថាកំពុងប្រឈមនឹងការផុតពូជ។ នៅក្នុងបញ្ជីក្រហមនៃប្រភេទសត្វជិតផុតពូជរបស់អង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ (IUCN) ពូជត្រីកាហោ ឬត្រីគល់រាំង ជាប្រភេទត្រីដែលជិតផុតពូជគួរឱ្យព្រួយបារម្ភខ្លាំង[១២២] ហើយ អម្បូរត្រីត្រសក់ក្រហម និងត្រីប្រា (Iridescent shark-catfish/Pangasius Hypophthalmus) ក៏ចាត់ទុកជាប្រភេទត្រីដែលប្រឈមនឹងការផុតពូជដែរ[១២៣]។ ជាងនេះទៅទៀត សត្វទីតលីតស្លាបក្រោមត្នោតចាស់ (Green Sandpiper/Tringa guttifer) គឺជាប្រភេទពូជបក្សីដែលគេប្រទះឃើញនៅក្នុងតំបន់ដីសើម និងកំពុងរងគ្រោះពីការជិតផុតពូជផងដែរ[១២៤]។

តំបន់ដីសើមបឹងទំពុន ឬជើងឯកអាចចាត់ទុកថាជាតំបន់ដ៏សំខាន់មួយសម្រាប់បង្កាត់ពូជត្រី។ បើតាមភស្តុតាងពីកសិករ និងអ្នកស្រាវជ្រាវបានបង្ហាញថា ត្រីដែលធ្វើបន្លាស់ទីមកពីទន្លេបាសាក់ និងទន្លេមេគង្គ អាចប្រើតំបន់ដីសើមនេះដើម្បីបង្កាត់ពូជនៅក្នុងរដូវត្រីពង[១២៥][១២៦]។ ការផ្លាស់ទីរបស់ត្រីនេះ ក៏គួរត្រូវសិក្សាស្រាវជ្រាវបន្ថែម ដែលនេះជាអនុសាសន៍សំខាន់មួយនៃអនុសាសន៍ផ្សេងទៀត ដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះ។

### ត្រីក្នុងទឹកបឹងទំពុន

"កាលពី ១០ ឆ្នាំមុនត្រីធំណាស់ មានចាប់ពី ៣០ ទៅ ៤០ គីឡូក្រាមក្នុងមួយក្បាល។ ប៉ុន្តែឥឡូវទំហំមិនធំដូចមុនទៀតទេ។ នៅពេលដែលក្រុមហ៊ុនអភិវឌ្ឍន៍ ចាក់លុបបឹងនេះទឹកកាន់តែខ្មៅកខ្វក់ហើយត្រីមិនអាចរស់នៅបានទេ។"

ត្រីនៅតំបន់បឹងទំពុន ឬជើងឯក គឺជាប្រភពអាហារ និងចំណូលរបស់ប្រជាសហគមន៍ជុំវិញបឹង។ បច្ចុប្បន្ននេះបទសម្ភាសបានរកឃើញថាបរិមាណត្រីបានថយចុះ និងមានទំហំតូចៗជាងមុន។ សហគមន៍ដែលរស់នៅតាមដងទន្លេមេគង្គ និងទន្លេបាសាក់ ការនេសាទគឺជាប្រភពចំណូលចម្បង ហើយដីខ្សាច់ដែលបូមចេញពីទន្លេទាំងនេះ ទៅលុបតំបន់បឹងទំពុន ឬជើងឯកបានគំរាមកំហែងដល់ជីវភាពរស់នៅរបស់ពួកគេនៅតាមដងទន្លេមេគង្គ។

"ត្រីមិននៅទីនោះទៀតទេ។ ប្រហែលជាពួកវាគេចចេញពីសំឡេងរំខាន ឬផ្លាស់ទីចូលទៅកាន់ ទឹកជ្រៅ ព្រោះក្រុមហ៊ុនអភិវឌ្ឍន៍បូមខ្សាច់ចេញពីទន្លេ។ ឥឡូវនេះ យើងពិបាកនេសាទត្រីណាស់។"

ការបូមខ្សាច់មិនមែនជាហានិភ័យតែមួយគត់ ដល់ជម្រកត្រីនៅតាមដងទន្លេមេគង្គ ឬទន្លេបាសាក់នោះទេ។ នៅពេលដែលតំបន់បឹងទំពុនមិនមានលទ្ធភាពចម្រោះទឹកកខ្វក់ដែលចេញពីរាជធានី ភ្នំពេញ ពេលនោះទឹកកខ្វក់នោះនឹងហូរចាក់ចូលទៅក្នុងទន្លេបាសាក់ ឬទន្លេមេគង្គ ឬទាំងពីរ។

---

[១១៩] អង្គការចៃកា "របាយការណ៍ត្រៀមស្ទង់មតិអំពីគម្រោងអភិវឌ្ឍន៍ប្រព័ន្ធទឹកកខ្វក់នៅក្នុងរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា" ២០១៩

[១២០] ដូចខាងលើ

[១២១] អនុក្រឹត្យលេខ ១២៣អនក្រ.បក ស្ដីពីការកំណត់ប្រភេទផល ផលិតផលជលផលដែលកំពុងគ្រោះថ្នាក់ថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩

[១២២] ហោហ្គេន(Hogan, Z.) ឆ្នាំ២០១១ Catlocarpio siamensis បញ្ជីក្រហមរបស់អង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិនៃប្រភេទត្រីរងការគំរាមគំហែងឆ្នាំ ២០១១៖ e.T180662A7649359. https://dx.doi.org/10.2305/IUCN.UK.2011-1.RLTS.T180662A7649359.en. ទាញយកនៅថ្ងៃទី ៣១ ខែមករា ឆ្នាំ២០២០

[១២៣] អះម៉ាត់ អេ ប៊ី(Ahmad, A.B.) ឆ្នាំ២០១៩ Probarbus jullieni . បញ្ជីក្រហមរបស់អង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិនៃប្រភេទត្រីរងការគំរាមគំហែងឆ្នាំ ២០១៩៖ e.T18182A1728224. https://dx.doi.org/10.2305/IUCN.UK.2019-2.RLTS.T18182A1728224.en. ទាញយកនៅថ្ងៃទី ៣១ ខែមករា ឆ្នាំ២០២០ Vidthayanon, C. & Hogan, Z. ឆ្នាំ២០១១ Pangasianodon hypophthalmus បញ្ជីក្រហមរបស់ អង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិនៃប្រភេទត្រីរងការគំរាមគំហែងឆ្នាំ ២០១១៖ e.T180689A7649971. https://dx.doi.org/10.2305/IUCN.UK.2011-1.RLTS.T180689A7649971.en. ទាញយកនៅថ្ងៃទី ៣១ ខែមករា ឆ្នាំ២០២០

[១២៤] អង្គការជីវិតសត្វស្លាបអន្តរជាតិ ឆ្នាំ២០១៦ Tringa guttifer . បញ្ជីក្រហមរបស់អង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិនៃប្រភេទត្រីរងការគំរាមគំហែងឆ្នាំ ២០១៦៖: e.T22693225A93391729. https://dx.doi.org/10.2305/IUCN.UK.2016-3.RLTS.T22693225A93391729.en. ទាញយកនៅថ្ងៃទី ៣១ ខែមករា ឆ្នាំ២០២០

[១២៥] កំណត់សម្គាល់ការស្រាវជ្រាវរបស់អង្គការសមាគមធាងត្នោត ២០១៩

[១២៦] សាលាក្រុងប៉ារីស និងសាលារាជធានីភ្នំពេញ, ការពង្រីក និងការផ្លាស់ប្ដូរនៃរាជធានីភ្នំពេញ (ឆ្នាំ២០១៨) ទំព័រ ២៨

## ប្រព្រឹត្តកម្មទឹកកខ្វក់

ការដើរតួនាទីជាតំបន់ប្រព្រឹត្តកម្មទឹកកខ្វក់ធម្មជាតិដ៏ធំមួយ តំបន់ដីសើមបឹងទំពុន ឬជើងឯកអាចបន្សុទ្ធទឹកសម្អុយក្នុងប្រសិទ្ធភាព ៥០% ដោយមានពពួករុក្ខជាតិដែលរស់លើទឹកដូចជារំចង់ ត្រកួន កញ្ឆែត កំប្លោក និងកក់ ដែលជាប្រភេទរុក្ខជាតិអាចដាំដុះដោយកសិករមូលដ្ឋានបាន។ ការសិក្សារបស់ចៃកាដើម្បីត្រៀមរៀបចំគម្រោងសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកកខ្វក់ ក៏មានតារាង ដែលបង្ហាញពីប្រសិទ្ធភាពនៃតំបន់ដីសើមក្នុងការបន្សុទ្ធទឹកភក់ស្អុយ (TSS) តម្រូវការអុកស៊ីសែនក្នុងជីវគីមី (BOD) បរិមាណនីត្រូហ្សែនសរុប (T-N) និង បរិមាណផូស្វ័រសរុប (T-P) ផងដែរ[១២៧]។

កង្វះប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ធ្វើឱ្យបរិមាណទឹកកខ្វក់ដ៏ច្រើន ដែលហូរចេញពីរាជធានីភ្នំពេញនឹងហូរបន្តចូលទៅក្នុងទន្លេបាសាក់មិនបានត្រូវបានបន្សុទ្ធឱ្យបានត្រឹមត្រូវគ្រាប់គ្រាន់នោះទេ។ ប្រសិនបើទឹកកខ្វក់ទាំងនេះហូរចូលទន្លេបាសាក់ដោយមិនបានបន្សុទ្ធ នោះទឹកកខ្វក់អាចនាំឱ្យបាត់បង់បរិមាណត្រីនៅក្នុងតំបន់ដែលទឹកហូរចូល និងបង្កជាហានិភ័យខ្ពស់ដល់សុខភាពរបស់ប្រជាពលរដ្ឋនៅតំបន់ក្បែរនោះ[១២៨] និងសត្វដែលរស់នៅក្នុង និងក្បែរតំបន់ដីសើម ដែលកំពុងត្រូវបានបំផ្លាញ។ លើសពីនេះទៀត នៅពេលតំបន់ដីសើមបឹងទំពុន ឬជើងឯកត្រូវគេបំផ្លាញកាន់តែខ្លាំងឡើង ប្រជាសហគមន៍ និងសត្វដែលរស់នៅក្បែរនោះនឹងកាន់តែប្រឈមនឹងការបំពុលកាន់តែខ្លាំងដែរ នៅពេលតំបន់បឹងទំពុន ឬជើងឯកមិនអាចធ្វើប្រព្រឹត្តកម្មទឹកកខ្វក់បានគ្រប់គ្រាន់ដូចក្នុងពេលកន្លងមក ព្រោះតែផ្ទៃបឹងរួមតូច។

ទោះជាចៃកា ផ្តល់ជំនួយដល់ការសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកកខ្វក់សម្រាប់រាជធានីភ្នំពេញក៏ដោយ ក៏គម្រោងនេះត្រូវការចំណាយប្រាក់ច្រើនសន្ធឹកសន្ធាប់ និងមិនសូវមានប្រសិទ្ធភាពខ្ពស់ ដូចប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ធម្មជាតិនៅក្នុងតំបន់បឹងទំពុននោះដែរ។ ប្រទេសជប៉ុនបានផ្តល់សច្ចាប័នលើកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ កតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច វប្បធម៌ និងនយោបាយ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រី (១៩៧៩) ហើយរាជរដ្ឋាភិបាលជប៉ុនត្រូវតែប្រកាន់ខ្ជាប់នូវកាតព្វកិច្ចរបស់ខ្លួនតាមអនុសញ្ញាទាំងនេះ។



[១២៧] អង្គការចៃកា "របាយការណ៍ស្តីពីការត្រៀមស្ទង់មតិអំពីគម្រោងអភិវឌ្ឍន៍ប្រព័ន្ធទឹកកខ្វក់នៅក្នុងរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា" ២០១៩

[១២៨] បានបញ្ជាក់តាមរយៈបទសម្ភាសជាមួយអ្នកជំនាញខាងបរិស្ថាន និងអ្នកជំនាញវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

# ៦. សេចក្តីសន្និដ្ឋាន

តំបន់ដីសើមបឹងទំពុន ឬជើងឯកក្នុងកំពុងត្រូវបានបំផ្លាញដោយក្រុមហ៊ុនអភិវឌ្ឍន៍ដែលសាងសង់ខុនដូបុរី និងផ្សារទំនើបធំៗ។ សារៈសំខាន់ជាចម្បងនៃតំបន់ដីសើមចំពោះប្រព្រឹត្តកម្មទឹកកខ្វក់ ការការពារទឹកជំនន់ ការផ្តល់ប្រភពអាហារ និងទីជម្រកសម្រាប់ប្រជាពលរដ្ឋក្រីក្រ គឺត្រូវបានយល់ដឹងយ៉ាងច្បាស់ពីទំនាក់ទំនងយ៉ាងជិតស្និទរវាងតំបន់ដីសើម និងអត្ថប្រយោជន៍សាធារណៈ។ ទោះយ៉ាងនេះក្តី ការបំផ្លាញតំបន់ដីសើមកំពុងបន្តឥតឈប់ឈរហើយ ការស្រាវជ្រាវនេះ បង្ហាញថាការរំលោភបំពានសិទ្ធិមនុស្ស និងផលប៉ះពាល់ដល់បរិស្ថានអាចនឹងកើតមាន ប្រសិនបើនិន្នាការបច្ចុប្បន្ននៅតែបន្ត។ ប្រសិនបើគ្មានការស្រាវជ្រាវជាលក្ខណៈវិទ្យាសាស្ត្រប្រកប ដោយតម្លាភា អំពីសារៈសំខាន់នៃតំបន់ដីសើមបឹងទំពុន ឬជើងឯក និងផលប៉ះពាល់នៃការបាត់បង់តំបន់នេះ ការបន្តបំផ្លាញតំបន់នេះនឹងគំរាមកំហែងដល់ជីវភាពរបស់ប្រជាជនជាងមួយលាននាក់ នៅក្នុងរាជធានីភ្នំពេញ ក្រុងតាខ្មៅ និងតំបន់ជុំវិញទាំងនេះ ដោយទឹកជំនន់ និងការបំពុលទឹកប្រកបដោយគ្រោះថ្នាក់។ ការស្រាវជ្រាវបន្ថែមទៀត ចាំបាច់ត្រូវធ្វើជាបន្ទាន់។ របាយការណ៍នេះ បានបង្ហាញនូវបញ្ហាធ្ងន់ធ្ងរជាច្រើន ដែលគួរតែមានការពិនិត្យមើលឡើងវិញទៅលើនិរន្តរភាពផ្នែកបរិស្ថាន និងការរំលោភសិទ្ធិមនុស្សបង្កដោយគម្រោងអភិវឌ្ឍន៍ទាំងនេះ។

# ៧. អនុសាសន៍ និងជម្រើសផ្សេងៗ

ដោយផ្អែកលើការរកឃើញនៃការស្រាវជ្រាវនេះ ក៏ដូចជាមតិ និងសំណូមពរពីប្រជាពលរដ្ឋមូលដ្ឋានរស់នៅក្នុងតំបន់បឹងតំពុន ឬជើងឯក របាយការណ៍នេះ សូមលើកឡើងនូវអនុសាសន៍ និងជម្រើសផ្សេងៗ ដែលមានដូចខាងក្រោម៖

**១. ផ្អាកការអភិវឌ្ឍនៅក្នុងតំបន់បឹងទំពុន ឬជើងឯករហូតដល់ជម្លោះដីធ្លី និងផលប៉ះពាល់លើសិទ្ធិមនុស្ស និងបរិស្ថានត្រូវបានសិក្សាឱ្យច្បាស់លាស់។**

ភស្តុតាងសំខាន់ៗ បង្ហាញថាស្ថានភាពនៅក្នុងតំបន់ដីសើមមានហានិភ័យខ្ពស់ដល់ប្រជាពលរដ្ឋមូលដ្ឋាន ប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញ និងទីក្រុងតាខ្មៅ។ ការអភិវឌ្ឍគួរត្រូវបានផ្អាករហូតដល់បញ្ហាដែលបានបង្ហាញនៅក្នុងការស្រាវជ្រាវនេះ ត្រូវបានសិក្សាស៊ីជម្រៅបន្ថែមទៀត បោះពុម្ពផ្សាយជាសាធារណៈ និងពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធដូចជា ប្រជាពលរដ្ឋក្នុងតំបន់ អង្គការសង្គមស៊ីវិល និងអ្នកជំនាញផ្នែកបរិស្ថាន។

**២. រាជរដ្ឋាភិបាលត្រូវតែធានានូវការសិក្សាបន្ថែមទៀត ដើម្បីឈ្វេងយល់ឱ្យបានច្បាស់លាស់អំពីផលប៉ះពាល់នៃគម្រោងទីក្រុងរណប អាយ អិន ស៊ីធី និងការបាត់បង់តំបន់ដីសើមបឹងទំពុន ឬជើងឯក។**

របាយការណ៍នេះ បង្ហាញឱ្យឃើញច្បាស់ពីតម្រូវការចាំបាច់នូវការស្រាវជ្រាវស៊ីជម្រៅបន្ថែមទាក់ទងនឹងគម្រោងអភិវឌ្ឍន៍ដ៏ធំបំផុតមួយនេះនៅក្នុងប្រទេសកម្ពុជា។ ការស្រាវជ្រាវស៊ីជម្រៅស្តីពីផលប៉ះពាល់នៃការបាត់បង់តំបន់បឹងទំពុន ឬជើងឯក ទៅលើអនាម័យទឹកស្អាត ប្រព័ន្ធជលសាស្ត្រ និងបរិស្ថាន គួរត្រូវបានធ្វើឡើង ប្រសិនបើពុំទាន់ត្រូវបានធ្វើនៅឡើយ។ រាល់ការស្រាវជ្រាវដែលបានធ្វើ គួរផ្សព្វផ្សាយដល់សាធារណជន និងអ្នកជំនាញដើម្បីយកទៅសិក្សា។

**៣. ក្រសួងដែនដី និងស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាលត្រូវធានាថាការបណ្តេញចេញ និងជម្លោះដីធ្លីគួរតែត្រូវបានដោះស្រាយអនុលោមតាមច្បាប់ គោលការណ៍សិទ្ធិមនុស្សស្តីពីការការបណ្តេញចេញ និងការតាំងទីលំនៅថ្មី និងមិនត្រូវបង្កើតឱ្យមានភាពមិនប្រក្រតីផ្នែកច្បាប់ណាមួយឡើយ។**

ការធ្វើចំណាត់ថ្នាក់ដីឡើងវិញនៅតំបន់បឹងទំពុន ឬជើងឯក បានបង្ហាញឱ្យឃើញច្បាស់នូវបញ្ហានីតិរដ្ឋ ដោយសារការណ៍នេះ ទាក់ទងនឹងការកាន់កាប់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។ ក្នុងចំណោមសហគមន៍ក្រីក្រជុំវិញបឹងទំពុនទាំងអស់ មានតែសហគមន៍ព្រែកតាគង់១ប៉ុណ្ណោះ ដែលត្រូវបានអាជ្ញាធរចេញប័ណ្ណកម្មសិទ្ធិដីធ្លី ហើយដំណើរការនេះគួរត្រូវបានអនុវត្តន៍សម្រាប់សហគមន៍ផ្សេងទៀត ដែលបានប្រើប្រាស់ និងរស់នៅទាំងនៅក្នុង និងជុំវិញតំបន់បឹងទំពុន ឬជើងឯក។

**៤. រាជរដ្ឋាភិបាលកម្ពុជា គួរតែប្រកាន់ខ្ជាប់ការប្តេជ្ញាចិត្តក្នុងការអនុវត្តកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួន។**

រាជរដ្ឋាភិបាលកម្ពុជាត្រូវតែអនុវត្តន៍នូវកាតព្វកិច្ចជាអន្តរជាតិរបស់ខ្លួនក្នុងការគោរព ការពារ និងបំពេញនូវសិទ្ធិមនុស្សដល់ពលរដ្ឋកម្ពុជា និង ពលរដ្ឋដែលរស់នៅក្នុងប្រទេសកម្ពុជា។ សិទ្ធិក្នុងការទទួលបានលំនៅឋានសមរម្យ សិទ្ធិទទួលបានសន្តិសុខសង្គម សិទ្ធិទទួលបានសុខភាពល្អ សិទ្ធិទទួលបានអនាម័យ សិទ្ធិទទួលបានការងារធ្វើ សិទ្ធិទទួលបានអាហារ សិទ្ធិទទួលបានការអប់រំ និងសិទ្ធិចូល រួមក្នុងកិច្ចការសាធារណៈរបស់សហគមន៍មូលដ្ឋានកំពុងរងផលប៉ះពាល់ពីការបាត់បង់តំបន់បឹងទំពុន ឬជើងឯក។ ដូចដែលបានលើកឡើងនៅក្នុងការរកឃើញសំខាន់ៗនៃរបាយការណ៍នេះ តាមរយៈការផ្តល់សច្ចាប័ន ឬចូលជាសមាជិកនៃអនុសញ្ញាអន្តរជាតិ រាជរដ្ឋាភិបាល មានកាតព្វកិច្ច គោរពតាមអនុសញ្ញាអន្តរជាតិទាំងនោះដែលរួមមានដូចជា៖ កតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (១៩៧៦) អនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍(១៩៦៩)អនុសញ្ញាស្តីពីឋានៈនៃជនភៀសខ្លួន (១៩៥១) អនុសញ្ញាស្តីពីការលុបបំបាត់ រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (១៩៧៩) មាត្រា១៤(២) អនុសញ្ញាស្តីពីសិទ្ធិកុមារ (១៩៨៩) និងអនុសញ្ញាស្តីពីសិទ្ធិជន ពិការ(២០០៨)។

**៥. ការផ្តល់អាជ្ញាប័ណ្ណបូមខ្សាច់គួរត្រូវបានផ្សព្វផ្សាយជាសាធារណៈ ដើម្បីធានាថាសាធារណជន មិនរងគ្រោះដោយសារការបូមខ្សាច់។ ក្រសួងបរិស្ថាន ឬក្រសួងរ៉ែ និងថាមពល គួរពិចារណាហាមឃាត់រាល់ការបូមខ្សាច់ពីទន្លេបាសាក់ និងទន្លេមេគង្គ។**

កង្វះតម្លាភាព និងការត្រួតពិនិត្យពីការបូមខ្សាច់នៅតែបន្តចោទជាបញ្ហា។ អាជ្ញាប័ណ្ណអាជីវកម្មបូមខ្សាច់ ក៏ដូចជាបទបញ្ញត្តិ និងច្បាប់ ផ្សេងៗ ពាក់ព័ន្ធនឹងការបូមខ្សាច់នៅក្នុងទន្លេធំៗនៃប្រទេសកម្ពុជា គួរត្រូវបានបញ្ជាក់ឱ្យបានច្បាស់លាស់។ រាល់អាជ្ញាប័ណ្ណទាំងអស់ រួមទាំង ការវាយតម្លៃហេតុប៉ះពាល់លើបរិស្ថានគួរត្រូវបានផ្សព្វផ្សាយ និងដាក់ក្នុងប្រព័ន្ធទិន្នន័យសាធារណៈ។

**៦. អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ គួរចេញផ្សាយជាសាធារណៈនូវរបាយការណ៍ដែលបង្ហាញថាផ្នែកណាខ្លះនៃតំបន់បឹងទំពុន ឬជើងឯក ជាទ្រព្យសាធារណៈរបស់រដ្ឋ និងតំបន់ណាដែលបាត់បង់ប្រយោជន៍សាធារណៈដើម្បីឱ្យសាធារណជនបានពិនិត្យមើល**

ទ្រព្យសាធារណៈ មិនគួរត្រូវបានចាត់ថ្នាក់ឡើងវិញ ដោយគ្មានការចូលរួមពិគ្រោះយោបល់ពីសាធារណជននៅក្នុងដំណើរការនោះ ឡើយ។ មធ្យោបាយមួយ ដើម្បីសម្រេចការងារនេះ គឺផ្សព្វផ្សាយព័ត៌មានដល់សាធារណជន មុនពេលធ្វើចំណាត់ថ្នាក់ឡើងវិញ។

**៧. ក្រសួងធនធានទឹក និងឧតុនិយម គួរពិចារណាពន្យាការផ្តល់អាជ្ញាប័ណ្ណទាំងអស់នៅលើតំបន់ដីសើមបឹងទំពុន ឬជើងឯក ដើម្បីការពារសាធារណជនពីការរងគ្រោះដោយការបំពុល និងបាត់បង់គុណភាពទឹក។ លើសពីនេះ ក្រសួងគួរពិចារណាឱ្យបានម៉ត់ចត់ដើម្បីការពារដីចំនួន ១.០០០ ហិកតាដែលនៅសល់ក្នុងតំបន់ដីសើម ដោយចាត់ទុកជាតំបន់សំខាន់សម្រាប់ប្រភេទត្រីជិតផុតពូជ និងជាតំបន់ដីសើមដែលមានសារៈសំខាន់សម្រាប់ប្រទេសកម្ពុជា។**

មាត្រា ២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៃព្រះរាជាណាចក្រកម្ពុជា (២០០៧) អនុញ្ញាតឱ្យក្រសួងការពារតំបន់អាងទឹក ដែលកំពុងត្រូវបានបំផ្លាញដោយសកម្មភាពមនុស្ស និងកន្លែងដែលរងគ្រោះពីការឆ្លងជំងឺ។ ក្រសួងគួរប្រើប្រាស់អំណាចទាំងនេះដើម្បីជា ប្រយោជន៍សាធារណៈ ប្រសិនបើចាំបាច់។

**៨. ជម្រើសផ្សេងទៀតពីការអភិវឌ្ឍរបស់គម្រោងអាយ អិន ជី ស៊ីធី និងគម្រោងដទៃទៀត គួរត្រូវបានពិចារណា។ គំរូកូនកាត់មួយខាងក្រោមនេះ គឺជាមធ្យោបាយមួយដើម្បីជាប្រយោជន៍សាធារណៈ និងឯកជន ក្នុងការគ្រប់គ្រងតំបន់ដីសើមបឹងទំពុន ឬជើងឯក។**

**គំរូកូនកាត់**

ការប្រឹក្សាយោបល់ជាសាធារណៈពិតជាមានសារៈសំខាន់ណាស់ដល់ការគ្រប់គ្រងធនធានសាធារណៈ ដែលមានដូចជាតំបន់ដីសើម បឹង ទំពុន ឬជើងឯក ជាឧទាហរណ៍។ នៅក្នុងករណីនេះ អត្ថប្រយោជន៍នៃតំបន់បឹងទំពុនមានទំហំធំធេងណាស់ ប្រើប្រៀបធៀបទៅនឹង ផលប្រយោជន៍ឯកជនដូចជាគម្រោងអភិវឌ្ឍន៍អាន អ៊ិន ជី ស៊ីធី និងគំរោងអភិវឌ្ឍន៍ផ្សេងទៀតជាដើម។ ការស្រាវជ្រាវត្រូវតែធ្វើឡើង និង ផ្សព្វផ្សាយជាសាធារណៈដែលបញ្ជាក់ថាតើតំបន់បឹងទំពុន ឬជើងឯកទំហំប៉ុណ្ណាត្រូវអភិរក្ស ដើម្បីផ្តល់ផលប្រយោជន៍ដល់ទាំងក្រុមហ៊ុន ឯកជន និងសាធារណៈ។

ជម្រើសនានាអាចដើរទន្ទឹមគ្នាជាមួយនឹងគម្រោងអាយ អិន ជី ស៊ីធី និងការអភិវឌ្ឍផ្សេងទៀតនៅក្នុងតំបន់ដីសើមបឹងទំពុន ឬជើងឯក។ ការគ្រប់គ្រងតំបន់ដីសើមគួរត្រូវបានវាយតម្លៃ ដោយផ្អែកលើផលប្រយោជន៍ចំពោះក្រុមខុសៗគ្នា។ ទោះជាយ៉ាងណាក៏ដោយ ផលប្រយោជន៍សាធារណៈគួរតែជាអាទិភាពចម្បង ដោយសារជាគោលការណ៍ច្បាប់ បឹងនេះជាទ្រព្យសម្បត្តិសាធារណៈសម្រាប់ការប្រើប្រាស់ទាំង អស់គ្នា[១២៩]។ ផលប្រយោជន៍ដែលបានមកពីការអភិរក្សតំបន់បឹងពុន ឬជើងឯកនេះ អាចមានដូចជា៖

ក- មានប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់តាមបែបធម្មជាតិដែលមានតម្លៃទាប ឬមិនចាំបាច់ចំណាយប្រាក់ (រោងចក្រប្រព្រឹត្តកម្មទឹកកខ្វក់ដែលត្រូវបង្កើតដោយអង្គការចៃកា អាចត្រូវបានប្រើប្រាស់ដើម្បីបង្កើនសមត្ថភាពនៃប្រព័ន្ធដែលមានស្រាប់)។

ខ- មានប្រព័ន្ធកាត់បន្ថយទឹកជំនន់តាមបែបធម្មជាតិដែលមានស្រាប់។

គ- មិនប៉ះពាល់ដល់ឱកាសបង្កើតប្រាក់ចំណូលសម្រាប់សហគមន៍ក្រីក្រ។

ការការពារសិទ្ធិប្រជាពលរដ្ឋ បរិស្ថាន និងជីវចម្រុះ ជាគំរូល្អដែលអាចធ្វើទៅបានក្នុងការអភិវឌ្ឍទីក្រុង។ ទោះជាយ៉ាងនេះក្តី លុះត្រាតែចំណុចទាំងអស់នេះត្រូវបានពិចារណាត្រឹមត្រូវតាមរយៈការជជែកពិភាក្សាយ៉ាងយកចិត្តទុកដាក់ ការស្រាវជ្រាវ និងការអនុវត្តគោលការណ៍ការយល់ព្រមជាមុន ដោយសេរី និងដោយទទួលបានព័ត៌មានគ្រប់គ្រាន់។

### អនុសាសន៍សម្រាប់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន និងរាជរដ្ឋាភិបាលជប៉ុន

សំណើបង្កើតរោងចក្រប្រព្រឹត្តកម្មទឹកកខ្វក់នៅក្នុងតំបន់បឹងទំពុន ឬជើងឯកគឺមិនស្របទៅនឹងវិធីសាស្ត្រប្រកបដោយទំនួលខុសត្រូវក្នុងការអភិវឌ្ឍនោះទេ បើគិតពីកត្តាសិទ្ធិមនុស្ស បរិស្ថាន និងការគ្រប់គ្រងសារពើពន្ធ។ គម្រោងនេះត្រូវតែពិចារណាឡើងវិញ ហើយការស្រាវជ្រាវបន្ថែមត្រូវតែធ្វើឡើងដើម្បីបញ្ជាក់អះអាងពីប្រសិទ្ធភាពនៃគម្រោងនេះ។ អង្គការចៃកាមានកាតព្វកិច្ចជាអន្តរជាតិ ដើម្បីគោរពសិទ្ធិ មនុស្សតាមរយៈកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ កតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី។

### អនុសាសន៍សម្រាប់ក្រុមហ៊ុនឯកជនដែលកំពុងប្រតិបត្តិការគម្រោងអភិវឌ្ឍន៍អាយ អិន ជី ស៊ីធី ឬគម្រោងផ្សេងៗនៅក្នុងតំបន់បឹងទំពុន ឬជើងឯក

ក្រុមហ៊ុនទាំងអស់ ត្រូវតែធានាថា គម្រោងរបស់ខ្លួនមិនមានការរំលោភសិទ្ធិមនុស្សណាមួយ មុនពេល អំឡុងពេល និងក្រោយពេលបញ្ចប់គម្រោងនោះទេ[១៣០]។ ក្រុមហ៊ុន ត្រូវតែផ្តល់នូវតម្លាភាពនៅក្នុងគម្រោងរបស់ពួកគេ និងគួរតែគោរពតាមគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិ ដើម្បីបង្ហាញពីសុច្ឆន្ទៈ និងការទទួលខុសត្រូវសង្គម។

---

[១២៩] មាត្រា ១៥ នៃច្បាប់ភូមិបាលឆ្នាំ២០០១

[១៣០] អង្គការសហប្រជាជាតិ៖ គោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស ២០១១ ផ្នែកទី ២ ១៣(ក)(ខ)

# ៨. ឧបសម្ព័ន្ធ

១. ទូកដែលផ្គត់ផ្គង់ខ្សាច់ទៅកាន់ស្ថានីយបូមនៅខាងក្រោយវត្តចាក់អង្រែលើ (សូមមើលផ្នែកផែនទីសម្រាប់ទីតាំងរបស់វត្ត)









## ២. ការបាក់ស្រុតច្រាំងទន្លេនៅតាមដងទន្លេមេគង្គជិតការដ្ឋានបូមខ្សាច់









### ៣. ទិន្នន័យស្ថានីយបូមខ្សាច់ (ស្ថានីយបឹងទំពុន និងបឹងត្របែក)







Project : Boeng Trabek
Sbject : Schedule for Operation Pump
Model : 800 VTP, Motor 8

32h

| ថ្ងៃ/ខែ/ឆ្នាំ | ម៉ោងបើក/បិទ | សីតុណ្ហភាព (ហ្វា A) | សីតុណ្ហភាព (ហ្វា B) | សីតុណ្ហភាព (ហ្វា C) | UP | DOWN | Currents (A) | Total Hour | |
|---|---|---|---|---|---|---|---|---|---|
| 01.04.19 | 7.00 | 37 | 36 | 37 | 37 | 36 | 35 | 309.306.306 | |
| | 11:00 | 82 | 85 | 83 | 89 | 69 | 59 | 326.324.323 | 4h |
| 02,04,19 | 19:30 | 31 | 30 | 30 | 31 | 32 | 31 | 311,308,304 | |
| | 23:00 | 81 | 85 | 82 | 84 | 48 | 57 | 326,328,325 | 3.30 |
| 04.04.19 | 08-40 | 31 | 32 | 31 | 31 | 31 | 31 | 312.303.307 | |
| | 09:00 | | | | | | | | 0.20 |
| 05,04,19 | 6:00 | 31 | 30 | 31 | 31 | 30 | 31 | 308,302,305 | |
| | 10h.40 | 92 | 94 | 83 | 49 | 59 | 322 | 4h 40 | 3.40 |
| 07,04,19 | 6:00 | 32 | 32 | 32 | 33 | 31 | 32 | 308,308,308 | |
| | 11:00 | 85 | 87 | 86 | 50 | 60 | | 341.339.337 | 5 |
| 08,04,19 | 6:30 | 33 | 32 | 32 | 32 | 32 | 3 | 308,318,322 | |
| | | | | | | | | | |
| 09,04,19 | 20:00 | 32 | 31 | 31 | 31 | 31 | 305,312,310 | | |
| | 22:00 | 77 | 78 | 77 | 50 | 59 | 318,320,318 | | 2h |
| 10.4.19 | 2: PM | 36 | 36 | 36 | 36 | 36 | 310.308.310 | | |
| | 7: | 75 | 76 | 75 | 47 | 55 | 309,308,306 | | 5h |
| 12.4.19 | 6: | 32 | 32 | 30 | 54 | 49 | 316.314,316 | | |
| | 11: | 85 | 89 | 87 | 53 | 62 | 334.330,329 | | 5h |
| 13.04.19 | 13:30 | 35 | 36 | 33 | 34 | 34 | 311.309.305 | | |
| | 18:00 | 84 | 86 | 85 | 51 | 61 | 326.324.320 | | 4.30 |



Project : Boeng Trabek
Sbject : Schedule for Operation Pump
Model : 800 VTP, Motor 8

| ថ្ងៃ/ខែ/ឆ្នាំ | ម៉ោងបើក/បិទ | សីតុណ្ហភាព (ហ្វា A) | សីតុណ្ហភាព (ហ្វា B) | សីតុណ្ហភាព (ហ្វា C) | UP | DOWN | Currents (A) | Total Hour |
|---|---|---|---|---|---|---|---|---|
| 19.03.19 | 09:00 | 30 | 31 | 30 | 31 | 30 | 308,305,305 | 41:30 |
| | 11:00 | 74 | 75 | 74 | 44 | 54 | 320,322,324 | 2h |
| 21.03.19 | 17:30 | 32 | 33 | 32 | 33 | 33 | 310.303.307 | |
| | 19:00 | 63 | 66 | 64 | 40 | 45 | 316.316.317 | 1.30h |
| 23.03.19 | 16:15 | 36 | 37 | 36 | 36 | 35 | 309.306.304 | |
| | 19:00 | 77 | 79 | 77 | 67 | 56 | 312.313.313 | 2h45 |
| 24,03,19 | 5:00 | 37 | 37 | 36 | 37 | 35 | 309,305,308 | |
| | 11:00 | 84 | 86 | 83 | 49 | 60 | 342,339,338 | 2h |
| 24,03,19 | 19:00 | 41 | 41 | 41 | 39 | 38 | 308,305,305 | |
| 25,03,19 | 01:15 | 87 | 88 | 87 | 51 | 62 | 318,322,325 | 5.45 |
| 25,03,19 | 7:30 | 37 | 37 | 38 | 38 | 35 | 305,302,308 | |
| | 12:30 | 86 | 87 | 85 | 50 | 61 | 317,314,314 | 5h |
| 25,03,19 | 6:30 | 41 | 40 | 40 | 38 | 36 | 308,303,305 | |
| | 11:00 | 86 | 89 | 85 | 51 | 61 | 325,313,310 | 4h.30 |
| 27,03,19 | 19,40 | 30 | 31 | 31 | 31 | 30 | 308,305,305 | |
| | 22,40 | 74 | 70 | 75 | 43 | 54 | 320,328,324 | 3h |
| 28.3.19 | 11:30 AM | 31 | 31 | 30 | 31 | 31 | 234,235,234 | |
| | 3: PM | 82 | 84 | 83 | 51 | 59 | 237,937,235 | 3h30 |
| 31,03,19 | 6:30 AM | 31 | 31 | 30 | 31 | 31 | 310,303,308 | |
| | 6: PM | 96 | 90 | 92 | 54 | 65 | 235.934,233 | 11h30 |

30

## ៤. ការគណនាតាមបែបគណិតវិទ្យាត្រូវបានប្រើដើម្បីគិតលើបរិមាណខ្សាច់ទាំងអស់ដែលបានចាក់បំពេញ

តាមការប៉ាន់ស្មាន ផ្ទៃបឹងទំពុនដែលនឹងត្រូវចាក់បំពេញមានទំហំប្រហែល ១៧,៣គីឡូម៉ែត្រការ៉េ។ ជម្រៅជាមធ្យមគឺ១-២ម៉ែត្រ ដូច្នេះហើយប្រវែង៣ម៉ែត្រគឺត្រូវបានគណនាជាកម្ពស់ដែលត្រូវការសម្រាប់ការចាក់បំពេញខ្សាច់ ដើម្បីធានាថាមូលដ្ឋានស្ថិតនៅលើនីវ៉ូទឹកជំនន់។ ការគណនាគឺ ១៧.៣០០.០០០×៣ = ៥១.៩០០.០០០ ម៉ែត្រគូប។

តំបន់បឹងជើងឯកសរុបដែលត្រូវបានប៉ាន់ស្មានសម្រាប់ការចាក់បំពេញមានទំហំ ៣,៦៨ គីឡូម៉ែត្រការ៉េ។ ជាមធ្យមបឹងនេះអាចមាន ជម្រៅ ៦ម៉ែត្រ ក្នុងអំឡុងរដូវវស្សា ដូច្នេះហើយកម្ពស់ជាមធ្យមដែលត្រូវការសម្រាប់ការចាក់បំពេញខ្សាច់ ដើម្បីធានាថាមូលដ្ឋានស្ថិតនៅលើនីវ៉ូទឹកសមុទ្រគឺ៧ម៉ែត្រ។ ការគណនាគឺ ៣.៦៨០.០០០×៧ = ២៥.៧៦០.០០០ ម៉ែត្រគូប។

**បរិមាណខ្សាច់សរុបដែលត្រូវការដើម្បីចាក់បំពេញបឹង=៧៧.៦៦០.០០០ម៉ែត្រគូប។**

ជម្រៅយោងតាម អង្គការចៃកា (២០១៦) ការសិក្សាស្ដីពីគម្រោងលើកកម្ពស់ប្រព័ន្ធលូ និងបង្ហូរទឹកស្អុយ នៅក្នុងតំបន់ទីប្រជុំជននៃរាជធានីភ្នំពេញ របាយការណ៍ចុងក្រោយ លេខ២។

## ៥. ចំណុចទីតាំងបទសម្ភាស វាយតម្លៃហេតុប៉ះពាល់សង្គម និងសិទ្ធិមនុស្ស



៦. កំណត់ហេតុប្រគល់សាកសពរបស់ការិយាល័យនគរបាលបច្ចេកទេសវិទ្យាសាស្ត្រ នៃស្នងការដ្ឋាននគរបាល រាជធានីភ្នំពេញ ទៅក្រុមគ្រួសាររបស់កុមារ ឈ្មោះដារ៉ា


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
ផែនការងារនគរបាលព្រហ្មទណ្ឌ
ការិយាល័យនគរបាលបច្ចេកទេសវិទ្យាសាស្ត្រ
លេខ............

កំណត់ហេតុប្រគល់សាកសព

នៅវេលាម៉ោង.........នាទី ថ្ងៃ.........ខែ.........ឆ្នាំ.........ព.ស ២៥៦......ត្រូវនឹងថ្ងៃទី.........ខែ.........ឆ្នាំ ២០......។
ក្រោយពេលដែលក្រុមសមត្ថកិច្ចចំរុះពិនិត្យសាកសព បានធ្វើការពិនិត្យចប់សព្វគ្រប់ហើយ:
-យើងខ្ញុំឈ្មោះ.........ជាមន្ត្រីនគរបាលយុត្តិធម៌ ឋាន:.........
ប្រធានក្រុម បានធ្វើការប្រគល់សាកសព:
-ឈ្មោះ.........ភេទ.........អាយុ.........
-និនាម.........
-ជនជាតិ.........កាន់លិខិតឆ្លងដែនលេខ.........
-មុខរបរ.........មានទីលំនៅ.........
-កើតឡើងនៅវេលាម៉ោង.........នឹង.........នាទីថ្ងៃទី.........ខែ.........ឆ្នាំ២០......
នៅ.........
-សភាព.........
បានប្រគល់អោយដល់ឈ្មោះ.........
ដែលត្រូវជា.........របស់សាកសព។
-កំណត់ហេតុប្រគល់បានធ្វើចប់នៅវេលាម៉ោង.........នាទី ថ្ងៃ.........ខែ.........ឆ្នាំ.........ព.ស ២៥៦......ត្រូវនឹង ថ្ងៃទី.........ខែ.........ឆ្នាំ ២០......ដោយបានអានអោយអ្នកទទួលស្តាប់ថាពិតជាត្រឹមត្រូវ និងបានផ្តិតមេដៃស្តាំទុកជាភស្តុតាងស្រាប់។
ស្នាមមេដៃអ្នកទទួល
គ្រូពេទ្យកោសល្យវិច័យរាជធានីភ្នំពេញ
មន្ត្រីនគរបាលយុត្តិធម៌

## ៧ – កម្រងសំណួរ ស្តីអំពីការឈ្វេងយល់ពីរបៀបរស់នៅរបស់ប្រជាសហគមន៍ក្នុងតំបន់

QID001: ឈ្មោះអ្នកសម្ភាសៈ ____________________ QID002: ថ្ងៃខែឆ្នាំចុះសម្ភាសៈ ____/____/2019/20

QID003: លេខកូដសម្ភាសៈ ________________

QID004: ទីតាំងចំនុច (GPS) X: ______________

Y: ______________

| ល.រ | សំណួរ | លេខកូដចម្លើយ | រំលង |
|---|---|---|---|
| Q1.1. | តើអ្នកឈ្មោះអ្វី? | | |
| Q1.2. | លេខទូរសព្ទៈ | | |
| Q1.3. | ភេទអ្នកផ្តល់បទសម្ភាស | 1. ប្រុស<br>2. ស្រី | |
| Q1.4. | តើអ្នកមានអាយុប៉ុន្មាន? | | |
| Q1.5. | តើអ្នករៀបការហើយរឺនៅ? | 1. លីវ<br>2. រៀបការ (រស់នៅក្បែរគ្នា)<br>3. រៀបការ (រស់នៅឆ្ងាយពីគ្នា)<br>4. ពោះម៉ាយ<br>5. មេម៉ាយ<br>6. ពោះម៉ាយ ឬមេម៉ាយមានកូន | |
| Q1.6. | តើអ្នកមានសញ្ជាតិអ្វី? | 1. ខ្មែរ<br>2. វៀតណាម<br>3. ចិន<br>4. ចាម<br>5. ជនជាតិដើមភាគតិច<br>6. កម្ពុជាក្រោម<br>7. ផ្សេងៗ | |
| Q1.7. | តើផ្ទះរបស់អ្នករស់នៅ មានចំនួនប៉ុន្មានគ្រួសារដែរ? (រាប់បញ្ចូលទាំងអ្នកជួលផ្ទះ និង ម្ចាស់ផ្ទះ) | ប្រហែល#: \|__\|__\|__\|__\| | |
| Q1.8. | តើមានប៉ុន្មានអ្នករស់នៅក្នុងផ្ទះអ្នក? | ចំនួនប្រុសៈ<br>ចំនួនស្រីៈ | |
| Q1.9. | តើមេគ្រួសាររបស់អ្នកជាស្ត្រីមែនទេ? | 1. បាទ/ចាស<br>2. ទេ | |
| Q1.10. | តើនៅក្នុងគ្រួសាររបស់អ្នកមានប៉ុន្មាននាក់មានអាយុ ក្រោម១៨ឆ្នាំ? | | |
| Q1.11. | តើមានមនុស្សប៉ុន្មាននាក់នៅក្នុងគ្រួសាររបស់អ្នកដែលកំពុងរៀននៅសាកលវិទ្យាល័យ? | | |

| | | | |
|---|---|---|---|
| Q1.12 | តើមានសមាជិកគ្រួសារអ្នកណាម្នាក់មានពិការភាពដែរឬទេ? | 1. បាទ/ចាស៎<br>2. ទេ | |
| Q1.13 | បើមាន តើមានអ្វីខ្លះ? | 1. ពិបាកមើល<br>2. ពិបាកស្តាប់<br>3. ពិបាកដើរ ឬក៏ឡើងជណ្តើរ<br>4. ពិបាកចងចាំ ឬក៏ពិបាកផ្តោតអារម្មណ៍<br>5. ពិបាកមើលថែខ្លួនឯង (ដូចជា ស្លៀកពាក់ )<br>6. លំបាកក្នុងការទំនាក់ទំនងដោយប្រើភាសា | |
| Q1.14 | តើមានសមាជិកគ្រួសារអ្នកណាម្នាក់ ដែលមានអាយុច្រើននៅបន្តធ្វើការ ដែររឺទេ? | 1. បាទ/ចាស៎<br>2. ទេ | |
| Q1.15 | តើមានសមាជិកគ្រួសារអ្នកណាម្នាក់ ដែលមានអាយុច្រើត្រូវការមើលថែដែររឺទេ? | 1. បាទ/ចាស៎<br>2. ទេ | |
| Q1.16 | តើតំបន់ ឬសហគមន៍ ឬក្រុមរបស់អ្នកមានឈ្មោះដែររឺទេ? | 1. មាន<br>2. មិនមាន | |
| Q1.17 | តើមានឈ្មោះអ្វី? | | |
| Q1.18 | ប្រសិនបើទីនោះមានប្រធានភូមិ តើអ្នកមានលេខទូរសព្ទគាត់ដែររឺទេ? | 1. ឈ្មោះ៖ ________________<br>2. លេខទូរសព្ទ៖__________________ | |
| Q1.19 | តើភាគច្រើនគ្រួសារតាមខ្នងផ្ទះទាំងនេះជាអ្នកជួលផ្ទះគេ ឬផ្ទះផ្ទាល់ខ្លួន? | 1. ផ្ទះផ្ទាល់ខ្លួន<br>2. ជួលផ្ទះគេ<br>3. ពាក់កណ្តាលផ្ទះផ្ទាល់ខ្លួននិងពាក់កណ្តាលជួល<br>4. អត់ដឹង<br>5. ផ្សេងៗ | |

## ២. មុខរបរ និងការអប់រំ

| ល.រ | សំណួរ | លេខកូដចម្លើយ |
|---|---|---|
| Q2.1. | តើអ្នកប្រកបមុខរបរជាអ្វី?<br>(ចម្លើយច្រើន) | 1. កសិករ (ដាំបន្លែ)<br>2. អ្នកនេសាទ (នេសាទ)<br>3. កម្មករធ្វើការដោយកម្លាំង<br>4. អ្នកជំនួញ/ម្ចាស់អាជីវកម្ម<br>5. បុគ្គលិករដ្ឋាភិបាល<br>6. បុគ្គលិកឯកជន<br>7. បុគ្គលិកអង្គការ<br>8. កម្មកររោងចក្រ<br>9. អ្នកបើកបរ/មេកានិក<br>10. កម្មករសំណង់<br>11. អ្នកចិញ្ចឹមសត្វ<br>12. អ្នកកែច្នៃអាហារ<br>13. ផ្សេងទៀត (……… .. ) |
| Q2.2. | តើអ្នកមានចំណូលប្រចាំខែប៉ុន្មានដែរ? | ______ USD |

| | | |
|---|---|---|
| Q2.3. | តើអ្នកមានការងារផ្សេងពីការងារខាងលើដែរឬទេ? | 1. បាទ/ចាស<br>2. ទេ |
| Q2.4. | បើមាន តើអ្នកទទួលបានចំណូលប៉ុន្មានដែរ? | _______ USD |
| Q2.5. | តើប្រាក់ចំណូលរបស់អ្នកពឹងផ្អែកលើទីតាំងដែរអ្នករស់នៅរឺ? (តើប្រាក់ចំណូលពឹងផ្អែកលើបឹង ឬរស់នៅក្នុងតំបន់បណ្តោះអាសន្ន?) | 1. បាទ/ចាស<br>2. ទេ |
| Q2.6. | ប្រសិនបើអ្នកទទួលបានប្រាក់ចំណូលពីបឹង តើអ្នកមានចំណាយជួលដីគេ ឬដីផ្ទាល់ខ្លួន? | 1. ជួលដីគេ<br>2. ដីផ្ទាល់ខ្លួន<br>3. ដីរដ្ឋ ឬសាធារណៈ<br>4. ម្ចាស់គេឲ្យធ្វើ ឬធ្វើលើដីគេ |
| Q2.7. | តើអ្នកប្រកបរបរអ្វីលើផ្ទៃបឹង? | 1. កសិកម្ម (ដាំបន្លែ)<br>2. នេសាទ<br>3. ចិញ្ចឹមសត្វ<br>4. ផ្សេងៗ |
| Q2.8. | ប្រសិនបើអ្នកដាំដំណាំលើផ្ទៃបឹង តើអ្នកលក់ប៉ុន្មានភាគរយហើយ ទុកហូបប៉ុន្មានភាគរយ? | Sell: %. Price per kilo:<br>Eat: %. |
| Q2.9. | តើអ្វីជាប្រភពចំណូលចម្បងក្នុងគ្រួសាររបស់អ្នក? | 1. កសិករ (ដាំបន្លែ)<br>2. អ្នកនេសាទ (នេសាទ)<br>3. កម្មករធ្វើការដោយកម្លាំង<br>4. អ្នកជំនួញ/ម្ចាស់អាជីវកម្ម<br>5. បុគ្គលិករដ្ឋាភិបាល<br>6. បុគ្គលិកឯកជន<br>7. បុគ្គលិកអង្គការ<br>8. កម្មកររោងចក្រ<br>9. អ្នកបើកបរ/មេកានិក<br>10. កម្មករសំណង់<br>11. អ្នកចិញ្ចឹមសត្វ<br>12. អ្នកកែច្នៃអាហារ<br>13. ផ្សេងទៀត (……… .. ) |
| Q2.10. | តើប្រភពចំណូលចម្បងទទួលបានប៉ុន្មាន? | _______ USD |
| Q2.11. | តើមានសមាជិកប៉ុន្មាននាក់ក្នុងគ្រួសាររបស់អ្នកមានការងារធ្វើ? (សូមរៀបរាប់) | |
| Q2.12. | តើប្រាក់ចំណូលសរុបក្នុងគ្រួសាររបស់អ្នកប៉ុន្មាន? (សរុបចំណូលពីអ្នកធ្វើការទាំងអស់ក្នុងគ្រួសារ) | _______ USD |
| Q2.13. | តើអ្វីទៅជាកម្រិតការអប់រំខ្ពស់បំផុតដែលអ្នកសំរេចបាន? | 1. ពុំមានការអប់រំផ្លូវការ<br>2. មិនបញ្ចប់បឋមសិក្សា<br>3. បានបញ្ចប់បឋមសិក្សា<br>4. មិនបញ្ចប់អនុវិទ្យាល័យ<br>5. បញ្ចប់អនុវិទ្យាល័យ<br>6. មិនបញ្ចប់វិទ្យាល័យ<br>7. បញ្ចប់វិទ្យាល័យ<br>8. ខ្ពស់ជាងវិទ្យាល័យ |

## ៣. ការកាន់កាប់ដីធ្លី

| ល.រ | សំណួរ | កូដចម្លើយ |
|---|---|---|
| Q3.1. | តើដីដែលអ្នកកំពុងរស់នៅ ជាប្រភេទដីអ្វី ? | 1. តាមច្រាំងទន្លេ<br>2. លើប្រឡាយ<br>3. លើស្រះធម្មជាតិ<br>4. លើស្រះជីក<br>5. លើបឹង<br>6. លើផ្លូវ<br>7. លើដំបូល<br>8. លើផ្លូវរថភ្លើង<br>9. នៅក្នុងឃ្លាំង ឬសំណង់របស់គេផ្សេង<br>10. តាមរបង (វត្តអារាម សាលា ផ្សារ .....)<br>11. នៅក្នុងវត្ត<br>12. កន្លែងរស់នៅធម្មតា ខុសពីខាងលើ<br>13. ផ្សេងៗ |
| Q3.2. | តើមាននរណាម្នាក់ធ្លាប់ប្រាប់ថា នៅទីតាំងនេះជាប្រភេទដីកម្មសិទ្ធអ្វីដែរឬទេ ?<br>(បើគាត់ជាអ្នកជួលផ្ទះនេះ សូមរំលង) | 1. បាទ/ចាស (ដីឯកជន)<br>2. បាទ/ចាស (ដីសាធារណៈរបស់រដ្ឋ)<br>3. បាទ/ចាស (ដីឯកជនរបស់ពួកយើង)<br>4. បាទ/ចាស (ដីឯកជនរបស់អ្នកដទៃ)<br>5. មិនដឹង |
| Q3.3. | ប្រសិនបើមានគេប្រាប់ តើគេជាអ្នកណា? | 1. អ្នកជិតខាង/មិត្តភ័ក្ត<br>2. ប្រធានភូមិ/ប្រធានសហគមន៍<br>3. មន្រ្តីសង្កាត់<br>4. មន្រ្តីខ័ណ្ឌ<br>5. មន្រ្តីចុះបញ្ជីដីធ្លី<br>6. ម្ចាស់ដី<br>7. ផ្សេងៗ |
| Q3.4. | ប្រសិនបើមានគេប្រាប់ តើគេប្រាប់អ្នកនៅឆ្នាំណា? | |
| Q3.5. | តើទីតាំងនេះ មានឯកសារផ្លូវច្បាប់អ្វីខ្លះ ដែលបញ្ជាក់ពីស្ថានភាពដីធ្លីដែរឬទេ? (ប្រសិនបើមាន ចូររៀបរាប់ និងថតចម្លង) អ្នកអាចស្នើរសុំថតរូបភាពបាន | 1. ប្លង់រឹង<br>2. ប្លង់ទន់<br>3. លិខិតបញ្ជាក់កាន់កាប់ដីធ្លី<br>4. មិនមានទេ |
| Q3.6. | តើអ្នកបានទទួលដំណឹងមុនធ្វើការបណ្តេញចេញដែរឬទេ? | ចាស / ទេ |
| Q3.7. | តើអ្នកណាជាអ្នកផ្តល់ដំណឹងនេះ? | 1. ប្រធានភូមិ/ប្រធានសហគមន៍<br>2. មន្រ្តីសង្កាត់<br>3. មន្រ្តីខ័ណ្ឌ<br>4. មន្រ្តីចុះបញ្ជីដីធ្លី<br>5. ម្ចាស់ដី<br>6. តំណាងក្រុមហ៊ុន<br>7. ផ្សេងៗ |
| Q3.8. | តើមានអ្វីកើតឡើងនៅពេលនោះ? | |

***៤. លំនៅឋាន ហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ និងជីវភាពរស់នៅ*** *(ចំណាំ៖ សំនួរដែលមានចាក់ព័ណ៌ប្រផេះ អាចបំពេញដោយអ្នកសម្ភាសខ្លួនឯងបានតាមរយៈការអង្កេត)*

| | | | |
|---|---|---|---|
| Q4.1. | តើផ្ទះអ្នកសាងសងពីអ្វី? | 1. ដី/ដីឥត<br>2. ក្តារឈើ/រនាបឬស្សី<br>3. បេតុង/ឥដ្ឋ/ថ្ម<br>4. ថ្មដុស<br>5. ក្តារខាត់<br>6. ឥដ្ឋក្បាច់/ឥដ្ឋការូ | |
| Q4.2. | តើជញ្ជាំងផ្ទះសាងសងពីអ្វី? | 1. ឬស្សី/ស្លឹក/ស្បូវ/ស្មៅ/ត្រែង ប្របុស<br>2. ដី<br>3. ក្តារឈើ/ក្តារបន្ទះ<br>4. បេតុង/ឥដ្ឋ/ថ្ម<br>5. ស័ង្កសី/អាលុមីញ៉ូម/បន្ទះលោហៈធាតុផ្សេងៗ<br>6. ហ្វីប្រូស៊ីម៉ង់ត៍<br>7. សម្ភារៈប្រើប្រាស់ហើយ/ជំនួសបន្ថែមបិទបាំង | |
| Q4.3. | តើដំបូលផ្ទះសាងសងពីអ្វី? | 1. ឬស្សី/ស្លឹក/ស្បូវ/ស្មៅ<br>2. ក្បឿង<br>3. ក្តារឈើ/ក្តារបន្ទះ<br>4. បេតុង/ឥដ្ឋ/ថ្ម<br>5. ស័ង្កសី/អាលុមីញ៉ូម/បន្ទះលោហៈធាតុផ្សេងៗ<br>6. ហ្វីប្រូស៊ីម៉ង់ត៍<br>7. បន្ទះប្លាស្ទិច/បន្ទះជ័រ | |
| Q4.4 | តើអ្នករស់នៅទីនេះ យូរប៉ុណ្ណាហើយ? | 1. តិចជាង 1ឆ្នាំ<br>2. 1 ទៅ 2 ឆ្នាំ<br>3. 2 ទៅ 3 ឆ្នាំ<br>4. 3 ទៅ 5 ឆ្នាំ<br>5. លើសពី 5 ឆ្នាំ | |
| Q4.5 | ហេតុអ្វីបានជាអ្នក មករស់នៅទីនេះ? | | |
| Q4.6 | តើនៅទីនេះ មានភ្ជាប់ទឹករដ្ឋដែរ ឬទេ? | 1. មាន<br>2. មិនមាន (កាលមុនធ្លាប់មាន)<br>3. មិនមាន (មិនដែលមានសោះ) | |
| Q4.7 | តើនៅទីនេះ ប្រើប្រាស់ប្រភពទឹកអ្វីសម្រាប់ផឹក? | 1. ទឹករដ្ឋ<br>2. ទឹករដ្ឋ (ផ្តល់ដោយឈ្មួញកណ្តាល)<br>3. ទឹកឯកជន<br>4. ទឹកធុងទិញ ឬឡាន<br>5. ទឹកកាដុងទិញ<br>6. ទឹកអណ្តូងស្នប់<br>7. ទឹកអណ្តូងលូ<br>8. ទឹកភ្លៀង<br>9. ទឹកស្រះ ទឹកវាលស្រែ ទឹកទន្លេ<br>10. ផ្សេងៗ | |

| | | | |
|---|---|---|---|
| Q4.8. | តើនៅទីនេះ ប្រើប្រាស់ទឹកអ្វីក្រៅពីផឹក? | 1. ទឹករដ្ឋ<br>2. ទឹករដ្ឋ (ផ្តល់ដោយឈ្មួញកណ្តាល)<br>3. ទឹកឯកជន<br>4. ទឹកធុងទិញ<br>5. ទឹកកាដុងទិញ<br>6. ទឹកអណ្តូងស្នប់<br>7. ទឹកអណ្តូងលូ<br>8. ទឹកភ្លៀង<br>9. ទឹកស្រះ ទឹកវាលស្រែ ទឹកទន្លេ<br>10. ផ្សេងៗ | |
| Q4.9. | តើទឹក មានតម្លៃប៉ុន្មាន?<br>(សម្រាប់តែចម្លើយ ចាប់ពី ២ដល់១០ តែប៉ុណ្ណោះ) | ១. ______________ដុល្លា/មួយម៉ែត្រគូប<br>២. ______________ដុល្លា/មួយធុង<br>៣. ______________ដុល្លា/មួយខែ | |
| Q4.10. | ប្រសិនបើប្រើប្រាស់ទឹកអណ្តូង តើអ្នកណា ជាអ្នកទៅ យកទឹក? | 1. ឪពុកម្តាយ<br>2. កូន<br>3. ពូ/មីង<br>4. ជីដូន/ជីតា<br>5. ផ្សេងៗ | |
| Q4.11. | តើត្រូវចំណាយពេលប៉ុន្មាននាទី ដើម្បីទៅដល់ប្រភពទឹកហើយត្រឡប់មកវិញ? | 1. ទឹកនៅក្នុងលំនៅដ្ឋាន<br>2. ចំណាយតិចជាង៣០នាទី<br>3. ចំណាយច្រើនជាង៣០នាទី<br>4. មិនដឹង | |
| Q4.12. | តើទីតាំងនេះ មានភ្ជាប់ភ្លើងរដ្ឋដែរ ឬទេ? | 1. មាន<br>2. មិនមាន (កាលមុនមាន ប៉ុន្តែឥឡូវមិនមាន)<br>3. មិនមាន (មិនដែលមានសោះពីមុនមក) | |
| Q4.13. | តើនៅទីនេះ ប្រើប្រាស់ភ្លើងអ្វី? | 1. ភ្លើងរដ្ឋ<br>2. ភ្លើងរដ្ឋ (ផ្តល់ដោយឈ្មួយកណ្តាល)<br>3. ភ្លើងឯកជន<br>4. ម៉ាស៊ីនភ្លើងឯកជន<br>5. ភ្លើងសូឡា<br>6. អាគុយ<br>7. មិនមានភ្លើងប្រើប្រាស់ទេ | 1,5->5.8 |
| Q4.14. | តើភ្លើង មានតម្លៃប៉ុន្មាន?<br>(សម្រាប់តែចម្លើយ ២ដល់៤) | ១. ______________ដុល្លា/មួយគីឡូវ៉ាត់ម៉ោង<br>២. ______________ដុល្លា/មួយខែ | |
| Q4.15. | តើទឹកភ្លៀង ត្រូវហូរយ៉ាងដូចម្តេច ?<br>(មិនមានប្រព័ន្ធ សំដៅលើមិន មានទុយោ ហូរចេញ ពីផ្ទះទៅ) | 1. តាមប្រព័ន្ធលូក្រោមដី<br>2. ហូរលើដីធម្មតា<br>3. ហូរពីផ្ទះ ទៅស្រះ បឹង ទន្លេ និងវាលស្រែ<br>4. គ្មានប្រព័ន្ធបង្ហូរ<br>5. ផ្សេងៗ | |

| | | | |
|---|---|---|---|
| Q4.16. | តើប្រព័ន្ធបង្ហូរទឹក មានដំណើរការដែរ ឬទេ? | 1. ដំណើរការល្អណាស់<br>2. ដំណើរការល្អ<br>3. ដំណើរការមិនល្អ<br>4. ដំណើរការមិនល្អទាល់តែសោះ<br>5. កាលមុនដំណើរការ តែឥឡូវខូច<br>6. មិនមានប្រព័ន្ធទាំងអស់ | |
| Q4.17. | តើនរណាជាអ្នកសាងសង់ប្រព័ន្ធបង្ហូរទឹកនេះ ? | 1. អាជ្ញាធរខណ្ឌ<br>2. អាជ្ញាធរសង្កាត់<br>3. អាជ្ញាធរភូមិ<br>4. ធ្វើខ្លួនឯង<br>5. អង្គការក្រៅរដ្ឋាភិបាល<br>6. ក្រុមហ៊ុន<br>7. ផ្សេងៗ | |
| Q4.18. | តើកាកសំណល់មនុស្ស ហូរទៅណា? | 1. ប្រព័ន្ធលូក្រោមដី<br>2. ហូរលើដីធម្មតា<br>3. ហូរពីផ្ទះ ទៅកាន់ស្រះ បឹង ទន្លេ និងវាលស្រែ<br>4. មិនមានប្រព័ន្ធ<br>5. ផ្សេងៗ | |
| Q4.19. | តើប្រព័ន្ធបង្ហូរកាកសំណល់មនុស្ស មានដំណើរការដែរ ឬទេ? | 1. ដំណើរការល្អណាស់<br>2. ដំណើរការល្អ<br>3. ដំណើរការមិនសូវល្អ<br>4. ដំណើរការមិនល្អទាល់តែសោះ<br>5. កាលមុនដំណើរការ តែឥឡូវមិនដំណើរការ | |
| Q4.20. | តើអ្នកណា ជាអ្នកសាងសង់ប្រព័ន្ធបង្ហូរទឹកនេះ? | 1. អាជ្ញាធរខ័ណ្ឌ<br>2. អាជ្ញាធរសង្កាត់<br>3. អាជ្ញាធរភូមិ<br>4. ធ្វើខ្លួនឯង<br>5. អង្គការក្រៅរដ្ឋាភិបាល<br>6. ក្រុមហ៊ុន<br>7. ផ្សេងៗ | |
| Q4.21. | តើនៅទីនេះ ធ្លាប់រងគ្រោះដោយសារទឹកជំនន់ យ៉ាងហោចណាស់ម្តង ក្នុងរយៈពេល ៣ រដូវ (រដូវវស្សា ) ចុងក្រោយទេ?<br>(ប្រសិនធ្លាប់ តើរយៈពេលប៉ុន្មានទើបទឹកជំនន់ហូរអស់) | 1. បាទ/ចាស (១ ទៅ២ ម៉ោង)<br>2. បាទ/ចាស (តិចជាង ១ថ្ងៃ)<br>3. បាទ/ចាស (តិចជាង ១សប្តាហ៍)<br>4. បាទ/ចាស (១ ទៅ២សប្តាហ៍)<br>5. បាទ/ចាស (២ ទៅ៤សប្តាហ៍)<br>6. បាទ/ចាស (ច្រើនជាង ៤សប្តាហ៍)<br>7. ទេ | |

| | | | |
|---|---|---|---|
| Q4.22. | តើផ្លូវចូលមកកាន់ទីនេះ មានលក្ខណៈ ដូចម្ដេច? | 1. ផ្លូវ២ទិស (អាចបើកឡានបាន២)<br>2. ផ្លូវ១ទិស (អាចបើកបានឡានតែ១)<br>3. ផ្លូវតូច (សម្រាប់បើកតែម៉ូតូ)<br>4. ស្ពានរឹងមាំ (ឡានអាចបើកបរបាន)<br>5. ស្ពានចាស់ទ្រុឌទ្រោម (សម្រាប់បើកតែម៉ូតូ)<br>6. ផ្លូវរថភ្លើង<br>7. ជណ្ដើរ<br>8. ផ្សេងៗ | |
| Q4.23. | តើផ្លូវចូលមកទីនេះ ត្រូវបានសាងសង់ឡើងមក ពីអ្វី? | 1. បេតុង<br>2. ឈើ<br>3. ដីធម្មតា<br>4. ដីគ្រួស<br>5. ផ្សេងៗ | |
| Q4.24. | តើនៅទីនេះ មានបង្គោលភ្លើងបំភ្លឺផ្លូវដែរ ឬទេ? | 1. បាទ/ចាស - មានដំណើរការ<br>2. បាទ/ចាស - មិនមានដំណើរការ<br>3. ទេ | |
| Q4.25. | តើនៅទីនេះ មានសេវាប្រមូលសម្រាមដែរ ឬទេ? | 1. មាន (រៀងរាល់ថ្ងៃ)<br>2. មាន (២ដង ក្នុង១សប្ដាហ៍)<br>3. មាន (ម្ដង ក្នុង១សប្ដាហ៍)<br>4. មាន (រៀងរាល់ ២សប្ដាហ៍ម្ដង)<br>5. ទេ | |
| Q4.26. | ប្រសិនបើមាន តើគេគិតតម្លៃយ៉ាងដូចម្ដេច? ( ប្រចាំខែ គិតជាដុល្លា) | 1. តម្លៃ | |
| Q4.27. | តើអ្នកណា ដែលជាអ្នកផ្ដល់សេវាប្រមូលសម្រាម? | 1. ក្រុមហ៊ុន ស៊ីនទ្រី<br>2. អង្គការ CSARO<br>3. ផ្សេងៗ | |
| Q4.28. | ប្រសិនបើមិនមានសេវាប្រមូលសម្រាមនោះទេ តើអ្នកគ្រប់គ្រងសម្រាមយ៉ាងដូចម្ដេច? | 1. ដុត<br>2. កប់<br>3. បោះចោល (កន្លែងដែលគេមកប្រមូលសម្រាម)<br>4. បោះចោល (កន្លែងដែលគ្មានសេវាប្រមូល)<br>5. ផ្សេងៗ | |
| Q4.29. | តើការប្រើប្រាស់បង្គន់អនាម័យនៅទីនេះ មានលក្ខណៈដូចម្ដេច? | 1. បង្គន់ឯកជន<br>2. បង្គន់ប្រើរួមគ្នា (២ ទៅ៣គ្រួសារ)<br>3. បង្គន់សាធារណៈ (ប្រើរួមក្នុងសហគមន៍)<br>4. មិនមានបង្គន់<br>5. ផ្សេងៗ | |
| Q4.30. | បើប្រើបង្គន់សាធារណៈ តើនៅឆ្ងាយប៉ុន្មាន? | 1. តិចជាង៥០ម៉ែត្រ<br>2. ៥០ម៉ែត្រ ទៅ ១០០ម៉ែត្រ<br>3. ១០០ម៉ែត្រ ទៅ ២០០ម៉ែត្រ<br>4. ច្រើនជាង២០០ម៉ែត្រ | |

| | | | |
|---|---|---|---|
| Q4.31. | មានប្រើព័ន្ធភ្លើងបំភ្លឺដែរឬទេ? | ចាស / ទេ | |
| Q4.32. | តើសមាជិកគ្រួសាររបស់អ្នកប្រើបង្គន់ប្រភេទណា? | 1. មិនមាន<br>2. បង្គន់ចាក់ទឹក ឬ(ចុចបង្ហូរទឹក) តភ្ជាប់ទៅប្រព័ន្ធលូ<br>3. បង្គន់ចាក់ទឹក ឬ(ចុចបង្ហូរទឹក) តភ្ជាប់ទៅអាងស្តុក ឬរណ្តៅ<br>4. បង្គន់ចាក់ទឹក ឬ(ចុចបង្ហូរទឹក) បង្ហូរទៅកន្លែងផ្សេង<br>5. បង្គន់រណ្តៅមានចាន់បង្គន់សម្រាប់បត់ជើង<br>6. បង្គន់រណ្តៅគ្មានផែនបង្គន់សម្រាប់បត់ជើង<br>7. បង្គន់បត់ជើងទម្លាក់ក្នុងទឹក | |
| Q4.33. | តើអ្នកទទួលបានប័ណ្ណសមធម៌ដែរ ឬទេ? | 1. ទេ<br>2. បាទ/ចាស - កម្រិត 1<br>3. បាទ/ចាស - កម្រិត 2 | |
| Q4.34. | ប្រសិនបើមាន តើប័ណ្ណនោះនៅអាចប្រើប្រាស់បានដែរឬទេ? | ចាស / ទេ | |
| Q4.35. | តើប័ណ្ណសមធម៌ ត្រូវបានផ្តល់អោយ តាំងពីឆ្នាំណា? | តម្លៃ | |
| Q4.36. | តើពីទីតាំងនេះទៅកាន់............មានចម្ងាយប៉ុន្មាននាទី (ធ្វើដំណើរដោយម៉ូតូ)?<br>សេវាសុខភាពសាធារណៈ សំដៅលើមណ្ឌលសុខភាព មន្ទីរពេទ្យ (មិនមែនឱសថស្ថាន ទណ្ឌពេទ្យ ឬគ្លីនិក នោះទេ) | 1. ផ្សារ ____________________ នាទី<br>2. មណ្ឌលសុខភាព ______________នាទី<br>3. វត្ត _____________________នាទី<br>4. បឋមសិក្សា _________________នាទី<br>5. អនុវិទ្យាល័យ ________________នាទី | |

| ល.រ | សំនួរ | ចម្លើយ (គួរតែថតសម្លេងទុក) | រំលង | សម្គាល់ |
|---|---|---|---|---|
| Q5.1. | តើអ្នកបានដឹងពីគម្រោង ING CITY ឬគម្រោងនានាដែលបាននិងកំពុងអនុវត្តនៅក្បែរផ្ទៃបឹងនេះដែរ ឬទេ? (ដូចជា អ៊ីអនម៉ល, បុរីប៉េងហួត, រោងចក្រប្រព្រឹត្តកម្មទឹកសម្អុយ, ផ្លូវសម្តេចហ៊ុនសែន) | ចាស / ទេ | | |
| Q5.2. | តើអ្នកដឹងអ្វីខ្លះ ពីគម្រោងទាំងនោះ? | | | |
| Q5.3. | តើអ្នកដឹងព័ត៌មានទាំងនោះ តាមរបៀបណា? | 1. ប្រធានភូមិ/ប្រធានសហគមន៍<br>2. មន្ត្រីសង្កាត់<br>3. មន្ត្រីខ័ណ្ឌ<br>4. មន្ត្រីចុះបញ្ជីដីធ្លី<br>5. ម្ចាស់ដី<br>6. តំណាងក្រុមហ៊ុន<br>7. ផ្សេងៗ | | |

| | | | | |
|---|---|---|---|---|
| Q5.4. | តើអ្នកមានបានជួបប្រជុំ ឬពិគ្រោះយោបល់ជាមួយក្រុមហ៊ុនទាក់ទងនឹងគម្រោងទាំងនោះដែរ ឬទេ? | ចាស / ទេ | | |
| Q5.5. | ប្រសិនបើមានការជួបប្រជុំឬពិគ្រោះយោបល់តើអ្នកបានចូលរួមដែរឬទេ? | ចាស / ទេ | | |
| Q5.6. | ប្រសិនបើបានចូលរួម តើគេបានប្រាប់អ្នកអ្វីខ្លះទាក់ទងនឹងគម្រោង និងផលប៉ះពាល់មកលើសហគមន៍? តើអ្នកមានទទួលបានលិខិតផ្លូវការ ការជូនដំណឹង ឬការផ្តល់ព័ត៌មានដែរ ឬទេ? | | | |
| Q5.7. | តើអ្នកមានបានទទួលការប្រឹក្សាយោបល់ ទាក់ទងនឹងគម្រោងដែរ ឬទេ? | ចាស / ទេ | | |
| Q5.8. | តើការប្រឹក្សាយោបល់អំពីអ្វីខ្លះ? សូមរៀបរាប់ដំណើររឿង (តើមានអ្នកដំណាងចូលរួមទេ/ផ្តល់ព័ត៌មានច្បាស់លាស់ទេ/តើគេអនុញ្ញាតិឲ្យអ្នកអាចសួរសំណួរបានទេ?) | | | |
| Q5.9. | តើអ្នកមានបានទទួលការជូនដំណឹងដែរឬទេមុននឹងក្រុមហ៊ុនចាប់ផ្តើមអនុវត្តគម្រោង? | ចាស / ទេ | | |
| Q5.10. | ប្រសិនបើមាន តើរយៈពេលប៉ុន្មាន? | 1. ត្រឹម៦ខែ<br>2. ជាង១ឆ្នាំ<br>3. ១ឆ្នាំ ទៅ២ឆ្នាំ<br>4. ២ឆ្នាំ ទៅ៣ឆ្នាំ<br>5. លើសពី៣ឆ្នាំ | | |
| Q5.11. | តើក្រុមហ៊ុន បានស្នើរសុំការអនុញ្ញាត ឬយល់ព្រមពីសហគមន៍ដែរ ឬទេ? | ចាស / ទេ | | |
| Q5.12. | តើអ្នកទទួលនូវផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍ទាំងនោះ ដែរឬទេ? | ចាស / ទេ | | |
| Q5.13. | តើវាបានប៉ះពាល់អ្វីខ្លះ ? | | | |
| Q5.14. | តើអ្នកខាតបង់អ្វីខ្លះ ដោយសារគម្រោងទាំងនោះ? | 1. ប្រាក់ចំណូល<br>2. ផ្ទះសម្បែង<br>3. ដីធ្លី<br>4. ឱកាសសេដ្ឋកិច្ច<br>5. ផ្លូវធ្វើដំណើរ ។ល។<br>6. ផ្សេងៗ | | |
| Q5.15. | តើអ្នកបានព្យាយាមទាមទារសំណងសម្រាប់ការបាត់បង់របស់អ្នកទេ? | ចាស / ទេ | | |

| | | | | |
|---|---|---|---|---|
| Q5.16. | តើបានលទ្ធផលអ្វីខ្លះពីការទាមទារសំណងនោះ? | 1. សំណងជាលុយ<br>2. ដោះដូរដីទៅនៅកន្លែងផ្សេង<br>3. មិនមានសំណង<br>4. ផ្សេងៗ | | |
| Q5.17. | តើអ្នកមើលឃើញពីផលប៉ះពាល់អ្វីខ្លះ ទៅថ្ងៃអនាគត? (សូមរៀបរាប់) | | | |
| Q5.18. | ប្រសិនបើអ្នកបានទទួលនូវសំណង | ចាស / ទេ | | |
| | Q5.18.1 តើនរណា ជាអ្នកផ្តល់សំណងនោះ? | 1. រដ្ឋាភិបាល<br>2. ក្រុមហ៊ុន<br>3. ផ្សេងៗ | | |
| | Q5.18.2 តើគេផ្តល់សំណងនោះ តាំងពីឆ្នាំណា? | | | |
| | Q5.18.3 តើអ្វីជាជម្រើស ក្នុងការទទួលយកសំណង? | 1. សំណងជាលុយ<br>2. ដោះដូរដីទៅនៅកន្លែងផ្សេង<br>3. មិនមានសំណង<br>4. ផ្សេងៗ | | |
| | Q5.18.4 ប្រសិនបើសំណងជាលុយ តើមានចំនួនប៉ុន្មាន? | | | |
| | Q5.18.5 តើសំណងដូចគ្នាសម្រាប់អ្នករស់នៅទីនេះ ដែរឬទេ? | ចាស / ទេ | | |
| | Q5.18.6 នរណាខ្លះបានចូលរួមពិភាក្សាអំពីសំណងនោះ? | 1. ប្រធានភូមិ/ប្រធានសហគមន៍<br>2. មន្ត្រីសង្កាត់<br>3. មន្ត្រីខ័ណ្ឌ<br>4. មន្ត្រីចុះបញ្ជីដីធ្លី<br>5. ម្ចាស់ដី<br>6. តំណាងក្រុមហ៊ុន<br>7. ប្រជាជនដែលប៉ះពាល់<br>8. អង្គការក្រៅរដ្ឋាភិបាល<br>9. ផ្សេងៗ | | |
| | Q5.18.7 តើត្រូវប្រើពេលប៉ុន្មានក្នុងការទូទាត់សំណង? | 1. ត្រឹម៦ខែ<br>2. ជាង១ឆ្នាំ<br>3. ១ឆ្នាំ ទៅ២ឆ្នាំ<br>4. ២ឆ្នាំ ទៅ៣ឆ្នាំ<br>5. លើសពី៣ឆ្នាំ | | |
| | Q5.18.8 តើឯកសារអ្វីខ្លះត្រូវការដើម្បីទទួលបានសំណង? | 1. ប្លង់រឹង<br>2. ប្លង់ទន់<br>3. លិខិតបញ្ជាក់កាន់កាប់ដីធ្លី<br>4. ប័ណ្ណគ្រួសារ ឬលិខិតបញ្ជាក់ទីលំនៅ<br>5. អត្តសញ្ញាណប័ណ្ណ<br>6. មិនចាំបាច់មានឯកសារ<br>7. ផ្សេងៗ | | |
| | Q5.18.9 គេមានបានផ្តល់ឯកសារអ្វីឲ្យអ្នកទេ? | ចាស / ទេ | | |

| | | | | |
|---|---|---|---|---|
| Q5.19. | ប្រសិនបើគេផ្ដល់សំណង តើអ្នកបានទទួលយកដែរ ឬទេ? | ចាស / ទេ | | |
| | Q5.19.1 ប្រសិនបើមិនយក ហេតុអ្វី? | 1. សំណងជាលុយតិចពេក<br>2. ឲ្យដូរទៅនៅកន្លែងពិបាក<br>3. មិនត្រូវនឹងអ្វីដែលចង់បាន<br>4. ផ្សេងៗ | | |
| | Q5.19.2 តើអ្នកពេញចិត្តនឹងសំណងនោះដែរ ឬទេ? | ចាស / ទេ | | |
| | Q5.19.3 ប្រសិនបើមិនពេញចិត្ត តើអ្នករិះគន់លើគម្រោងសំណងនោះដែរ ឬទេ? | ចាស / ទេ | | |
| | Q5.19.4 តើអ្នកទទួលបានសំណងអ្វីដែរ? | 1. សំណងជាលុយ<br>2. ដោះដូរដីទៅនៅកន្លែងផ្សេង<br>3. មិនមានសំណង<br>4. ផ្សេងៗ | | |
| Q5.20. | តើក្រុមគ្រួសាររបស់អ្នកត្រូវការសំណងអ្វីខ្លះពីក្រុមហ៊ុនឬរដ្ឋាភិបាលសម្រាប់ការខាតបង់របស់អ្នក? | | | |

## ៦. ការយល់ដឹង ពីគម្រោង ING CITY

សម្រាប់អ្នកដែលមិនបានដឹងពីគម្រោងទាំងនេះ សូមផ្ដល់ព័ត៌មានមួយចំនួនទៅពួកគាត់ (ដូចជាផលប៉ះពាល់នៃបរិស្ថាន និងម្ចាស់គម្រោងទាំងនោះ)

| ល.រ | សំនួរ | ចម្លើយ (គួរតែថតសម្លេងទុក) | រំលង | សម្គាល់ |
|---|---|---|---|---|
| Q6.1. | តើអ្នកធ្លាប់បានជួបក្រុមហ៊ុន ING ទាក់ទងនឹងគម្រោងទាំងនោះដែរ ឬទេ? | ចាស / ទេ | | |
| Q6.2. | តើអ្នកធ្លាប់បានជួបក្រុមផ្សេង ទាក់ទងនឹងគម្រោងទាំងនោះ ដែរឬទេ? (សូមរៀបរាប់) | ចាស / ទេ | | |
| Q6.3. | តើអ្នកគិតថា គម្រោងទាំងនេះ ផ្ដល់អត្ថប្រយោជន៍ដល់ប្រជាជនកម្ពុជាដែរ ឬទេ? | ចាស / ទេ | | |
| Q6.4. | តើអ្នកយល់ថា ការបង្កើតគម្រោងទាំងនេះ ល្អដែរ ឬទេ? | ចាស / ទេ | | |
| Q6.5. | ជាទូទៅ តើអ្នកយល់យ៉ាងណាចំពោះការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា? | 1. អាក្រក់ខ្លាំង<br>2. អាក្រក់<br>3. ធម្មតា<br>4. ល្អ<br>5. ល្អណាស់ | | |

| | | | | |
|---|---|---|---|---|
| Q6.6. | តើអ្នកយល់យ៉ាងណា ចំពោះការអភិវឌ្ឍន៍គម្រោងនៅបឹងទំពុននេះ ?<br>(សូមអោយអ្នកឆ្លើយ ពន្យល់អោយបានក្បោះក្បាយ) | | | |
| Q6.7. | តើអ្នកធ្លាប់ជួបរឿង ដូចការអភិវឌ្ឍន៍នេះ ពីមុនដែរ ឬទេ? | ចាស / ទេ | | |
| Q6.8. | តើអ្នកមានស្គាល់អ្នកណាផ្សេង ដែលធ្លាប់ជួបប្រទះនូវការអភិវឌ្ឍន៍ដូចនេះដែរ ឬទេ? | ចាស / ទេ | | |
| Q6.9. | តើអ្នកមានមតិយ៉ាងណា ទៅកាន់ក្រុមហ៊ុន ING ? | | | |



លីកាដូ
LICADHO

បណ្ដាញយុវជនកម្ពុជា
C.Y.N

អង្គការ សមធម៌កម្ពុជា
equitable cambodia

អង្គការសមាគមធាងត្នោត
Sahmakum Teang Tnaut-a Cambodian Urban NGO

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្ដមស្នងការ
កម្ពុជា